ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ១៧ មេសា ១៩៧៥-១៧ មេសា ២០២២ សាច់រឿងរបស់អ្នករស់រានជីវិតពីរបបខ្មែរក្រហមគួរត្រូវបានផ្សព្វផ្សាយឱ្យច្រើន និងជាមេរៀនរហូត
- អគ្គរដ្ឋទូតសាធារណរដ្ឋបារាំងប្រចាំកម្ពុជាទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៦៨ ខែមេសា ឆ្នាំ២០២២

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៦៨ ខែមេសា ឆ្នាំ២០២២

## មាតិកា


### សំបុត្រ

- ផ្កាយក្រពើ, ការចងចាំមួយពីថ្ងៃ១៧ ........១
- ១៧ មេសា ១៩៧៥-១៧ មេសា ២០២២ សាច់រឿងរបស់អ្នករស់រានជីវិតពីរបបខ្មែរក្រហមគួរត្រូវបានផ្សព្វផ្សាយ .............. ៣

### ផ្នែកឯកសារ

- សុខរ៉ា ៖ យុវជនសួរចម្លើយក្រុមភ្លៅ ...... ៦

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

- អគ្គរដ្ឋទូតសាធារណរដ្ឋបារាំងប្រចាំកម្ពុជា ទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ ........... ៩
- ដំណើរទស្សនកិច្ចសិក្សារបស់សិស្សវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន កំពង់លាវ...... ១១
- សិស្សានុសិស្សវិទ្យាល័យជាស៊ីម តាកែវ ស្វែងយល់ពីផ្ទាំងពិព័រណ៍រូបថត .......... ១៥
- កងទ័ពជើងគោកចំនួន ៩០រូប ទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ.. ១៧
- វាសនារបស់ គីម កំសត់ អ្នកស៊ើប ...... ២១
- ឈា សុខឿន៖ នារីពេទ្យឃុំសម័យខ្មែរ... ២៤
- វង្វេងបាត់ប្តីនៅថ្ងៃជម្លៀស............... ២៧
- រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំព្រៃឃ្នេស.............. ២៩
- រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិបឹងជ្រោង ................ ៣៨

### ផ្នែកវេទិកាសាធារណៈ

- វេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ......៤៩
- វេទិកាប្រវត្តិសាស្ត្រគ្រួសារនៅស្រុកបូរីជលសារ ខេត្តតាកែវ.....................៥៤




កងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ កំពុងអានទស្សនាវដ្តីស្វែងរកការពិត ក្នុងអំឡុងពេលចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)


### ផ្នែកស្រាវជ្រាវរកគ្រួសារ

«ទួលពិឃាដ»

- ភូមិយោគកំណើតអ្នកបួស............... ៥៧



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧៥ព.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ ៖** ឆាំង យុ, សោម ប៊ុនថន, ដារ៉ារដ្ឋ មេត្តា, សុភ័ក្រ្ត ភាណា, ភា រស្មី, ង៉ាន់ វីន, ឡុង ដានី, ភួង សុខថា, មីន សាណាស់, ថុន ស្រីពេជ្រ, មេន នឿន, គាត ស្រីឡែន, ឈុំ រ៉ា និង ឡុង វង្សសមិទ្ធ

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ុភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសួនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង


Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ផ្កាយក្រពើ, ការចងចាំមួយពីថ្ងៃ១៧ មេសា

ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា



*មេដឹកនាំខ្មែរក្រហមជិះលើរថភ្លើង។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ក្រុមគ្រួសាររបស់ខ្ញុំត្រូវជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ។ យើងបានធ្វើដំណើរទៅកាន់ស្រុកកំណើតម្ដាយរបស់យើង ដែលស្ថិតនៅឯខេត្តតាកែវ។ កាលនោះ គឺនៅឆ្នាំ១៩៧៥ ហើយមានពាក្យចចាមអារាមបានលេចឡើងថា យើងអាចត្រឡប់មកផ្ទះនៅទីក្រុងភ្នំពេញវិញ។ ថ្ងៃមួយ ខ្មែរក្រហមបានមកប្រាប់យើងឲ្យរៀបចំបង្វេច និងចេញដំណើរ។ យើងសង្ឃឹមក្នុងចិត្តថា នេះគឺជាការធ្វើដំណើរវិលត្រឡប់មកផ្ទះយើងវិញហើយ។

ខ្មែរក្រហមបានបញ្ជូនយើងឲ្យឡើងរថភ្លើង។ នៅលើរថភ្លើងមានមនុស្សម្នាជាច្រើន ដែលយើងមិនអាចអង្គុយបាន។ បងស្រីរបស់ខ្ញុំម្នាក់មានកូនស្រីមួយដែលទើបតែមានអាយុពីរ-បីខែប៉ុណ្ណោះ។ នាងមានឈ្មោះថា តាន់ កែវកិតាណា។ យើងគ្រប់គ្នាចាប់ផ្ដើមព្រួយបារម្ភចំពោះរឿងរ៉ាវដែលអាចកើតឡើងបន្ទាប់។ នៅពេលយប់ ពូរបស់ខ្ញុំឈ្មោះ កែវ ឈឿន បានក្រឡេកមើលទៅផ្កាយឯលើមេឃ ហើយដំណាលប្រាប់យើងអំពីផ្កាយក្រពើ។

ផ្កាយក្រពើ គឺជារឿងនិទានដែលយើងបានរៀនកាលពីក្មេងៗ នេះគឺជារឿងនិទាន ស្តីអំពីក្រពើមួយក្បាល ដែលបានសាងអំពើល្អ ហើយបានក្លាយទៅជាផ្កាយនៅលើមេឃ។ ផ្កាយក្រពើតំណាងឲ្យសេចក្តីសង្ឃឹម ទិសដៅ និងសេចក្តីល្អ។ គេអាចសម្លឹងរកមើលផ្កាយក្រពើនៅលើមេឃ ព្រោះផ្កាយនេះអាចជួយចង្អុលប្រាប់ទិសដៅដល់យើងបាន។

នៅពេលធ្វើដំណើរតាមរថភ្លើងនាពេលរាត្រី ពូរបស់ខ្ញុំតែងតែចង្អុលប្រាប់ខ្ញុំអំពីផ្កាយក្រពើនោះ។ គាត់បានប្រាប់យើងទាំងអស់គ្នាថា យើងកំពុងធ្វើដំណើរត្រឡប់ទៅទីក្រុងភ្នំពេញ។ យើងទាំងអស់គ្នាសប្បាយចិត្តខ្លាំងណាស់ ដោយដឹងថានឹងបានត្រឡប់មកផ្ទះវិញ។ បើទោះបីជា យើងត្រូវធ្វើដំណើរជាច្រើនថ្ងៃ និងឈប់តាមផ្លូវជាច្រើនកន្លែងក៏ដោយ ក៏យើងមិនខ្វល់ដែរ ឲ្យតែយើងធ្វើដំណើរលើទិសដៅត្រូវមួយនេះ។ រំពេចនោះ យើងក៏បានដឹងការពិត។ បន្ទាប់ពីធ្វើដំណើរទៅដល់ខេត្តពោធិ៍សាត់ ប្រជាជនជាច្រើនត្រូវបញ្ជាឲ្យចុះពីទូរថភ្លើង។ អ្នកដំណើរផ្សេងទៀតត្រូវធ្វើដំណើរបន្តទៅកាន់ខេត្តបាត់ដំបង នៅក្បែរព្រំដែនប្រទេសថៃ។ ការធ្វើដំណើររបស់យើងមិនទាន់បានបញ្ចប់នៅឡើយទេ ពោលគឺការធ្វើដំណើររបស់យើងទើបតែចាប់ផ្តើមតែប៉ុណ្ណោះ។

សព្វថ្ងៃនេះ ខ្ញុំនៅតែនឹកឃើញដល់ផ្កាយក្រពើ។ ក្នុងអំឡុងពេលមួយនោះ ផ្កាយក្រពើបាននាំមកនូវក្តីសង្ឃឹម និងភាពរីករាយដល់យើង បើទោះបីជាវាហាក់បីដូចជាការស្រមើស្រមៃយ៉ាងណាក៏ដោយ។ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបំបែកចេញពីគ្នា។ យើងចាប់ផ្តើមជីវិតថ្មីរៀងៗខ្លួន ជាមួយនឹងការអត់ឃ្លាន ការធ្វើការធ្ងន់ និងអំពើប្រល័យពូជសាសន៍។ ខ្ញុំយល់ថាខ្លួនខ្ញុំមានសំណាង ដែលបានរស់រានមានជីវិតពីរបបដ៏ឃោរឃៅ ស្របពេលដែលសមាជិកក្រុមគ្រួសាររបស់ខ្ញុំជាច្រើននាក់បានស្លាប់បាត់បង់ជីវិត ដូចជាកូនស្រីរបស់បងស្រីខ្ញុំ និងពូរបស់ខ្ញុំជាដើម។ តាំងពីពេលនោះមក ខ្ញុំបានប្តូរការយល់ឃើញរបស់ខ្ញុំចំពោះផ្កាយក្រពើ។



រូបដើរនៅខាងមុខរាប់ពីស្តាំ៖ អៀង សារី ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេស និង វន វ៉ែន ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) ចុះពិនិត្យផ្លូវរថភ្លើង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ១៧ មេសា ១៩៧៥-១៧ មេសា ២០២២
## សាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមគួរត្រូវបាន ផ្សព្វផ្សាយឱ្យច្រើន និងជារៀងរហូត

សោម ប៊ុនថន



ប្រជាជនត្រូវបានកងយោធាខ្មែរក្រហមជម្លៀសចេញពីផ្ទះសម្បែង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រហូតមកដល់ខែមេសា ឆ្នាំ២០២២ នេះ គឺមានរយៈពេល៤៧ឆ្នាំមកហើយ ចាប់តាំងពីរបបខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ក្នុងរយៈពេលជាង៣ឆ្នាំតែប៉ុណ្ណោះដែលកងយោធារបស់ខ្មែរក្រហមឡើងគ្រប់គ្រងអំណាច របបនេះបានសម្លាប់ប្រជាជនកម្ពុជាស្លូតត្រង់ប្រមាណជាងពីរលាននាក់ និងបានបំផ្លាញស្ទើរទាំងស្រុងនូវហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសជាតិ សាសនា ទំនៀមទម្លាប់ប្រពៃណី និងវប្បធម៌។ នៅពេលបច្ចុប្បន្ន មានប្រជាជនដែលមានអាយុលើសពី៥០ ប្រមាណជាង៥លាននាក់តែប៉ុណ្ណោះ ដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនោះ នៅតែចងចាំអំពីទុក្ខលំបាកនិងហេតុការណ៍ដ៏ភ័យរន្ធត់ដែលខ្លួនបានជួបប្រទះ និងបានចាប់ផ្ដើមកសាងប្រទេសជាតិឡើងវិញដោយគ្មានអ្វីទាំងអស់ជាមួយនឹងភាពទ្រុឌទ្រោមដែលបន្សល់ទុកពីរបបនេះ។ ទោះបីយ៉ាងណា រហូតមកទល់នឹងពេលសព្វថ្ងៃ សាច់រឿងរបស់អ្នករានមានជីវិតទាំងនោះ មិនទាន់ត្រូវបានលាតត្រដាង និងផ្សព្វផ្សាយឲ្យបានទូលំទូលាយនៅឡើយ។



ប្រជាជនត្រូវបានកងយោធាខ្មែរក្រហមជម្លៀសចេញពីផ្ទះសម្បែង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)









កងយោធាខ្មែរក្រហមចូលក្នុងទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជាដោយមានការគាំទ្រពីប្រទេសជាដៃគូ និងរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតកម្មវិធីជាច្រើនដើម្បីឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អាចរៀបរាប់សាច់រឿងខ្លួន តាមរយៈការបង្កើតកម្មវិធី វេទិកាប្រវត្តិសាស្ត្រគ្រួសារដែលអ្នករស់មានជីវិតពីរបបខ្មែរក្រហមអាចរៀបរាប់ពីរឿងរ៉ាវរបស់ខ្លួនប្រាប់ទៅដល់កូនចៅ និងសាច់ញាតិរបស់ខ្លួន, វេទិកាថ្នាក់រៀនស្តីអំពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលផ្តល់ឱកាសឲ្យសិស្សសិក្សាឈ្វេងយល់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ តាមរយៈគ្រូខ្ទេស និងវាគ្មិនធ្វើបទបង្ហាញ និង គម្រោងសុខភាព និងប្រវត្តិសាស្ត្រ ដែលមានក្រុមអ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលរស់នៅតាមតំបន់ដាច់ស្រយាលទូទាំងប្រទេសកម្ពុជារាប់ពាន់នាក់ កំពុងចុះទៅសួរសុខទុក្ខ និងស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ព្រមទាំងស្តាប់រឿងរ៉ាវរបស់គាត់។ ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជានឹងកត់ត្រា រួចហើយសរសេរសាច់រឿងរបស់អ្នករស់រានមានជីវិតរបបខ្មែរក្រហម ទាំងនោះដើម្បីបោះពុម្ពផ្សាយនៅលើគេហទំព័រសារព័ត៌មាន, ទស្សនាវដ្តីស្វែងរកការពិត និងចែកជូនសាធារណជនដើម្បីអាន។

សាច់រឿងរបស់អ្នករស់រានមានជីវិតទាំងនេះ គឺជាឯកសារប្រវត្តិសាស្ត្រ និងនៅតែមានសារប្រយោជន៍សម្រាប់យុវជនជំនាន់ក្រោយ សិក្សារៀនសូត្រ ខណៈដែលប្រទេសជាច្រើននៅលើពិភពលោកនៅតែបារម្ភពីការកើតឡើងនូវអំពើហិង្សា និងការសម្លាប់យ៉ាងរង្គាល ដែលនាំទៅដល់អំពើប្រល័យពូជសាសន៍។



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរៀបរាប់អំពីរឿងរ៉ាវដែលខ្លួនបានឆ្លងកាត់ប្រាប់ដល់អ្នកស្ម័គ្រចិត្តកម្ពុជា នៅខេត្តស្វាយរៀង។ (សោម ស្រីនិច/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ស្តូបដែលទើបសាងសង់ថ្មីសម្រាប់តម្កល់អដ្ឋិធាតុជនរងគ្រោះ ដែលត្រូវបានខ្មែរក្រហមសម្លាប់ នៅវត្តបុស្សស្រីសាញ់ ស្ថិតនៅក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ (សោម ប៊ុនថន/មជ្ឈមណ្ឌលឯកសារកម្ពុជា)



អដ្ឋិធាតុរបស់ជនរងគ្រោះចំនួន៣៧៧ នាក់ ដែលត្រូវបានខ្មែរក្រហមសម្លាប់ នៅវត្តបុស្សស្រីសាញ់ ស្ថិតនៅក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ (សោម ប៊ុនថន/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ពិធីបង្សុកូលឧទ្ទិសកុសលជូនសាច់ញាតិដែលបានស្លាប់ នៅខាងមុខចេតីយ៍ ក្នុងវត្តបុស្សស្រីសាញ់ នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២២។ (សោម ប៊ុនថន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សុខ វ៉ា ៖ យុវជនសួរចម្លើយ ក្រុមក្រៅ មន្ទីរស-២១

*ដារ៉ារដ្ឋ មេត្តា*



ខ្នោះដាក់អ្នកទោសនៅខាងក្រោមកុដិរបស់ព្រះសង្ឃ នៅវត្តចំពុះក្អែកក្នុងក្រុងភ្នំពេញ ដែលខ្មែរក្រហមបានកែប្រែទៅជាកន្លែងឃុំឃាំងអ្នកទោសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សុខ វ៉ា ភេទប្រុស មានអាយុ២០ឆ្នាំ ក្នុងឆ្នាំ១៩៧៨។ ខ្ញុំមានស្រុកកំណើតនៅភូមិព្រែកដាំងព្រាំ ឃុំវាលស្បូវ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។ នៅក្នុងឆ្នាំ១៩៧៣ នៅពេលដែលកងទ័ពបដិវត្តន៍វាយចូលទៅដល់អន្លង់ខ្ញុំកំពុងជួយបេះសណ្ដែកអំរបស់ខ្ញុំនៅបឹងទួលឈើនាង លុះពេលត្រឡប់មកវិញ ខ្ញុំជួបជាមួយឈ្មោះ សោម សាលឿន។ សាលឿន សួរខ្ញុំមកពីណា ខ្ញុំប្រាប់ សាលឿន ថាមកពីជួយបេះសណ្ដែកអំ។ សាលឿន សួរនាំខ្ញុំអំពីការងារខ្ញុំ ហើយគាត់ចង់ឲ្យខ្ញុំជួយធ្វើការងារគាត់។ សាលឿន ប្រាប់ថាមិនមានការងារអ្វីធំដុំទេ គឺជួយដើរមើលកន្លែងកងទ័ពរំដោះបោះមូលដ្ឋាននៅកន្លែងណា ហើយយកមករាយការណ៍ប្រាប់គាត់។ ស្អែកឡើងខ្ញុំទៅជួប សាលឿន នៅផ្លូវជាតិលេខ១ នៅពេលដែលគាត់ជិះម៉ូតូជាមួយឈ្មោះ ប៉ែន ដារ៉េត គឺជាគិញរបស់គាត់ត្រឡប់មកពីពិនិត្យសភាពការណ៍កងរំដោះនៅពេលថ្ងៃត្រង់។ ក្រោយមកកងទ័ពបដិវត្តន៍វាយចូលដល់ភូមិខ្ញុំ។ ខ្ញុំត្រូវបានជម្លៀសមកនៅតំបន់រំដោះស្ថិតនៅភូមិកូនជ្រៃ ឃុំព្រែកអំបិល ស្រុក២០ តំបន់២៥។ ខ្ញុំបានដាច់ការទាក់ទងទាំងអស់ពីខ្សែរយៈ។

នៅក្នុងឆ្នាំ១៩៧៥ ខ្ញុំបានចូលបម្រើបដិវត្តន៍ និងបានមកនៅក្នុងអង្គភាពវរសេនាតូច ២៧៥។ រហូតដល់ចុងឆ្នាំ១៩៧៥ អង្គការបានចាត់តាំងខ្ញុំឲ្យមកនៅមន្ទីរ៤៤។ ខ្ញុំនៅមន្ទីរ៤៤រយៈពេល៣ថ្ងៃអង្គការចាត់

តាំងខ្ញុំឲ្យមករៀនបច្ចេកទេសយោធានៅសាលា៧០៣។

នៅពាក់កណ្ដាលឆ្នាំ១៩៧៦ អង្គការបានចាត់តាំងខ្ញុំមកមន្ទីរ ស-២១ នៅក្នុងអង្គភាពសួរចម្លើយ។ ថ្ងៃមួយពេលខ្ញុំកំពុងសួរចម្លើយអ្នកទោស ស្រាប់តែបងម៉ាន ដើរចូលទៅកន្លែងខ្ញុំ។ បងម៉ាន និយាយថា ខ្ញុំរស់នៅបន្ទប់អាប់អួរបេះតែរស់នៅកើតដែរ។ នៅថ្ងៃបន្ទាប់ បងម៉ាន បានមកជួបខ្ញុំនៅបន្ទប់ម្ដងទៀត ហើយឲ្យខ្ញុំទាក់ទងជាមួយ មិត្តអ៊ន មិត្តគ្រី មិត្តកាត់ ធ្វើការនៅក្រុមឯកសារ និងមិត្តបូ។ នៅចុងឆ្នាំ១៩៧៦ មិត្តកាត់ ត្រូវទៅនៅជាមួយក្រុម បងនន គឺជាអ្នកគូរផែនទីរបស់មន្ទីរ ស-២១ ចំណែកខ្ញុំនៅជាមួយ មិត្តអ៊ិន។ ក្រោយមកនៅពេលខ្ញុំនាំខ្មាំងទៅទុក ខ្ញុំដើរតាមផ្លូវបានជួបនឹងមិត្តកាត់, បងថា, មិត្តវ៉ែត ធ្វើការនៅក្នុងក្រុមអង្កៀម និងមិត្តគ្រី។ នៅពេលនោះមិត្តកាត់ និយាយថា យើងលេងៗបានសមាជិកច្រើនដែរ។

នៅក្នុងឆ្នាំ១៩៧៧ បងម៉ានមកប្រាប់ខ្ញុំថា ឥឡូវមានកម្លាំងគេមកពីក្រៅមកជួយ យើងនៅខាងក្នុងដូច្នេះត្រូវត្រៀមខ្លួនរង់ចាំជាជំនួយដែរ។ មកពីក្រៅនឹងឲ្យសញ្ញាមកយើងនៅពេលដុតផ្ទះ ហើយមិត្តត្រូវទាក់ទងសហការឲ្យជាប់ជាមួយ មិត្តឈុន។ ក្រោយមកមានភ្លើងឆេះផ្ទះ បងម៉ាន និង បងឈុនមកប្រាប់ខ្ញុំថាត្រូវតែប្រុងប្រយ័ត្នព្រោះពេលវេលាបានមកដល់ហើយ ត្រូវប្រុងប្រៀបចាំជួយវាយគេពីក្នុងវិញ។ នៅពាក់កណ្ដាលឆ្នាំ១៩៧៧ ពេលម៉ោងហូបបាយថ្ងៃ ខ្ញុំដើររកដូងទុំនៅផ្លូវខាងជើងត្រង់កន្លែងក្រុមក្ដៅបច្ចុប្បន្ន នៅពេលនោះខ្ញុំជួប បងថា ហើយគាត់សួរខ្ញុំមានរឿងអ៊ីយប់មិញ។ ខ្ញុំប្រាប់គាត់ថាខ្ញុំមិនដឹងទេ។ ក្រោយមកអង្គការបានចាត់តាំង ខ្ញុំមកនៅក្រុមក្ដៅ ហើយខ្ញុំជាប់ការទាក់ទងជាមួយ បងថា។ តាមរយៈ បងថា ខ្ញុំភ្ជាប់ទំនាក់ទំនងជាមួយឈ្មោះ ហ៊ាង និងមិត្តមាគ គឺជាគិញរបស់ សោម សារឿន។ នៅខែសីហា ឆ្នាំ១៩៧៧ អង្គការឲ្យខ្ញុំទៅកាប់ទន្ទ្រានខែត្រនៅខាងក្រៅ ខ្ញុំបានជួបជាមួយបងថា បងហ៊ាង មិត្តមាគ និងបានជួប សាលឿន កំពុងជះកង់។ ខ្ញុំសួរ សាលឿន ថា ទៅណាបង? គាត់ថាទៅកន្លែងវិញ។ ខ្ញុំសួរគាត់បន្តទៀតថា កន្លែងបងនៅទីណា? គាត់ថានៅឃ្លាំងតាមផ្លូវ១៨មីនា គឺឃ្លាំងលេខ៨២។ ក្រោយមកទៀតពេលខ្ញុំទៅយកខ្មាំង ខ្ញុំបានជួប មិត្តវ៉ែត និង មិត្តកាត់។ មិត្តកាត់ សួរខ្ញុំថាឯកសារមិត្តធ្វើចាំបាច់ឲ្យច្បាស់ម្ល៉េះ គ្រាន់តែដេញសួរត្រួសៗហើយ ហុចឯកសារមកបានហើយ។ មិត្តវ៉ែត សួរខ្ញុំបន្តទៀតថា យកអាណាល្មមៗ យកវាយមកឲ្យក្រុមអង្កៀមខ្លះទៅ កុំឲ្យរហ័សទាន់សភាពការណ៍។ នៅខែកញ្ញា ឆ្នាំ១៩៧៧ ខ្ញុំចេញទៅក្រៅរកកូនល្ហុង ពេលនោះខ្ញុំក៏ជួប សាលឿន ម្ដងទៀត ហើយគាត់សួរខ្ញុំអំពីសភាពការណ៍ខាងក្នុង។ គាត់ប្រាប់ថា នៅពេលសត្វពញាក់យំ គឺជាសញ្ញាសភាពការណ៍ដើម្បីវាយខាងក្នុង។ ក្រោយមកខ្ញុំទាក់ទងជាមួយឈ្មោះ ហ៊ាង និងមិត្តមាគ នៅពេលទៅកាត់សក់។ បងហ៊ាង និយាយថា មិនមានអ៊ីសំខាន់ជាងធ្វើឯកសារទេ ប៉ុន្តែមិត្តជឿខ្ញុំទៅ មិត្តមិនចាំបាច់ខិតខំពេកទេ នៅពេលសួរចម្លើយមិត្តធ្វើជាងក់ខ្លះទៅ គ្មានអ្នកណាអង្គុយចាំតែមើលទេ។ ក្រោយមកខ្ញុំធ្វើសកម្មភាពវាយខ្មាំងឲ្យមានសភាពទុរន់ទុរា ធ្វើការមិនកើត។ នៅខែតុលា ឆ្នាំ១៩៧៧ ខ្ញុំ បងថា បងហ៊ាង និងមិត្តមាគ ចេញទៅកាប់ទន្ទ្រានខែត្រនៅខាងក្រៅម្ដងទៀតក៏បានជួបជាមួយនឹង សាលឿន។ ពេលនោះគាត់មករកគ្រឿងបន្លាស់រថយន្ត។ បង សាលឿន បានណែនាំឲ្យយើងស្គាល់មនុស្ស៣នាក់ទៀត មានឈ្មោះ ចាន់ សុផា គឺជាមេក្រុមនៅឃ្លាំងលេខ៨២, សំ សារឿន នៅក្នុងឃ្លាំងលេខ៨២ និង សំ អុល គឺជាយុទ្ធជននៅឃ្លាំងលេខ៨២។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៧ ខ្ញុំបានចេញទៅកាប់មែកក្រខុប។ ពេលខ្ញុំដើរចេញបានបន្តិច បានជួប បងហ៊ាង និង សាលឿន ហើយពេលនោះគាត់បញ្ឈក់អំពីផែនការ ថា ការដែលធ្វើសំឡេងជាសត្វពញាក់យំ គឺជាសញ្ញាដើម្បីឲ្យមិត្តខាងក្នុងដឹង ហើយប្រុងប្រៀបខ្លួនដើម្បីចាំជួយវាយ។ នៅខែធ្នូ ឆ្នាំ១៩៧៧ នៅពេលខ្ញុំទៅយកខ្មាំងសួរចម្លើយ ខ្ញុំជួបមិត្តកាត់ ទៅយកខ្មាំងមកធ្វើឯកសារដែរ។ ខ្ញុំបានប្រាប់ មិត្តកាត់ ពីខ្នងបង្អែករឹងមាំ។ នៅពាក់កណ្ដាលខែធ្នូ ឆ្នាំ១៩៧៧ ខ្ញុំបានធ្វើសកម្មភាពវាយខ្មាំងឲ្យទុរន់ទុរា ធ្វើឯកសារ

ឲ្យរួចតែពីដៃ, មិនសួរដេញដោល, មិនវិភាគ ហើយខ្ញុំនៅអនុវត្តសកម្មភាពនេះរហូតមក។

នៅខែមករា ឆ្នាំ១៩៧៨ ខ្ញុំនៅតែធ្វើសកម្មភាពនេះជាបន្តទៀត។ ខ្ញុំយកខ្មាំងទៅ ទុកហើយត្រឡប់មកវិញបានដើរជុំគ្នាជាមួយមិត្តកាត់។ មិត្តកាត់សួរខ្ញុំថា តើអ្នកណាខ្លះជាមិត្តបង្អែករបស់យើង ខ្ញុំបានប្រាប់គាត់ថានៅ ខាងក្រៅមាន សាលឿន គឺជាប្រធានឃ្លាំង នៅតាមផ្លូវទៅស្អាត។ នៅពាក់កណ្តាលខែកុម្ភៈ ឆ្នាំ១៩៧៨ នៅថ្ងៃមួយពេលខ្ញុំហូបបាយរួច ខ្ញុំទៅជញ្ជូនឈើចូលធ្វើទ្រើងត្រឡាច ស្រាប់តែជួប មិត្តសាលឿនទៀត។ សាលឿន និយាយថា ឥឡូវមិត្ត ធ្វើសកម្មភាពបន្តទៀតទៅ ព្រោះខ្ញុំជិតនាំទ័ពមកហើយគឺនៅចុងខែកុម្ភៈ ឆ្នាំ១៩៧៨ នេះ។ នៅចុងខែកុម្ភៈ ឆ្នាំ១៩៧៨ ខ្ញុំនិងបងថា នាំគ្នាធ្វើសកម្មភាពសួរចម្លើយខ្មាំងនារី ហើយឲ្យដើរស្រាត ព្រមទាំងវាយខ្មាំងនារីនោះឲ្យទុរន់ទុរាធ្វើការមិនកើត។ នៅខែមីនា ឆ្នាំ១៩៧៨ អង្គការចាប់ខ្ញុំតែម្តង។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារលេខJ០០០៧៨។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់សុខរ៉ា ពិតប្រាកដយ៉ាងណានោះទេ។**



កុដិរបស់ព្រះសង្ឃនៅវត្តចំពុះក្អែកក្នុងក្រុងភ្នំពេញ ដែលខ្មែរក្រហមកែប្រែទៅជាកន្លែងឃុំឃាំងអ្នកទោសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អគ្គរដ្ឋទូតសាធារណរដ្ឋបារាំងប្រចាំកម្ពុជាទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ

*សុភ័ក្ត្រ ភាណា*



អគ្គរដ្ឋទូតសាធារណរដ្ឋបារាំងប្រចាំកម្ពុជា លោក ហ្សាក់ ប៉ីឡេ ទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ នាព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០២២។ (សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



គណៈប្រតិភូមមកពីស្ថានទូតសាធារណរដ្ឋបារាំងប្រចាំកម្ពុជា និងលោកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា នៅបណ្ណាល័យសម្តេចម៉ែ នាព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០២២។ (សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

បណ្ណាល័យសម្តេចម៉ែ មានកិត្តិយសនិងសេចក្តីសោមនស្សទទួលស្វាគមន៍ឯកអគ្គរដ្ឋទូតថ្មីនៃសាធារណរដ្ឋបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា លោក ហ្សាក់ ប៉ីឡេ និងលោក ម៉ៃខល លី ប្រធានការិយាល័យនៃក្រសួងការបរទេសបារាំង នាព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០២២។

បណ្ណាល័យសម្តេចម៉ែ គឺជាគេហដ្ឋានខ្មែរដែលសាងសង់ឡើងក្នុងសម័យអាណានិគមបារាំង។ បណ្ណាល័យនេះមានផ្ទុកឯកសារមកពីច្រើនប្រភព ក្នុងនោះក៏មានបណ្តុំឯកសារជាភាសាបារាំង។ ឯកសារជាភាសាបារាំងទាំងនេះ ដើរតួនាទីជាធនធានដ៏សំខាន់ ពីព្រោះថាឯកសារទាំងនេះគឺជាកំណត់ហេតុរៀបរាប់អំពីព្រឹត្តិការណ៍នានា នៅមុនសម័យកាលសង្គ្រាម ក្នុងអំឡុងសង្គ្រាម និងក្រោយសង្គ្រាម ដែលតម្រូវឲ្យអ្នកសិក្សាស្រាវជ្រាវ មានចំណេះដឹងភាសាបារាំង ដើម្បីស្វែងយល់ និងទទួលបានព័ត៌មានទាំងអស់នេះឲ្យបានពេញលេញ។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្ហាញដល់ភ្ញៀវកិត្តិយសនូវប្លង់ស្ថាបត្យ-កម្មសហសម័យនៃវិទ្យាស្ថានស្លឹករឹត ដែលរចនា

ឡើងដោយស្ថាបត្យករស្ត្រីដ៏ល្បីរន្ទឺកម្រិតពិភពលោក គឺលោកស្រី ហ្សា ហា ហាឌីដ។ វិទ្យាស្ថានស្ទឹករីត គឺជាសំណង់ស្ថាបត្យកម្មរំឭកការចងចាំអំពីរបបឃោរឃៅតែមួយគត់ ដែលរចនាដោយស្ថាបត្យករស្ត្រី។ ការប្រើប្រាស់ស្នាដៃស្ថាបត្យកម្មសហសម័យបែបទំនើបរបស់លោកស្រី ហ្សា ហា ហាឌីដ គឺដើម្បីលើកកម្ពស់តួនាទីរបស់ស្ត្រី ដែលភាគច្រើនជាអ្នករស់រានជីវិតពីរបបខ្មែរក្រហម និងជាកម្លាំងចលករដ៏ចាំបាច់ក្នុងការកសាង និងការអភិវឌ្ឍសង្គមជាតិ។ សំណង់ស្ថាបត្យកម្មនេះត្រូវធ្វើឡើងដោយស្ត្រី ដែលមានកិត្តិសព្ទល្បីល្បាញក្នុងឆាកអន្តរជាតិ។

សម្តេចម៉ែ ព្រះអង្គសព្វព្រះរាជហឫទ័យ រាជប្រទានការប្រើប្រាស់ព្រះនាមរបស់ព្រះអង្គជាឈ្មោះនៃបណ្ណាល័យសម្តេចម៉ែ ដែលជាផ្នែកមួយនៃសំណង់ដ៏ប្រណិតនេះ។ ទ្រង់ព្រះរាជារំពឹងថា នៅថ្ងៃណាមួយសំណង់នេះនឹងលេចវត្តមានឡើងជាស្ថាពរ។

បច្ចុប្បន្ន បណ្ណាល័យសម្តេចម៉ែ បានចែកចាយឯកសារអេឡិចត្រូនិចដ៏សំខាន់ផ្តល់ជាព័ត៌មានប្រវត្តិ-សាស្ត្ររាប់លានច្បាប់ដល់យុវជន-យុវនារីកម្ពុជា ដែលមានចំនួនប្រមាណជាង៦៥ភាគរយនៃប្រជាជនកម្ពុជាសរុប ដើម្បីសិក្សាស្រាវជ្រាវ និងយល់ដឹងឲ្យបានកាន់តែប្រសើរអំពីប្រវត្តិសាស្ត្ររបស់ខ្លួន។ ប្រជាជនកម្ពុជាក៏អាចស្វែងរកនូវកំណត់ហេតុប្រវត្តិសាស្ត្រក្នុងទម្រង់អេឡិចត្រូនិច នៅតាមបណ្តាមជ្ឈមណ្ឌលឯកសារសាខាទាំងប្រាំរបស់បណ្ណាល័យសម្តេចម៉ែ ដែលតាំងទីនៅក្នុងខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តតាកែវ ស្រុកអន្លង់វែងនៃខេត្តឧត្តរមានជ័យ និង កោះថ្មនៃខេត្តត្បូងឃ្មុំ។

ក្នុងអំឡុងទស្សនកិច្ចនេះ ភ្ញៀវកិត្តិយស និងលោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានពិភាក្សាអំពីប្រធានបទជាច្រើនជុំវិញយុត្តិធម៌អន្តរកាល និងដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចការដែលត្រូវធ្វើបន្ត។ គួររំឭកថា សាធារណរដ្ឋបារាំង គឺជាសហហត្ថលេខីនៃការគាំទ្របង្កើតឲ្យមានសាលាក្តីខ្មែរក្រហម ដែលបម្រើដល់យន្តការស្វែងរកការពិតនិងយុត្តិធម៌សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរាប់លាននាក់។







អគ្គរដ្ឋទូតសាធារណរដ្ឋបារាំងប្រចាំកម្ពុជា លោក ហ្សាក់ ប៉ុឡេ ទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ នាព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០២២។ (សុភ័ក្រ្ត ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅចុងបញ្ចប់ លោកឯកអគ្គរដ្ឋទូត ហ្សាក ប៉ុឡេ បានថ្លែងអំណរគុណចំពោះការទទួលស្វាគមន៍យ៉ាងរាក់ទាក់ និងបង្ហាញការកោតសរសើរដល់កិច្ចការចងក្រងឯកសារដ៏មានសារសំខាន់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបម្រើដល់ការសិក្សាស្រាវជ្រាវ និងជំរុញការយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជានៅក្នុងស្រទាប់យុវជន-យុវនារីជំនាន់ក្រោយក្នុងកម្រិតជាតិ តំបន់ និងអន្តរជាតិ។

# ដំណើរទស្សនកិច្ចសិក្សា

## របស់សិស្ស វិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន កំពង់លាវ មកកាន់មជ្ឈមណ្ឌលឯកសារខ្មែរក្រហមខេត្តព្រៃវែង

*គា រស្មី*



*សិស្សវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន កំពង់លាវ ទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារខ្មែរក្រហម ខេត្តព្រៃវែង។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

កាលពីខែមីនា ឆ្នាំ២០២២ កន្លងមក មជ្ឈមណ្ឌលឯកសារខ្មែរក្រហមខេត្តព្រៃវែង បានបង្កើតកម្មវិធីដំណើរទស្សនកិច្ចសិក្សាមួយជាមួយសិស្សានុសិស្សមកពីវិទ្យាល័យ សម្តេចតេជោ ហ៊ុនសែនកំពង់លាវ ក្នុងគោលបំណងចង់សិស្សានុសិស្សសិក្សាឈ្វេងយល់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ តាមរយៈការមើលផ្ទាំងពិព័រណ៍រូបភាព។ ដំណើរទស្សនកិច្ចសិក្សានេះមានការជួយសម្របសម្រួលពីលោក ហួន ប៊ុន គឺជានាយកវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន កំពង់លាវ។

សិស្សានុសិស្សចំនួន២៣នាក់ និងលោកគ្រូប្រវត្តិវិទ្យា១នាក់បានធ្វើដំណើរមកដល់មជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង ដោយអនុវត្តតាមគោលការណែនាំរបស់ក្រសួងសុខាភិបាល។ សិស្សានុសិស្សបានមើលផ្ទាំងពិព័រណ៍រូបភាពអចិន្ត្រៃយ៍នៅខាងក្រៅមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែងរួមមាន៖ ប្រវត្តិរូបកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម ការរៀបអាពាហ៍ពិពាហ៍ ការហូបអាហាររួម ការធ្វើការងាររួម ទីតាំងសម្លាប់ និងទីតាំងតម្កល់អដ្ឋិធាតុ។ បន្ថែមលើនេះ សិស្សានុសិស្សបានពិព័រណ៍រូបថតស្តីអំពីជីវិតគ្រួសារ

សិស្សវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន កំពង់លាវ ទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារខ្មែរក្រហមខេត្តព្រៃវែង។
(ដេង ពន្សាវ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)





ប្រជាជន១៧ មេសា ដែលបានជម្លៀសចេញពីទីក្រុងភ្នំពេញ។

បន្តមកសិស្សានុសិស្សបានមើលផ្ទាំងពិព័រណ៍រូបថតអចិន្ត្រៃយ៍នៅខាងក្នុងការិយាល័យមជ្ឈមណ្ឌលឯកសារខ្មែរក្រហមខេត្តព្រៃវែង រួមមានៈ រូបភាពដែនទីរណ្តៅសាកសពនៅភូមិភាគបូព៌ា, ទីតាំងសម្លាប់មនុស្ស, កន្លែងតម្កល់អដ្ឋិធាតុ និងមន្ទីរសន្តិសុខ។ សិស្សានុសិស្សបានសិក្សាឈ្វេងយល់ទាក់ទងទៅនឹងរូបថតរបស់ជនរងគ្រោះដែលបានថតក្នុងគុកទួលស្លែង ការធ្វើការងារលើកទំនប់ ១ មករា ខេត្តកំពង់ធំ និងរូបថតដែលនិយាយអំពីជីវិតរបស់ក្រុមរណសិរ្សសាមគ្គីរំដោះជាតិកម្ពុជាដែលរស់នៅក្នុងព្រៃ។

ក្រោយពីបានទស្សនាពិព័រណ៍រូបភាព សិស្សានុសិស្សបានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម ៖

**ស៊ាន ស៊ាងលី** ភេទស្រី អាយុ១៧ឆ្នាំ រៀននៅវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន កំពង់លាវ ថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រសង្គម បាននិយាយថា



*ស៊ាន ស៊ាងលី អាយុ១៧ឆ្នាំ រៀននៅវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន កំពង់លាវ ថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រសង្គម។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

មុនដំបូងខ្ញុំបានដឹងអំពីសម័យខ្មែរក្រហមតាមរយៈ តានិងយាយរបស់ខ្ញុំ។ យាយរបស់ខ្ញុំរៀបរាប់ថា នៅក្នុងសម័យខ្មែរក្រហម ប្រជាជនត្រូវធ្វើការងារធ្ងន់ធ្ងរជាច្រើន ប៉ុន្តែមិនទទួលបានអាហារហូបគ្រប់គ្រាន់នោះទេ ហើយនៅពេលដែលមានជំងឺផ្សេងៗមិនមានថ្នាំព្យាបាល។ ខ្ញុំនៅចាំរឿងមួយរបស់លោកយាយខ្ញុំ ធ្វើឲ្យខ្ញុំមានសេចក្តីអាណិតចំពោះលោកយាយជាខ្លាំង គឺនៅពេលដែលខ្មែរក្រហមយក លោកយាយទួតរបស់ខ្ញុំទៅកសាង ហើយលោកយាយខ្ញុំមិនដឹងនៅតែរង់ចាំនៅផ្ទះ រហូតទាល់តែសួរលោកយាយទួតម្នាក់ទៀតទើបដឹងថាអង្គការយកគាត់ទៅសម្លាប់បាត់ហើយ។ ក្នុងពេលនិយាយរឿងនេះ ខ្ញុំមានសេចក្តីអាណិតដល់លោកយាយខ្ញុំយ៉ាងខ្លាំង ព្រោះទឹកមុខរបស់គាត់ក្រៀមក្រំ ស្ទើរតែស្រក់ទឹកភ្នែក ហើយខ្ញុំមានអារម្មណ៍ថាខ្ញុំមានសំណាងណាស់ដែលកើតមិនទាន់សម័យខ្មៅងងឹតមួយនោះ។ មួយវិញទៀត នៅពេលឃើញផ្ទាំងពិព័រណ៍បង្ហាញពីទីតាំងសម្លាប់ និងតម្កល់អដ្ឋិធាតុនៅវត្តធ្លក ខ្ញុំមានអារម្មណ៍អាណិតអាសូរដល់ប្រជាជនទាំងអស់ ព្រោះថាយើងមិនដឹងអំពីទោសកំហុសអ្វីសោះត្រូវបានអង្គការយកទៅសម្លាប់ដោយមិនដឹងខ្លួន។ និយាយជារួមទៅ ដំណើរទស្សនកិច្ចសិក្សានៅថ្ងៃនេះមានសារសំខាន់ណាស់សម្រាប់ខ្ញុំ ព្រោះអាចឲ្យខ្ញុំដឹងកាន់តែច្បាស់អំពីជំនាន់ ប៉ុល ពត និងបង្កើនចំណេះដឹងបន្ថែមទៀតទាក់ទងប្រវត្តិសាស្ត្ររបស់ជាតិខ្លួន។

**ឆាំ រស់** ភេទប្រុស អាយុ១៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិធ្លុយ ស្រុកពោធិ៍រៀង ខេត្តព្រៃវែង បានរៀបរាប់ ខ្ញុំគឺជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន កំពង់លាវ។ កាលពីក្មេងលោកយាយរបស់ខ្ញុំធ្លាប់បាននិយាយអំពីជីវិតរបស់គាត់ក្នុងសម័យខ្មែរក្រហម ថាអត់មានអាហារហូបចុកគ្រប់គ្រាន់ ធ្វើការហួសកម្លាំង និងយកប្រជាជនទៅសម្លាប់ចោលអស់ជាច្រើននាក់។ អំឡុងពេលនោះ ខ្ញុំមិនសូវជាជឿគាត់ប៉ុន្មានទេ ព្រោះខ្ញុំនៅក្មេងមិនបានគិត ប៉ុន្តែឥឡូវខ្ញុំជឿជាក់ថារបបខ្មែរក្រហមពិតជាកើតមានមែន ហើយអ្វីដែលលោកយាយរបស់ខ្ញុំនិយាយគឺជាការពិត។ លើសពីនេះទៅទៀត ខ្ញុំធ្លាប់បានមើលវីដេអូចាក់ផ្សាយក្នុងទូរទស្សន៍ ដែលនិយាយអំពីប្រវត្តិរបស់ខ្មែរក្រហម ការគាបសង្កត់ឲ្យធ្វើការធ្ងន់ៗ និងការធ្វើទារុណកម្មផ្សេងៗ។



*ឆាំ រស់ អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន កំពង់លាវ។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

**ស៊ុន និតា** ភេទស្រី អាយុ១៨ឆ្នាំ គឺជាសិស្សថ្នាក់ទី១២C នៃវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន កំពង់លាវ ផ្នែកវិទ្យាសាស្ត្រសង្គម បាននិយាយថា មុនដំបូងនៅពេលដែលខ្ញុំឮម្តាយ ឪពុករបស់ខ្ញុំនិយាយអំពីសម័យខ្មែរក្រហមថាគាត់ពិបាកក្នុងកា

រស់នៅ និងការហូបចុក ប៉ុន្តែខ្ញុំមិនបានជឿគាត់នោះទេ ព្រោះគិតថាគាត់និយាយកុហក។ ក្រោយមកនៅពេលដែលខ្ញុំបានចំណាយពេលមួយព្រឹកក្នុងការដើរទស្សនាផ្ទាំងពិព័រណ៍ពីមួយទៅមួយ ធ្វើឲ្យខ្ញុំមានការផ្លាស់ប្តូរគំនិតថាសម័យខ្មែរក្រហមពិតជាកើតមានមែននៅក្នុងប្រទេសកម្ពុជា។ ចំពោះមូលហេតុដែលខ្ញុំជឿបែបនេះគឺ មកពីខ្ញុំបានឃើញផ្ទាំងពិព័រណ៍ជាច្រើនដែលបង្ហាញអំពីការធ្វើការងាររបស់ប្រជាជន ការជម្លៀសប្រជាជន ការហូបអាហាររួមគ្នា ការធ្វើទារុណកម្ម និងការសម្លាប់មនុស្សយ៉ាងឃោរឃៅរបស់ ប៉ុល ពត។ លើសពីនេះទៅទៀត ពិព័រណ៍ដែលបង្ហាញអំពីឆ្អឹងជនរងគ្រោះនៅភ្នំកំប្ញុក ស្រុកបាភ្នំ ខេត្តព្រៃវែង និងនៅមន្ទីរសន្តិសុខវត្តធ្លក ខេត្តស្វាយរៀង គឺជាភស្តុតាងដ៏សំខាន់មួយ ដែលបានបង្ហាញឲ្យក្មេងជំនាន់ក្រោយឃើញ និងជឿជាក់។



ស៊ុន និតា អាយុ១៨ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន កំពង់លាវ ផ្នែកវិទ្យាសាស្ត្រសង្គម។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាចុងក្រោយ ខ្ញុំចង់សំណូមពរឲ្យក្រុមការងារនៅតែបន្តធ្វើកម្មវិធីមួយនេះឡើងដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹង និងបានស្គាល់របបខ្មែរក្រហមកាន់តែច្បាស់។



សិស្សវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន កំពង់លាវ ទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារខ្មែរក្រហម ខេត្តព្រៃវែង។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សានុសិស្សវិទ្យាល័យជាស៊ីម តាកែវ
## ស្វែងយល់ពីផ្ទាំងពិព័រណ៍រូបថតខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តតាកែវ

ង៉ាន់ វីន



សិស្សានុសិស្សថ្នាក់ទី៨ចំនួន១១នាក់ មកពីវិទ្យាល័យជាស៊ីម តាកែវ ទស្សនាផ្ទាំងពិព័រណ៍រូបថត ដែលដាក់តាំងបង្ហាញនៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តតាកែវ។ (ង៉ាន់ វីន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ សិស្សានុសិស្សថ្នាក់ទី៨ចំនួន១១នាក់ មកពីវិទ្យាល័យជាស៊ីម តាកែវ បានចូលមកទស្សនាផ្ទាំងពិព័រណ៍រូបថត ដែលដាក់តាំងបង្ហាញនៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តតាកែវ។ មជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តតាកែវ បានដាក់តាំងបង្ហាញផ្ទាំងពិព័រណ៍ចំនួន៨ផ្ទាំងនៅក្នុងបរិវេណខាងមុខទីស្នាក់ការមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តតាកែវ ដើម្បីបង្ហាញពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រទាក់ទងនឹងរបបខ្មែរក្រហមដូចជា៖ រូបថតបង្ហាញពីការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសកម្ពុជាក្នុងអំឡុងពេលសង្គ្រាមរ៉ាំរ៉ៃ នាដើមទសវត្សរ៍ឆ្នាំ១៩៧០ (រូបថតស្ពានជ្រោយចង្វារ), រូបថតមេដឹកនាំខ្មែរក្រហមដែលបានបង្កឲ្យមានការបាត់បង់ជីវិតមនុស្សរាប់លាននាក់ក្នុងអំឡុងពេលគ្រប់គ្រងរបស់ខ្លួន និងរូបថតស្តីពីដំណើរវិលត្រឡប់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មកកាន់ស្រុកកំណើតរបស់ខ្លួន បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅក្នុងខែមករា ឆ្នាំ១៩៧៩។

ជាដំបូង ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តតាកែវបានណែនាំសិស្សានុសិស្សទាំងនោះឲ្យពិនិត្យមើល និងស្វែងយល់ពីរូបថតនិងខ្លឹមសារនៃ

រូបថតនីមួយៗនៃផ្ទាំងពិព័រណ៍ទាំង៨ផ្ទាំង។ សិស្សម្នាក់ក្នុងចំណោមសិស្សទាំងអស់បានសួរសំណួរក្នុងគោលបំណងចង់ស្គាល់មុខមាត់របស់តាម៉ុក ដែលជាប្រធានភូមិភាគនិរតី។ ក្រុមការងារបានចង្អុលបង្ហាញសិស្សម្នាក់នោះពីរូបថត តាម៉ុក អមជាមួយនឹងការពន្យល់បន្ថែមពីតួនាទី និងប្រវត្តិរបស់ តាម៉ុក។

តាម៉ុក គឺជាលេខាភូមិភាគនិរតីឬភូមិភាគ៤០៥។ ភូមិភាគនេះរួមមានខេត្តកំពតនិងខេត្តតាកែវទាំងមូល ស្រុកពីរក្នុងខេត្តកំពង់ស្ពឺ (ស្រុកសំរោងទងនិងស្រុកគងពិសី) និងស្រុកប្រាំក្នុងខេត្តកណ្តាល (ស្រុកកណ្តាលស្ទឹង ស្អាង កោះធំ កៀនស្វាយ និង ស្រុកលើកដែក)។ ភូមិភាគ នេះចែកចេញជាបួនតំបន់គឺ ៖ តំបន់១៣ តំបន់៣៣ តំបន់៣៥ និង តំបន់២៥។ យោងតាមសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបោះពុម្ពឆ្នាំ២០២០ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជាបានឲ្យដឹងពីសាវតាររបស់ តាម៉ុក ដោយសង្ខេបថា៖ «តាម៉ុកកើតឆ្នាំ១៩២៦ នៅខេត្តតាកែវ។ តាម៉ុក បានបួសរៀនអស់ជាច្រើនឆ្នាំ ហើយបានរៀបការ ជាមួយប្អូនជីដូនមួយរបស់គាត់ឈ្មោះ អ៊ុក ឃឹម ហើយមានកូនបួននាក់។ ឆ្នាំ១៩៤៩ តាម៉ុកធ្វើជាប្រធានឥស្សរស្រុកក្នុងខេត្តតាកែវ។ តាម៉ុក បានចូលជាសមាជិកក្រុមកុម្មុយនីស្តនៅឆ្នាំ១៩៦៣។ ពីឆ្នាំ១៩៦៨ ដល់ឆ្នាំ១៩៧៨ តាម៉ុកជាលេខាភូមិភាគនិរតី។ នៅខែវិច្ឆិកាឆ្នាំ១៩៧៨ តាម៉ុក ត្រូវបានតែងតាំងជាអនុលេខាទីពីរបក្សកុម្មុយនីស្តកម្ពុជា។ បន្ទាប់ពីការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យ តាម៉ុក មិនដែលស្នើសុំការលើកលែងទោស ហើយមិនដែលមានបំណងចុះចូលជាមួយរដ្ឋាភិបាលទេ។ តាម៉ុក ត្រូវបានចាប់ខ្លួនដោយកងទ័ពរដ្ឋាភិបាលនៅក្បែរព្រំដែនថៃ នៅខែមីនា ឆ្នាំ១៩៩៩។

មុននឹងសិស្សានុសិស្សវិលត្រឡប់ទៅកាន់ថ្នាក់រៀនរបស់ខ្លួនវិញ ក្រុមការងារយើងបានណែនាំពីទីតាំងមជ្ឈមណ្ឌលឯកសារកម្ពុជាមួយកន្លែងទៀត ដែលមានទីតាំងស្ថិតនៅក្នុងបរិវេណមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តតាកែវ ព្រមទាំងបានពិពណ៌នាពីគោលបំណងនៃការបង្កើតមជ្ឈមណ្ឌលនេះថា ដើម្បីផ្តល់ឱកាសដល់សិស្សានុសិស្សគរុសិស្ស គ្រូបង្រៀន អ្នកស្រាវជ្រាវ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានចូលប្រើប្រាស់ឯកសារនិងរៀនសូត្របន្ថែមទៀតពីប្រវត្តិសាស្ត្រខ្មែរក្រហម សម្រាប់ការចងចាំ និងទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ជាលើកទីពីរទៀត។



សិស្សានុសិស្សថ្នាក់ទី៨ចំនួន១១នាក់ មកពីវិទ្យាល័យជាស៊ីម តាកែវ ទស្សនាផ្ទាំងពិព័រណ៍រូបថត ដែលដាក់តាំងបង្ហាញនៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តតាកែវ។ (ង៉ាន់ វីន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# កងទ័ពជើងគោកចំនួន៩០រូប ទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ

ឡុង ដានី



កងទ័ពជើងគោកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២ ។ (សុខ វណ្ណៈ និង ឈុំ រ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



នៅព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២ ក្រុមការងារវិមានឈ្នះ ឈ្នះបានដឹកនាំសិក្ខាកាមដែលជាកងទ័ពជើងគោកចំនួន៩០រូបមកទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ។ ជាការចាប់ផ្ដើម លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម បានមានប្រសាសន៍ជម្រាបដល់សិក្ខាកាមថា មជ្ឈមណ្ឌលឯកសារកោះថ្ម ត្រូវបានបង្កើតឡើងក្រោមការផ្ដួចផ្ដើមរបស់ឯកឧត្ដម នាយឧត្ដមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេសសម្ដេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេសក្រសួងការពារជាតិ និងលោក ឆាំង យុ នាយក មជ្ឈមណ្ឌលឯកសារកម្ពុជា។ មជ្ឈមណ្ឌលឯកសារកោះថ្មត្រូវបានដាក់ឲ្យដំណើរការប្រើប្រាស់ជាសាធារណៈចាប់ពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ក្រោមការសហការយ៉ាងជិតស្និទ្ធរវាងក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការពារជាតិ និងមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងគោលបំណងដូចខាងក្រោម៖

១) ដើម្បីបង្ហាញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៦០ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០។

២) ដើម្បីពង្រឹងដល់ដំណើរការសន្តិភាព និងទប់ស្កាត់ជម្លោះនានាតាមរយៈកម្មវិធីអប់រំៗ កម្មវិធីអប់រំនេះនឹងផ្តល់ឱកាសឲ្យយុវជនជំនាន់ក្រោយដែលភាគច្រើនរស់នៅតាមជនបទបានចូលរួមរៀនសូត្រៗ

៣) លើកទឹកចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងការចែករំលែកអំពីរឿងរ៉ាវបុព្វហេតុ ពិសោធន៍ផ្ទាល់ខ្លួនដល់ក្មេងៗជំនាន់ក្រោយៗ

៤) ប្រមែប្រមូលរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទីតាំងបទឧក្រិដ្ឋដែលបានបន្សល់ពីរបបខ្មែរក្រហមៗ

ជាកិច្ចបន្តលោក ឡុង ដានី បានដឹកនាំសិក្ខាកាមដើរទស្សនាពិព័រណ៍រូបថតដែលបន្សល់ទុកពីទសវត្សរ៍ឆ្នាំ១៩៦០ ដល់ទសវត្សរ៍ឆ្នាំ១៩៩០ៗ រូបថតទាំងនោះរួមមាន ៖ រូបថតបង្ហាញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជាដោយចាប់ផ្តើមចេញពីតំបន់កោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងស្រុកស្នួល ខេត្តក្រចេះៗ រូបថតនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលធ្វើឲ្យប្រជាជនកម្ពុជាប្រមាណ២លាននាក់បានស្លាប់ៗ រូបថតភ័ស្តុតាងមួយចំនួនអំពីបទឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមមកលើប្រជាជនកម្ពុជាៗ រូបគំនូរបង្ហាញអំពីដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុលពតនៅថ្ងៃទី២០ខែមិថុនាឆ្នាំ១៩៧៧ និងចុងក្រោយគឺរូបថតស្តីអំពីការផ្តួចផ្តើមបង្កើតគោលនយោបាយឈ្នះឈ្នះរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ និងការទទួលបានសន្តិភាពពេញលេញនៅក្នុងឆ្នាំ១៩៩៨ៗ កោះថ្មគឺជាទីតាំងប្រវត្តិសាស្ត្រនៃដំណើរផ្សងគ្រោះថ្នាក់ដល់អាយុជីវិតរបស់សម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្ត៤នាក់ផ្សេងទៀតរួមមាន៖ នុច ថន, ញឹក ហួន, ស៊ូ គឹមស្រ៊ាង ហៅ សាញ់ និង វ៉ា ប៉ោអ៊ាន ដើម្បីស្វះស្វែងរកកិច្ចអន្តរាគមន៍ និងកសាងកម្លាំងវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពតៗ នៅយប់ថ្ងៃ





ទី ២០ ខែមិថុនា ឆ្នាំ១៩៧៧ សម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្ត៤នាក់ទៀត បានសម្រេចចិត្តក្នុងស្ថានភាពដ៏លំបាកជាទីបំផុត ដោយបានធ្វើដំណើរចាកចេញពីទីបញ្ជាការដ្ឋានវរសេនាធំតំបន់២១ ស្ថិតនៅក្នុងភូមិកោះថ្មឃុំទន្លូង ស្រុកមេមត់ខេត្តត្បូងឃ្មុំទាំងយប់ឆ្ពោះទៅកាន់ស្រុក ឡុកនិញ ខេត្តសុងបៃ (បច្ចុប្បន្នស្រុក ឡុកនិញ ខេត្តប៊ិញហ្វឿក) ប្រទេសវៀតណាមៗ

លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំអំពើប្រល័យពូជសាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជា







កងទ័ពជើងគោកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារ កោះថ្ម ខេត្តត្បូងឃ្មុំ នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២ ។ (សុខ វណ្ណៈ និង ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក៏បានធ្វើបទបង្ហាញអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និយមន័យអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមក្នុងគោលបំណងទប់ស្កាត់កុំឲ្យមានអំពើឃោរឃៅកើតឡើងម្តងទៀតនៅប្រទេសកម្ពុជា និងប្រទេសផ្សេងៗទៀតនៅលើសកលលោក។

នៅចុងបញ្ចប់លោក ផេង ពង្សរ៉ាស៊ី បានចាក់បញ្ចាំងភាពយន្តឯកសារចំនួន២ដល់សិក្ខាកាមដែលជាកងទ័ពជើងគោកបានទស្សនា គឺខ្សែភាពយន្តឯកសារស្តីពីដំណើររបស់សមមិត្ត ហ៊ុន សែន ទៅប្រទេសវៀតណាម ដើម្បីប្រមែប្រមូលកងកម្លាំងវាយបកមកលើរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ និងភាពយន្តមួយទៀត គឺខ្សែភាពយន្តស្តីអំពីមរតក និងការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨។ លោក ផេង ពង្សរ៉ាស៊ី ក៏បានពន្យល់ណែនាំដល់សិក្ខាកាមដែលជាកងទ័ពជើងគោកទាំងអស់អំពីសារសំខាន់នៃការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងផលប៉ះពាល់នៃអំពើប្រល័យពូជសាសន៍ជាលក្ខណៈបុគ្គលម្នាក់ក្រុមគ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល។

សិក្ខាកាមដែលជាកងទ័ពជើងគោកបានបង្ហាញនូវចំណាប់អារម្មណ៍ដូចខាងក្រោម៖

**លោកឧត្តមសេនីយ៍ត្រី ខឹម បូណា** នាយិការងសេនាធិការកងទ័ពជើងគោកបានមានប្រសាសន៍



ថា នាងខ្ញុំបានមកចូលរួមទស្សនកិច្ចសិក្សាជាប្រវត្តិសាស្ត្រដ៏អស្ចារ្យនេះ ដោយបានឃើញនូវភ័ស្តុតាងជាក់ស្តែង និង រូបថតប្រវត្តិសាស្ត្រនេះ ធ្វើឲ្យនាងខ្ញុំរំភើប និងក្តុកក្តួលនឹកដល់គុណបំណាច់សម្តេចតេជោ ហ៊ុន សែន ដែលបានយកជីវិតធ្វើជាដើមទុនដើម្បីរំដោះប្រទេសជាតិយើងឲ្យរួចផុតរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ជាចុងក្រោយ នាងខ្ញុំសូមគោរពជូនពរឲ្យសម្តេចតេជោមានសុខភាពល្អ ដឹកនាំប្រទេសឲ្យមានសន្តិភាពជារៀងរហូត។

**អនុសេនីយ៍ទោ ជុន សុធី** ធ្វើការនៅការិយាល័យទី៥កងទ័ពជើងគោកបានមានប្រសាសន៍ថា ខ្ញុំមានការរំភើបរីករាយណាស់ដែលមកធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្មដែលជាទីតាំងប្រវត្តិសាស្ត្រយោធាមួយ ដែលសម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្ត៨នាក់ទៀតធ្លាប់បានចាកចេញទៅប្រទេសវៀតណាម ដើម្បីប្រមែប្រមូលកម្លាំង និងរកជំនួយពីប្រទេសវៀតណាម ដើម្បីមករំដោះប្រទេសកម្ពុជាយើងឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ប៉ុល ពត។ លោក អនុសេនីយ៍ទោ ជុន សុធី ក៏មានការរីករាយដែរដែលក្រុមការងារវិមានឈ្នះ ឈ្នះ និងមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំទទួលស្វាគមន៍ និងធ្វើបទបង្ហាញយ៉ាងច្បាស់អំពីបណ្តុំរូបថត និងដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧។



កងទ័ពជើងគោកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២ ។
( សុខ វណ្ណៈ និង ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# ខាសនារបស់ គឹម កំសត់ អ្នកស៊ើបការណ៍ ឱ្យវៀតកុង និងនីរសារតំបន់២៤

ភួង សុខថា



គឹម កំសត់ អាយុ៧៨ឆ្នាំ ជាប្រជាពលរដ្ឋរស់នៅភូមិស្វាយដោរ ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៧ ខែ១មករា ឆ្នាំ១៩៧០ ខ្ញុំបានចូលបម្រើបដិវត្តន៍ៗ ដំបូងឡើយ ខ្ញុំធ្វើការនៅក្នុងកងស៊ើបការណ៍ឲ្យកងកម្លាំងវៀតណាម ជាមួយសមាជិក១២នាក់ផ្សេងទៀតៗ រាល់ពេលដែលខ្ញុំចេញទៅស៊ើបការណ៍ម្តងៗ ខ្ញុំអត់មានកាន់អាវុធទេ ហើយដើរធម្មតាដូចគេដូចឯង ដើម្បីកុំឲ្យខាងលន់នល់ ចាប់អារម្មណ៍ខ្ញុំៗ ដូច្នេះតួនាទីរបស់ខ្ញុំ គឺគ្រាន់តែទៅយកព័ត៌មានពីទីតាំងកងទ័ពខ្មាំងនៅកន្លែងណា? កន្លែងលាក់អាវុធធុនធំនៅកន្លែងណា? កន្លែងមេបញ្ជាការធំៗស្នាក់នៅកន្លែងណា? ហើយមូលដ្ឋានកាំភ្លើងធំរបស់ខ្មាំងនៅត្រង់ណាប៉ុណ្ណោះៗ មុខព្រួញស៊ើបការណ៍របស់ខ្ញុំ គឺចាប់ពី(ឃុំ)កំពង់សឹងទៅ(ស្រុក)ពាមជរ កាត់តាមតាគោក ល្វា និងអ្នកលឿងៗ ក្រុមខ្ញុំមានសមាជិកទាំងអស់ប្រាំនាក់ៗ វិធីសាស្ត្រស៊ើបការណ៍របស់ខ្ញុំគឺខ្ញុំធ្វើជាអ្នកលក់ដូរៗ ខ្ញុំពុន(វែក)មាន់ពុនទាយកទៅលក់នៅក្នុងផ្សារ ដើម្បីបន្លំខ្លួនចូលទៅស៊ើបការណ៍ឲ្យកាន់តែជ្រៅក្នុងទឹកដីខ្មាំងកាន់កាប់ៗ រាល់ពេលចូលទៅស៊ើបការណ៍ម្តងៗ គឺខ្ញុំប្រថុយជីវិតណាស់ៗ ថ្ងៃមួយ ខ្ញុំបានជួបជាមួយមិត្តភក្តិធ្លាប់រៀនជាមួយគ្នានៅតាមផ្លូវៗ មិត្តខ្ញុំគេធ្វើជាទាហានខាងលន់នល់ៗ យើងបានជជែកគ្នាពីរឿងការងារៗ យើងឯកភាពគ្នាថា លាក់ការណ៍សម្ងាត់រៀងខ្លួនៗ ជារៀងរាល់ពេលដែលខ្ញុំយកព័ត៌មានបានម្តងៗ ខ្ញុំត្រូវរាយ

ការណ៍ពីព័ត៌មានទាំងនោះមកឲ្យ អាឡូង ដែលជាមេបញ្ជាការខាងកងកម្លាំងវៀតណាម (វៀតកុង)។ អាឡូង កំណត់ថ្ងៃ (ពេលវេលា) វាយថ្ងៃណាគឺស្រេចតែគាត់។

រហូតមកដល់ពាក់កណ្តាលឆ្នាំ១៩៧២ សង្គ្រាមរវាងទាហាន លន់ នល់ និងវៀតកុង បានកើតឡើង។ ខ្ញុំនិងសមាជិកក្រុម២នាក់ទៀត ត្រូវចេញទៅកាន់មុខព្រៃញលា ហើយសមាជិកក្រុម២នាក់ផ្សេងទៀត គឺត្រូវចេញទៅមុខព្រៃញខាងក្រាំងពុក ឆ្ពោះឡើងទៅ (កំពង់) ត្របែក។ ខ្ញុំចេញទៅដល់ត្រឹមតែពាក់កណ្តាលផ្លូវប៉ុណ្ណោះ ក៏ត្រូវផ្អាក និងរត់ពួននៅក្នុងត្រង់សេ (លេណដ្ឋាន) ព្រោះមានសង្គ្រាមកើតឡើង។ ខ្ញុំឃើញមានយន្តហោះទម្លាក់គ្រាប់បែក និងមានការដាក់ពង្រាយកងទ័ពខាង លន់ នល់ ជាច្រើននាក់។ នៅម៉ោងប្រហែលជា១០ព្រឹក អាវុធចាប់ផ្តើមផ្ទុះនៅសមរភូមិក្រសាំងចារ។ នៅម៉ោងប្រហែល១១កន្លះ គ្រាប់ផ្លោងមួយគ្រាប់បានធ្លាក់ចំត្រង់សេដែលខ្ញុំនិងសមាជិកម្នាក់ទៀតកំពុងលាក់ខ្លួន។ ត្រង់សេ បានបាក់សង្កត់សមាជិកក្រុមខ្ញុំម្នាក់នោះស្លាប់ភ្លាមៗ។ បន្តិចក្រោយមក គ្រាប់ផ្លោងមួយគ្រាប់ទៀត បានធ្លាក់ចំកន្លែងដដែល។ លើកនេះ ខ្ញុំត្រូវរបួសនិងសន្លប់លែងដឹងខ្លួន។ នៅម៉ោងប្រហែល១២យប់ ទើបខ្ញុំដឹងខ្លួនឡើងវិញ។ គេយកខ្ញុំទៅដាក់នៅសេនាធិការតំបន់២៤។ ត្រចៀករបស់ខ្ញុំទាំងសងខាង ស្ទើរស្តាប់លែងឮអ្វីទាំងអស់។ ខ្ញុំបានសម្រាកព្យាបាលនៅក្នុងសេនាធិការតំបន់២៤រហូតដល់បានគ្រាន់បើ ទើបគេ (កម្មាភិបាល ថ្នាក់លើ) ប្រគល់ខ្ញុំមកឲ្យខាងមន្ទីរនីសារតំបន់២៤។ ខ្ញុំធ្វើការនៅក្នុងកងស៊ើបការណ៍អស់រយៈពេលជាង២ឆ្នាំ។ ក្នុងរយៈពេលនេះ ខ្ញុំបានរាយការណ៍ពីតំបន់ខ្មាំងទៅឲ្យកងកម្លាំងវៀតណាមមិនតិចជាង៣០ដងទេ។

ខ្ញុំអាចស្តាប់ឮបានខ្លះៗ។ ចាប់តាំងពីពេលនោះមក ខ្ញុំលែងធ្វើការនៅក្នុងកងស៊ើបការណ៍ទៀតហើយ។ ខ្ញុំត្រូវនៅធ្វើការក្នុងមន្ទីរនីសារតំបន់២៤វិញ។ នៅទីនោះ ខ្ញុំស្គាល់កម្មាភិបាលធំៗមួយចំនួនដូចជា តាជ័យ ជាប្រធានមន្ទីរតំបន់២៤។ តាឈូក ជាប្រធានតំបន់២៤។ តាឈឹម ជាប្រធានសេដ្ឋកិច្ចតំបន់២៤។ តាប៉ក់ ជាប្រធាននីរសារតំបន់២៤ និង ចាន់ ចក្រី ជាមេបញ្ជាការកងពលលេខ២ប្រចាំភូមិភាគបូព៌ា។ ភារកិច្ចរបស់ខ្ញុំនៅក្នុងមន្ទីរនីរសារ គឺជាអ្នករត់សំបុត្រពីមន្ទីរតំបន់២៤ទៅឲ្យកម្មាភិបាលតាមឃុំមួយចំណុះឲ្យតំបន់២៤។ ខ្ញុំធ្លាប់យកលិខិតទៅឲ្យ ចាន់ ចក្រី ម្តងដែរ។

នៅពាក់កណ្តាលឆ្នាំ១៩៧៥ ខ្ញុំត្រូវអង្គការស្នើឲ្យរៀបការប្រពន្ធ។ ចាប់តាំងពីរៀបការប្រពន្ធរួច ខ្ញុំត្រូវអង្គការផ្លាស់ប្តូរកន្លែងធ្វើការរហូត។ ដំបូង ខ្ញុំត្រូវបញ្ជូនទៅធ្វើការនៅកន្លែង ឡូតដ្ឋ។ ក្រោយមក ប្អូនខ្ញុំម្នាក់ដែលជិតដិតជាមួយអង្គការថ្នាក់លើ បានបង្ហើបប្រាប់ខ្ញុំថា ខ្ញុំមានឈ្មោះក្នុងបញ្ជីដែលត្រូវចាប់ខ្លួនយកទៅដាក់គុកទួលជ្រែ។ ប្អូនខ្ញុំវាបានសរសេរសំបុត្រក្លែងក្លាយមួយឲ្យខ្ញុំ។ ខ្ញុំកាន់សំបុត្រនេះរត់ចេញពីការដ្ឋាន ឡូតដ្ឋ ឆ្ពោះទៅកាន់មន្ទីរតំបន់ ដើម្បីទៅរកប្រពន្ធខ្ញុំ។ នៅតាមផ្លូវ មានកម្មាភិបាលច្រើននាក់ណាស់សួរនាំខ្ញុំពីដំណើររបស់ខ្ញុំ។ គ្រប់ពេល ខ្ញុំបង្ហាញសំបុត្រក្លែងក្លាយនោះទៅពួកគេ។ ទីបំផុតខ្ញុំបានមកដល់មន្ទីរតំបន់។ ពេលនោះ ប្រពន្ធខ្ញុំកំពុងប្រជុំជាមួយ តាជ័យ ព្រោះគាត់ក៏ជានីរសារតំបន់ដែរ។ ប្រពន្ធខ្ញុំចុះមកជួបខ្ញុំ។ ខ្ញុំបានប្រាប់គាត់តាមដំណើរសាច់រឿងដែលសមមិត្ត សាញ់ រកចាប់ខ្លួនខ្ញុំមកកាន់ទួលជ្រែ។ ដឹងរឿងហើយ ប្រពន្ធខ្ញុំបាននាំខ្ញុំទៅជួបជាមួយ តាជ័យ។ ខ្ញុំហុចលិខិតដែលខ្ញុំកាន់ជាប់នៅនឹងដៃទៅឲ្យប្រពន្ធខ្ញុំហុចបន្តទៅឲ្យ តាជ័យ។ តាជ័យ អានរួចក៏និយាយថា «បើវា (សាញ់) ហ៊ានមកចាប់គឺត្រូវចាប់វាដាក់គុកជំនួសតែម្តងទៅ»។ ក្រោយមក ខ្ញុំបានទៅស្នាក់នៅក្នុងការដ្ឋានលា អស់រយៈពេល៣ខែទៀត ទើបត្រូវផ្លាស់ប្តូរទៅនៅ ទឹកវិល ពាមជរ និងនៅព្រៃប្រទល់ក្របី៥០០។

នៅឆ្នាំ១៩៧៧ ព្រឹត្តិការណ៍តាមចាប់ សោភឹម បានរំដើបរំជួលខ្លាំង។ កម្មាភិបាលធំៗមួយចំនួនត្រូវចាប់ខ្លួន និងសម្លាប់។ ខ្ញុំនិងប្រពន្ធបានគិតគ្នាថា នឹង

ចាកចេញពីកន្លែងធ្វើការ ទៅកាន់ស្រុកកំណើតម្តាយនៅឯស្វាយដោរ។ ប្រពន្ធខ្ញុំបានឡើង (ធ្វើដំណើរ) ទៅមន្ទីរតំបន់២៨ ដើម្បីយកគំរូលិខិតអនុញ្ញាតមួយចំនួនទុកគ្រាន់ប្រើប្រាស់នៅតាមផ្លូវ។ គាត់ (ប្រពន្ធ) ស៊ីញ៉េ ហើយបោះត្រាលើលិខិតទាំងនោះរួចរាល់អស់ ទុកតែចន្លោះដែលត្រូវបំពេញតាមជាក់ស្តែងប៉ុណ្ណោះ។ ព្រលឹមឡើងម៉ោងប្រហែល៨ព្រឹក យើងបានចាកចេញតាមទូកមួយគ្រឿងដែលលួចពីគេ ឆ្ពោះមកកាន់ស្រុកកំណើតម្តាយ។ កាលនោះ ទឹកកំពុងលិចភូមិអ្នកស្រុកនៅឡើយ។ ម៉ោងប្រហែល១០ថ្ងៃដដែល យើងបានមកដល់គោលដៅ។ ស្នាក់នៅផ្ទះម្តាយបានប្រហែលកន្លះខែ យើងទាំងអស់គ្នាត្រូវកម្មាភិបាលខ្មែរក្រហមខាងនិរតី បង្ខំឲ្យចាកចេញទៀត។ នៅតាមផ្លូវ ខ្ញុំបានប្តូរឈ្មោះរបស់ខ្ញុំពី គឹម កំសត់ មកជា ស្រី អេង វិញ ព្រោះចង់គេចឲ្យផុតពីការតាមរកចាប់ខ្លួនពីសំណាក់ខ្មែរក្រហមខាងនិរតី តាមរយៈការស្រាវជ្រាវប្រវត្តិរូបពីមុនរបស់ខ្ញុំ។ ខ្ញុំប្រើឈ្មោះ ស្រី អេង រហូតមកដល់បច្ចុប្បន្ននេះ។

រហូតមកដល់ឆ្នាំ១៩៧៩ ខ្ញុំបានវិលត្រឡប់មករស់នៅឯផ្ទះវិញ។ មេភូមិ បានស្នើឲ្យខ្ញុំធ្វើជាប្រធានក្រុមកងប្រវាស់ដៃនៅក្នុងភូមិ។ ក្រោយមក ខ្ញុំត្រូវបានស្នើឲ្យធ្វើជាប្រធានក្រុមបក្សប្រជាជនកម្ពុជា រហូតដល់សព្វថ្ងៃ។ ចំពោះព្រឹត្តិការណ៍ដែលខ្ញុំបានជួបកន្លងមកដល់ពេលនេះ ខ្ញុំគ្មានស្រណោះស្រណោកអ្វីបន្តិចទេ។ ទោះបីជាត្រចៀកទាំងសងខាងរបស់ខ្ញុំនៅតែស្តាប់អ្វីមិនឮរហូតដល់បច្ចុប្បន្ន ដោយសារសង្គ្រាមនាពេលនោះក៏ដោយ ក៏ខ្ញុំមិនស្តីបន្ទោសអ្វីទាំងអស់។ ផ្ទុយទៅវិញ ខ្ញុំសប្បាយចិត្តចំពោះជីវិតរបស់ខ្ញុំនាពេលនេះ។ ខ្ញុំរស់នៅតែពីរនាក់ប្តីប្រពន្ធនៅឯស្រុកកំណើត។ កូនៗរបស់ខ្ញុំមានប្តីប្រពន្ធអស់ហើយ ហើយពួកគេរស់នៅឆ្ងាយៗពីខ្ញុំក្នុងជីវភាពដែលអាចរ៉ាប់រងខ្លួនឯងបានដោយមិនធ្វើឲ្យឪពុកម្តាយពិបាកចិត្តឡើយ។ បើមិនរវល់ពីកិច្ចការគណបក្សទេ ខ្ញុំនៅផ្ទះដឹកតែ ជួយប្រពន្ធដាំស្ល និងធ្វើស្រែបន្តិចបន្តួច។



ទេសភាពវាលស្រែរដូវប្រាំង ក្នុងឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។
(ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឈា សុខឿនៈ នារីពេទ្យឃុំសម័យខ្មែរក្រហម

*ភា រស្មី*



*ឈា សុខឿន នៅផ្ទះរបស់គាត់ ស្ថិតនៅភូមិកែវស្នា ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ (ភា រស្មី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

*នៅឆ្នាំនេះ ឈា សុខឿន មានអាយុជិត៧០ឆ្នាំហើយ។ គាត់មិនសូវមានពេលទំនេរនៅផ្ទះឡើយ ព្រោះគាត់មានភារកិច្ចសំខាន់មួយចំនួនដែលកំពុងអនុវត្តនៅក្នុងភូមិ ឃុំរបស់គាត់។ សុខឿន ក្រៅពីជួយរៀបចំម្ហូបអាហារសម្រាប់ចង្ហាន់ប្រគេនព្រះសង្ឃនៅក្នុងវត្ត គាត់គឺជាជំនួយការរបស់ក្រុមគ្រូពេទ្យឃុំ។ សុខឿន បានអប់រំអ្នកភូមិឲ្យយល់ដឹងអំពីសារសំខាន់នៃការប្រើប្រាស់មន្ទីរពេទ្យសម្រាប់ថែរក្សាសុខភាពផ្ទាល់ខ្លួន។ សុខឿនមានសុខភាពល្អ និងរឹងប៉ឹងដូចពេលដែលគាត់ស្ថិតក្នុងវ័យក្មេងអញ្ចឹង។ កាលពីទសវត្សរ៍ឆ្នាំ១៩៧០ សុខឿន គឺជាកម្មាភិបាលនារីភូមិកែវស្នា គឺជាកម្មាភិបាលពេទ្យឃុំព្រៃឃ្នេស និងជាអ្នកដែលអង្គការចាត់តាំងជាខ្មែររំដោះប្រចាំឃុំព្រៃឃ្នេសដែលទុកចិត្តក្នុងការសម្រេចបញ្ជូនយុវជន និងយុវនារី នៃឃុំព្រៃឃ្នេសឲ្យចូលបម្រើបដិវត្តន៍។ សុខឿន បានត្អូញត្អែរថា គាត់សោកស្តាយចំពោះការចំណាយពេលវេលាចូលបម្រើបដិវត្តន៍របស់គាត់នាពេលកន្លងមក។ ខាងក្រោមនេះ គឺជាសម្តីរបស់ សុខឿន ដែលបាននិយាយប្រាប់ក្រុមការងារមជ្ឈមណ្ឌលឯកសារខ្មែរក្រហម ខេត្តព្រៃវែង អំពីបទពិសោធន៍របស់គាត់៖*

*«ខ្ញុំឈ្មោះ ឈា សុខឿន អាយុ៦៧ឆ្នាំ។ សព្វថ្ងៃខ្ញុំរស់នៅភូមិកែវស្នា ឃុំព្រៃឃ្នេស ស្រុកមេសាង*

ខេត្តព្រៃវែង។ នៅក្នុងឆ្នាំ១៩៧០ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ខ្ញុំសម្រេចចិត្តចូលធ្វើជាកងឈ្លបនៅក្នុងភូមិកំណើតរបស់ខ្ញុំ ដើម្បីតាមទារឲ្យសម្តេចឪ ឡើងគ្រប់គ្រងអំណាចវិញ និងដើម្បីការពារប្រជាជននៅក្នុងភូមិ។ ក្រុមរបស់ខ្ញុំមានសមាជិកចំនួន១២នាក់។ ម៉ន និង សារ៉ាត គឺជាអ្នកគ្រប់គ្រងក្រុមកងឈ្លប។ ពួកយើងគឺជាកម្លាំងជួរមុខដែលត្រៀមខ្លួនគ្រប់ពេលសម្រាប់ការស្ម័គ្រចិត្តចូលធ្វើជាយោធា។ ក្រុមកងឈ្លបទាំងអស់តម្រូវឲ្យចូលរៀនវគ្គនយោបាយនៅពេលយប់ ដូចប្រជាជនឯទៀតដែរ។ យើងរៀនអំពី «គោលមាគ៌ាសង្គ្រោមប្រជាជន»។ ក្រៅពីរៀនសូត្រវគ្គនយោបាយ តួនាទីរបស់យើងជាកងឈ្លប គឺដើរមើល យាមកាម និងស៊ើបយកការណ៍ពីប្រជាជននៅក្នុងភូមិអំពីសកម្មភាពធ្វើទំនាក់ទំនងក្បត់ ប្លន់ស្រូវអង្ករ និងសត្វចិញ្ចឹមផ្សេងៗទៅឲ្យខាង លន់ នល់ យកទៅរាយការណ៍ឲ្យប្រធានសហករណ៍បានដឹង។ នៅឆ្នាំ១៩៧២ ម៉ន និងសារ៉ាត បានបញ្ជូនសមាជិកក្រុមរបស់ខ្ញុំមួយចំនួនឲ្យចូលបម្រើជាយោធាដើម្បីប្រយុទ្ធជាមួយទាហាន លន់ នល់។ ចំណែកខ្ញុំ ត្រូវបានផ្លាស់ប្តូរឲ្យទៅគ្រប់គ្រងកងយុវនារីភូមិជំនួសវិញ។ ខ្ញុំមានតួនាទីជាអនុប្រធានកងនារី មានភារកិច្ចគ្រប់គ្រង និងមើលការខុសត្រូវនារីៗនៅក្នុងភូមិកែវស្នា ការការពារសន្តិសុខរបស់ប្រជាជននៅក្នុងភូមិ និងជ្រើសរើសនារីៗឲ្យចូលបម្រើជាយោធា។ ក្នុងពេលដែលខ្ញុំធ្វើជាអនុប្រធានកងនារីភូមិ ខ្ញុំនិងមិត្តនារីពីរនាក់ទៀត ត្រូវថ្នាក់លើចាត់តាំងឲ្យចូលរៀនវិជ្ជាពេទ្យ ដើម្បីចូលបម្រើការជាកម្មាភិបាលពេទ្យនៅមន្ទីរពេទ្យភូមិស្វាយដោរ ឃុំព្រៃឃ្នេស។ ខ្ញុំរៀនពេទ្យអស់រយៈពេលបីខែ ជាមួយគ្រូពេទ្យជំនាញនៅក្នុងឃុំព្រៃឃ្នេស។ នៅខែដំបូង ខ្ញុំរៀនផ្សំថ្នាំ រៀនចំណាំឈ្មោះថ្នាំ និងរៀនចាក់ថ្នាំលើខ្មើយ។ នៅខែទីពីរនិងទីបី ខ្ញុំចេញទៅព្យាបាល និងចាក់ថ្នាំឲ្យប្រជាជននៅក្នុងឃុំជាមួយគ្រូពេទ្យជំនាញប្រចាំឃុំព្រៃឃ្នេស។ ខ្ញុំសប្បាយចិត្តក្នុងការធ្វើការងារនេះ ខ្លាំងណាស់ ព្រោះខ្ញុំគិតថា ខ្ញុំធ្វើឲ្យប្រទេសជាតិមានសុខសន្តិភាព និងប្រជាជនមានសុខភាពល្អ។

នៅឆ្នាំ១៩៧៣រហូតដល់ថ្ងៃជ័យជម្នះ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំចូលបម្រើការជាកម្មាភិបាលពេទ្យប្រចាំព្រៃឃ្នេសពេញលេញ។ តួនាទីរបស់ខ្ញុំគឺព្យាបាលប្រជាជនក្នុងឃុំ។ មុនដំបូង ការព្យាបាលគឺប្រើប្រាស់ថ្នាំពេទ្យដែលបានមកពីការរៃអង្គាសលុយពីអ្នកភូមិយកទៅទិញថ្នាំពីស្រុកមេសាង។ បន្ទាប់មក ការព្យាបាលគឺប្រើប្រាស់ថ្នាំបុរាណ ថ្នាំឫសឈើជំនួសវិញ។

បន្ទាប់ពីថ្ងៃ១៧ មេសា ១៩៧៥មក ខ្ញុំនៅតែធ្វើជាកម្មាភិបាលពេទ្យប្រចាំការនៅក្នុងឃុំព្រៃឃ្នេសដដែល។ ការហូបចុកនៅពេលនោះ គឺខ្វះខាតខ្លាំងណាស់។ របបអាហារតិចទៅៗ។ ម្នាក់ៗទទួលបានអង្ករតែពីរខាំកន្ទះប៉ុណ្ណោះក្នុងមួយថ្ងៃ។ ប្រជាជនចាប់ផ្តើមខ្វះខាតស្បៀងអាហារក្នុងការហូបចុក ហើយក៏មានជំងឺរាតត្បាតច្រើនទៀត ដូចជាជំងឺគ្រុនចាញ់ រាគមូល និងក្តៅខ្លួនជាដើម។ ខ្ញុំនៅព្យាបាលជំងឺអ្នកទាំងនោះគ្មានពេលទំនេរឡើយ។

នៅឆ្នាំ១៩៧៧ ខ្ញុំសុំប្រធានសហករណ៍ចុះទៅធ្វើការនៅតាមការដ្ឋានវិញម្តង ព្រោះខ្ញុំគិតថាខ្ញុំអាចស្គាល់កន្លែងផ្សេងៗ និងអាចទទួលបានរបបអាហារគ្រាន់បើជាងនៅក្នុងសហករណ៍។ អង្គការបានយល់ព្រម និងបានបញ្ជូនខ្ញុំទៅកាន់មូលដ្ឋានកោះទៃ ក្នុងតួនាទីជាអ្នកព្យាបាលជំងឺឲ្យក្រុមកងចល័តដែលបំពេញភារកិច្ចលើកសណ្តូរទឹក (ទំនប់ទឹក) និងមើលការខុសត្រូវពីសុខភាពកងចល័តនារីៗ។ ក្រោយមក អង្គការបញ្ជូនខ្ញុំឲ្យទៅធ្វើការនៅក្នុងមូលដ្ឋានស្រែជម្រៅបន្តទៀត ក្នុងតួនាទីដដែល។ នៅស្រែជម្រៅ ខ្ញុំត្រូវរបួសក្បាលដោយគ្រាប់កាំភ្លើងរបស់កងទ័ពវៀតណាម។ ខ្ញុំដឹងរឿងរ៉ាវជាច្រើនទាក់ទងនឹងការប្រយុទ្ធគ្នា និងផែនការគប់គ្រាប់បែកសម្លាប់កងចល័តក្នុងពេលបំពេញការងារនៅកន្លែងលើកទំនប់ទឹកនៅស្រែជម្រៅ។ ផែនការនេះ បានបែកការណ៍ ហើយពុំមាននរណាម្នាក់ចូលក្នុងការដ្ឋានលើកសណ្តូរនេះទៀតទេ។

ដោយសារខ្ញុំត្រូវរបួស អង្គការបានបញ្ជូនខ្ញុំឲ្យមកព្យាបាលខ្លួននៅក្នុងភូមិវិញនៅឆ្នាំ១៩៧៨។ ពេលមកដល់សហករណ៍ ខ្ញុំឃើញយោធាខ្មែរក្រហមមកពីភូមិភាគនិរតី កំពុងបញ្ជូនឲ្យប្រជាជនជីករណ្ដៅជាច្រើននៅភូមិកែវស្នា ដោយមិនប្រាប់ពីមូលហេតុនៃការជីកឡើយ។ ខ្ញុំបានឮដំណឹងមិនច្បាស់ការថា ការជីករណ្ដៅទាំងនេះគឺសម្រាប់ត្រៀមទុកសម្លាប់ប្រជាជន។ គ្រាន់តែឮដំណឹងនេះ ខ្ញុំនិងមិត្តនារីពេទ្យផ្សេងទៀតបានត្រៀមថ្នាំទុកសម្រាប់សម្លាប់ខ្លួនឯងរួចជាស្រេច ប៉ុន្តែក្រោយមក យើងមិនបានលេបថ្នាំសម្លាប់ខ្លួនឡើយ។

នៅដើមខែមករា ឆ្នាំ១៩៧៩ ខ្ញុំធ្វើដំណើរចេញពីភូមិទាំងជើងទទេ ព្រោះវៀតណាមជិតចូលមកដល់ឃុំព្រៃឃ្នេស។ ខ្ញុំធ្វើដំណើរទៅដល់ឃុំបាបោងរៀបនឹងធ្វើក្បូនឆ្លងទឹកទៅបន្តទៀត ក៏ត្រូវកងទ័ពវៀតណាមតាមទាន់ ហើយកងទ័ពវៀតណាមទាំងនោះបានប្រាប់ខ្ញុំឲ្យវិលត្រឡប់មកភូមិកំណើតវិញ។

បន្ទាប់ពីខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំក៏បានចូលធ្វើការស្ម័គ្រចិត្តនៅក្នុងឃុំព្រៃឃ្នេសបន្តទៀត គឺនៅក្នុងក្រុមទ្រទ្រង់សុខភាព ដើម្បីណែនាំប្រជាជនឲ្យមកព្យាបាលជំងឺនៅមណ្ឌលសុខភាព រួមទាំងការឆ្លងទន្លេ។ ក្នុងឆ្នាំ១៩៨២ ខ្ញុំរៀបការជាមួយបុរសម្នាក់នៅក្នុងភូមិ និងបានរស់នៅជាមួយគ្នារហូតមានកូន៥នាក់។ ប៉ុន្តែ ឥឡូវកូនរបស់ខ្ញុំស្លាប់អស់៣នាក់ហើយ។ ជាចុងក្រោយ ខ្ញុំមានការសោកស្ដាយខ្លាំងណាស់ដែលបានចូលបម្រើការងារឲ្យខ្មែរក្រហម ព្រោះខ្ញុំចង់ឲ្យប្រទេសមានសន្តិភាព និងយុត្តិធម៌ ប៉ុន្តែអង្គការធ្វើឲ្យប្រទេសធ្លាក់ក្នុងសង្គ្រាម និងកាប់សម្លាប់ជីវិតមនុស្សអស់ជាច្រើននាក់»។



ទេសភាពវាលស្រែ ស្ថិតនៅឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។
( ផេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា )

# ជនរងគ្រោះបាត់ប្តីនៅថ្ងៃជម្លៀស ខែមេសា ឆ្នាំ១៩៧៥

*មីន សាណាស់*



កែវ សោភ័ណ្ឌ អាយុ៧១ឆ្នាំ រស់នៅភូមិព្រៃជ្រៃ ឃុំព្រៃជ្រៃ ស្រុកពាមរក៍ ខេត្តព្រៃវែង។
(មីន សាណាស់/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ កែវ សោភ័ណ្ឌ អាយុ៧១ឆ្នាំ មានស្រុកកំណើតនៅភូមិព្រៃជ្រៃ ឃុំព្រៃជ្រៃ ស្រុកពាមរក៍ ខេត្តព្រៃវែង។ កាលពីសម័យសង្គមរាស្ត្រនិយម ខ្ញុំគឺជាសិស្ស និងរៀនបានត្រឹមថ្នាក់ទី៣ចាស់ នៅវិទ្យាល័យអង្គឌួង។ ក្រោយមក ខ្ញុំបានផ្លាស់មករៀនបន្តនៅទីក្រុងភ្នំពេញ។ នៅមុនពេលព្រឹត្តិការណ៍ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែង នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយបុរសម្នាក់ឈ្មោះ ជា ជនមានមុខរបរជាគ្រូបង្រៀននៅវិទ្យាល័យកៀនឃ្លាំង ក្នុងសង្កាត់ជ្រោយចង្វារ ក្រុងភ្នំពេញ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលខ្មែរក្រហមទទួលបានជ័យជម្នះលើរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់ ខ្ញុំទើបតែឆ្លងទន្លេកូនប្រុសបានរយៈពេលប្រហែលពីរខែតែប៉ុណ្ណោះ។ ខ្ញុំបានមកស្នាក់នៅផ្ទះបងថ្លៃរបស់ខ្ញុំនៅម្តុំទួលគោក។ ខ្ញុំព្រមទាំងសាច់ញាតិនិងក្មួយៗត្រូវយោធាខ្មែរក្រហមបង្ខំឲ្យចាកចេញពីផ្ទះ។ នៅពេលខ្ញុំដើរចេញមកខាងក្រៅ ខ្ញុំឃើញប្រជាជនដើរពេញដងផ្លូវ ដោយខ្លះ លី សែង និងដឹកអីវ៉ាន់ៗ ខ្ញុំនិងបងប្អូនដើរសំដៅទៅផ្ទះរបស់ខ្ញុំម្នាក់ទៀតនៅម្តុំបឹងត្របែក ព្រោះប្តីរបស់ខ្ញុំនៅចាំផ្ទះបងរបស់ខ្ញុំនៅ ទីនោះ។

នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមដេញឲ្យចាកចេញពីផ្ទះនៅបឹងត្របែក ក្នុងទីក្រុងភ្នំពេញឆ្ពោះទៅស្រុកកំណើតជាបន្ទាន់។ ខ្ញុំនិងស្វាមីបីកូនអាយុទើបពីរខែធ្វើដំណើរថ្មើរជើងកាត់តាមពីមុខវិទ្យាល័យបឹងត្របែក ដោយគ្មានបានរៀបចំរបស់របរអ្វីទាំងអស់ ក្នុងគោលបំណងឆ្លងទៅផ្លូវជាតិលេខមួយ។ ខណៈនោះ យោធាខ្មែរក្រហមដែលឈរយាមនៅក្បាលស្ពានព្រះមុនីវង្សត្រើយខាងលិចបានឃាត់ក្រុមគ្រួសាររបស់ខ្ញុំនិងបញ្ជូនឲ្យគ្រួសាររបស់ខ្ញុំដើរវាងទៅកាន់ផ្លូវចាក់អង្រែឆ្ពោះ

ទៅកាន់ទីក្រុងតាខ្មៅវិញ។ នៅតាមផ្លូវខ្ញុំឮសម្រែកយោធាខ្មែរក្រហមបញ្ជាប្រជាជនឲ្យដើរទៅមុខឲ្យលឿន។ ខ្ញុំនិងប្តីរបស់ខ្ញុំត្រូវបានយោធាខ្មែរក្រហមឃាត់និងសួរនាំនៅតាមផ្លូវ។ បន្ទាប់ពីសួរនាំរួចហើយ មានយោធាខ្មែរក្រហមម្នាក់បញ្ជាឲ្យខ្ញុំដើរពីខាងមុខប្តីរបស់ខ្ញុំ ចំណែកប្តីរបស់ខ្ញុំដើរតាមក្រោយ ព្រោះមានកងយោធាខ្មែរក្រហមជាច្រើនឈរយាមនៅអមសងខាងផ្លូវ។ ខ្ញុំបានសុំយោធាខ្មែរក្រហមដើរទន្ទឹមគ្នាជាមួយប្តីរបស់របស់ខ្ញុំ ប៉ុន្តែយោធាខ្មែរក្រហមនោះមិនអនុញ្ញាត។ ខ្ញុំដើរបណ្តើរ ងាកមើលប្តីរបស់ខ្ញុំដើរពីក្រោយបណ្តើរ។ ស្រាប់តែមួយរំពេចក្រោយមក ខ្ញុំងាកទៅក្រោយម្តងទៀតស្រាប់តែវង្វេងបាត់ប្តី។ នេះជាពេលវេលាចុងក្រោយដែលខ្ញុំបានបែកពីប្តី។ ខ្ញុំខំប្រឹងបីកូនអាយុពីរខែដើរទៅមុខទៀត និងខំប្រឹងទប់ទឹកភ្នែក ព្រោះភ័យខ្លាចសម្រែកយោធាខ្មែរក្រហម។

បន្ទាប់ពីធ្វើដំណើរដោយថ្មើរក្រោមកម្តៅថ្ងៃ និងភ្លៀងផ្គរ អស់រយៈពេលជាងដប់ថ្ងៃខ្ញុំបានមកដល់ភូមិព្រៃជ្រៃ ឃុំព្រៃជ្រៃ ស្រុកពាមរក៍ ខេត្តព្រៃវែង។ ពេលមកដល់ភូមិភ្លាម ប្រធានសហករណ៍បានហៅខ្ញុំទៅសួរនាំថា តើកាលរស់នៅភ្នំពេញ ប្តីរបស់មិត្តនារីមានតួនាទីអ្វី? តើប្តីរបស់មិត្តធ្លាប់ធ្វើជាកងកុម្មង់ដូរដែរឬទេ? ប្រធានសហករណ៍សួរនាំខ្ញុំមិនមែនមួយដងទេ ព្រមទាំងលួចឆែកឆេររបស់របរនៅលើផ្ទះរបស់ខ្ញុំថែមទៀតផង។ រាល់ចម្លើយដែលខ្ញុំឆ្លើយប្រាប់ប្រធានសហករណ៍នោះ គឺខ្ញុំមិនលាក់លៀមទេ។ ខ្ញុំបានឆ្លើយថា ប្តីរបស់ខ្ញុំគឺជាគ្រូបង្រៀន ហើយខ្ញុំគឺជាមេផ្ទះ។ ក្រោយពីសួរនាំអស់ចិត្តហើយ ប្រធានសហករណ៍បានឲ្យខ្ញុំយកកូនទៅឲ្យចាស់ៗមើលថែ។ ចំណែកខ្ញុំត្រូវចុះទៅស្ទូងស្រូវ និងធ្វើស្រែជូនអង្គការ ព្រមទាំងធ្វើការងារកសិកម្មផ្សេងៗទៀតនៅក្នុងសហករណ៍ស្រុកពាមរក៍។ ប្រធានកងមិនបានគិតថាខ្ញុំមានកូនខ្ចីឡើយ។ ពេលកូនរបស់ខ្ញុំមានអាយុមួយឆ្នាំ អង្គការចាប់ផ្តើមចល័តខ្ញុំឲ្យទៅធ្វើការវែកដី លើកទំនប់ និងជីកប្រឡាយនៅតំបន់ផ្សេងៗ។ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅក្នុងកងស្រួចឲ្យកងទ័ពបដិវត្តន៍ដែរ។ ខ្ញុំខំធ្វើការជូនអង្គការអស់ពីកម្លាំងកាយចិត្ត ប៉ុន្តែពុំមានអាហារសម្រាប់បរិភោគគ្រប់គ្រាន់ឡើយ។

ក្រោយមក ប្រធានសហករណ៍មានផែនការបញ្ជូនប្រជាជនមួយចំនួនឲ្យទៅរស់នៅតំបន់ដីខ្លាញ់ ដោយបានកោះហៅខ្ញុំនិងក្រុមគ្រួសារឲ្យមកជួបជុំគ្នាទាំងយប់។ ប្រធានបទប្រជុំគឺ ប្រធានសហករណ៍ប្រកាសឈ្មោះអ្នកដែលមាននៅក្នុងបញ្ជីដែលសុទ្ធសឹងជាប្រជាជនថ្មីឲ្យត្រៀមរៀបចំខ្លួនផ្លាស់ប្តូរ ទៅរស់នៅតំបន់ដីខ្លាញ់ ដែលសម្បូររបស់ហូបចុក។ ខ្ញុំមិនអាចប្រកែកបានទេ។ ខ្ញុំបានរៀបចំខោអាវ និងត្រៀមម្ហូបខ្លះទុកឲ្យកូនហូបនៅតាមផ្លូវ។ នៅព្រឹកចេញដំណើរ ស្រាប់តែប្រជាជនក្នុងភូមិជាមួយគ្នាមកប្រាប់ខ្ញុំថាអង្គការលែងឲ្យចាកចេញហើយ។ ខ្ញុំឮបែបនេះលួចត្រេកអរក្នុងចិត្ត និងគិតថាខ្លួនខ្ញុំនិងកូនអាចមានជីវិតរស់រានតទៅមុខទៀតជាមិនខាន។ មិនយូរប៉ុន្មានកងទ័ពវៀតណាមក៏ចូលមកដល់។

ក្រោយថ្ងៃរំដោះ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រទេសជាតិបានសុខសន្តិភាព។ ខ្ញុំក៏ចូលធ្វើជាគ្រូបង្រៀននៅវិទ្យាល័យអង្គឌួងផ្នែកគណិតវិទ្យា។ នៅពេលបង្រៀន ខ្ញុំតែងតែឆ្លៀតឱកាសបញ្ជ្រាបសិស្សពីប្រវត្តិសាច់រឿងរបស់ខ្ញុំដែលបានឆ្លងកាត់របបខ្មែរក្រហម និងការព្រាត់ប្រាស់គ្រួសារ។ សព្វថ្ងៃរស់នៅ ខ្ញុំរស់នៅក្នុងភូមិទី៨ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ជាមួយកូនប្រុសម្នាក់ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម។

# រឿងរ៉ាវរបស់អ្នករស់រានមានជីវិត

## ពីរបបខ្មែរក្រហមនៅឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង

*ថុន ស្រីពេជ្រ*

### *១) កយ កន ៖ កងចល័ត*



*កយ កន អាយុ៧៨ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅ ភូមិបារាច ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

កយ កន មានអាយុ៧៨ឆ្នាំគឺជាអ្នករស់រានមានជីវិតម្នាក់ពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ កន បានចែករំលែកនូវបទពិសោធន៍របស់ខ្លួន ដែលបានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ប្រាប់មកកាន់បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅក្នុងរបបខ្មែរក្រហម កន បានលើកឡើងថា មានរឿងរ៉ាវមួយចំនួនដែលខ្លួននៅតែចងចាំមិនភ្លេចនៅក្នុងរបបខ្មែរក្រហមនោះ គឺ ទុក្ខលំបាករបស់ប្រជាជន ការជម្លៀសគាត់និងប្រជាជនទៅកាន់ខេត្តពោធិ៍សាត់ ការសម្លាប់មនុស្ស ការវាយធ្វើបាប ការធ្វើការងារជាទម្ងន់ និងការហូបចុកពុំគ្រប់គ្រាន់ជាដើម។ «កាលនៅជាកុមារភាព ក្នុងអាយុ៧ឆ្នាំ ខ្ញុំបានចូលរៀននៅវត្តបារាច ដែលមានព្រះសង្ឃជាអ្នកបង្រៀន អំពីចំណេះដឹងទូទៅ ផ្នែកជីវសាស្ត្រ និងសង្គមសាស្ត្រ។ ខ្ញុំរៀនត្រឹមថ្នាក់ទី១០ នៅក្នុងសម័យសង្គមរាស្ត្រនិយម។ បន្ទាប់ពីឈប់រៀន ខ្ញុំបានបួសជាព្រះសង្ឃនៅវត្តបារាច អស់រយៈពេល៦វស្សា ហើយក៏បានសឹកវិញនៅឆ្នាំ១៩៦៨។ ខ្ញុំមានបងប្អូនចំនួន៤នាក់ ស្រី១នាក់ និងប្រុស៣នាក់។ ខ្ញុំគឺជាកូនច្បងនៅក្នុងគ្រួសារ។ ខ្ញុំរៀបការជាមួយប្រពន្ធរបស់ខ្ញុំនៅឆ្នាំ១៩៧០។

ក្រោយរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ នៅឆ្នាំ១៩៧០ នៅក្នុងភូមិដែលខ្ញុំកំពុងរស់នៅក៏ចាប់ផ្តើមមានភាពច្របូកច្របល់។ មានការទម្លាក់គ្រាប់បែកជាច្រើនលើកច្រើនសារ បានធ្វើឲ្យប្រជាពលរដ្ឋមានការលំបាកយ៉ាងខ្លាំង ជាពិសេសធ្វើឲ្យខ្ញុំរត់ចូលក្នុងលេណដ្ឋាន ហើយត្រូវរត់ចាកចេញពីផ្ទះ ឆ្ពោះទៅទីវាល ដើម្បីរកកន្លែងសុវត្ថិភាព និងស្នាក់អាស្រ័យបណ្តោះអាសន្នទៀត។ ការទម្លាក់គ្រាប់បែក បានស្ងាត់នៅឆ្នាំ១៩៧៣។

នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានទទួលជ័យជម្នះទាំងស្រុងទៅលើ របប លន់ នល់។ ក្នុងគ្រានោះដែរ ខ្មែរក្រហមបានរៀបចំឲ្យប្រជាជនទាំងអស់ ធ្វើការងាររួមគ្នា។ នៅរដូវប្រាំងខ្មែរក្រហមបានប្រើឲ្យ ខ្ញុំជីកប្រឡាយ លើកប្រព័ន្ធភ្លឺស្រែនៅស្រុកមេសាង។ រីឯរដូវវស្សាវិញខ្មែរក្រហមបានចាត់ឲ្យខ្ញុំភ្ជួររាស់ដីនៅក្នុងភូមិ។ ចំណែកឯការហូបចុករបស់ខ្ញុំវិញ គឺហូបតែបបរប៉ុណ្ណោះ ចាប់តាំងពីឆ្នាំ១៩៧៧ មករហូតដល់ខ្មែរក្រហមបរាជ័យ។

នៅខែធ្នូ ឆ្នាំ១៩៧៨ ខ្ញុំនិងគ្រួសារត្រូវបានខ្មែរក្រហមជម្លៀសទៅកាន់ ខេត្តពោធិ៍សាត់ជាមួយនឹងគ្រួសារដទៃជាច្រើនទៀត។ ខ្ញុំបានដឹង ថាការដែលខ្លួនត្រូវបានអង្គការបញ្ជូនទៅបែបនេះ គឺមិនល្អទេ

និងមានបំណងចង់រត់ជាច្រើនលើកច្រើនសារ។ មានថ្ងៃមួយពេលមកដល់ភូមិគ្រួស ខ្ញុំសម្រេចចិត្តថានឹងរត់ម្តងទៀត ប៉ុន្តែជាអកុសល ខ្ញុំត្រូវបានកម្មាភិបាលខ្មែរក្រហមចាប់ខ្លួននៅពេលនោះ។ «ខ្ញុំត្រូវបានកម្មាភិបាលខ្មែរក្រហម វាយធ្វើបាបយ៉ាងដំណំ ដោយវាយដងធាក់ដង និងយកកាំភ្លើងវាយក្បាលខ្ញុំទៀត ធ្វើឲ្យខ្ញុំឈឺចាប់យ៉ាងខ្លាំង និងបាត់បង់ស្មារតីមួយរំពេច» ។ លុះព្រឹកឡើង ខ្ញុំនិងអ្នកឯទៀតត្រូវជម្លៀសទៅមុខបន្តទៀត។ ដំណើរឆ្ពោះទៅកាន់ពោធិ៍សាត់ ខ្ញុំបានជិះកប៉ាល់ឡើងទៅច្បារអំពៅ រួចឡើងជិះរថភ្លើងបន្ត។ រថភ្លើងបានឈប់នៅម្តុំ អូបត់។ កន បានចាប់ផ្តើមធ្វើការនៅទីនោះតាមការបញ្ជារបស់ខ្មែរក្រហម។ ខ្ញុំត្រូវមើលគោក្របីចំនួន ១០០ ក្បាល រែកទឹកដាក់ពាង កាប់ខស និងភ្ជួរស្រែ។ ខ្ញុំបានសម្រាកតិចតួចណាស់។ រីឯការហូបចុកវិញ ក៏យ៉ាប់ណាស់ដែរ ដោយរៀងរាល់ថ្ងៃគឺហូបតែបបរក្នុងរយៈពេលជម្លៀសទៅតំបន់ពោធិ៍សាត់នោះ។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ បើទោះបីជានៅទីក្រុងភ្នំពេញ បែកហើយក៏ដោយ ខ្ញុំមិនអាចវិលត្រឡប់មកភូមិកំណើតវិញដែរ។ រយៈពេល៦ខែបន្ទាប់ពីបែក ខ្មែរក្រហម បានបង្ខាំងប្រជាជនមិនឲ្យរត់ចេញទៅណាឡើយ ពោលគឺខ្មែរក្រហមបានបង្ខំឲ្យប្រជាជននៅធ្វើការឲ្យខ្លួន និងយកទៅសម្លាប់ម្តងមួយៗ រហូតដល់ច្រើន តួយ៉ាងដូចជាមានថ្ងៃមួយនៅវេលាប្រហែលម៉ោង៥កន្លះល្ងាច ខណៈពេលដែល ខ្ញុំកំពុងបេះកំប្លោកឲ្យរោងបាយ ខ្ញុំបានឃើញយោធាខ្មែរក្រហមចំនួន ៣នាក់ បានបណ្តើរមនុស្សចំនួនចំនួន ៧ នាក់ យកទៅបាញ់សម្លាប់ចោលនៅត្រពាំងដងទឹក។ ខ្ញុំភ័យខ្លាំងណាស់ និងចេះតែនឹកគិតក្នុងចិត្ត ខ្លាចតែខ្លួនមានលទ្ធផលដូចជាពួកគេ។

នៅខែមិថុនា ឆ្នាំ១៩៧៩ ខ្មែរក្រហមបានកៀរប្រជាជនឲ្យឡើងទៅលើភ្នំ (មិនស្គាល់ភ្នំ) ដើម្បីយកទៅសម្លាប់ ប៉ុន្តែក៏ត្រូវបានប្រាប់ឲ្យត្រឡប់មកវិញដោយបុរសជិះសេះម្នាក់មិនស្គាល់អត្តសញ្ញាណ។ ខ្ញុំសប្បាយចិត្តខ្លាំងណាស់ នៅពេលដែលដឹងថាមានអ្នកមករំដោះខ្ញុំ និងប្រជាជនទាំងមូលឲ្យរួចផុតពីកណ្តាប់ដៃខ្មែរក្រហម។ ខ្ញុំនិងគ្រួសារបានដើរត្រឡប់មកផ្ទះវិញ។ នៅតាមផ្លូវ មានមនុស្សស្លាប់ច្រើនណាស់ ដោយអ្នកខ្លះស្លាប់ ហើមស្អុយពេញវាល។ ខ្ញុំបានមកដល់ផ្ទះវិញដោយថ្មើរជើង ក្នុងរយៈពេលមួយខែ។ មកដល់ភូមិ ខ្ញុំឃើញប្រជាជនថាមានសិទ្ធិសេរីភាពឡើងវិញ ហើយនៅក្នុងភូមិក៏មានការរៀបចំរចនាសម្ព័ន្ធភូមិឃុំរួចជាស្រេចហើយដែរ។ នៅឆ្នាំ២០០៦ ខ្ញុំត្រូវបានប្រជាជនជ្រើសតាំងឲ្យធ្វើជាមេភូមិ បារាច រហូតមកដល់បច្ចុប្បន្ន» ។

## ២) គិត វ៉ន៖ យុវនារីកម្លាំងស្រួច



គិត វ៉ន អាយុ៦៦ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិបារាច ឃុំព្រៃឃ្នេស ស្រុកមេសាងខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឈ្មោះរបស់ខ្ញុំគឺ គិត វ៉ន។ ខ្ញុំមានអាយុ ៦៦ឆ្នាំ។ បច្ចុប្បន្នខ្ញុំរស់នៅ ភូមិឫស្សីស្បាត ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំ មានបងប្អូនចំនួន ៥នាក់។ បងប្អូនប្រុស ២នាក់របស់ខ្ញុំត្រូវបានខ្មែរក្រហមយកទៅសម្លាប់ដោយសារមិនព្រមចូលធ្វើយោធា។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំគឺជាយុវនារីកម្លាំងស្រួច ខ្ញុំត្រូវធ្វើការងារធ្ងន់ៗជាច្រើន ព្រមទាំងត្រូវចាកឆ្ងាយពីផ្ទះ ដើម្បីចល័តទៅធ្វើការនៅតំបន់ផ្សេងៗទៀត នៅក្នុងឃុំព្រៃឃ្នេស។ ខ្ញុំត្រូវបានខ្មែរក្រហមប្រើឲ្យធ្វើការ ទាំងថ្ងៃទាំងយប់។ រាល់កិច្ចការងារដែលខ្មែរក្រហម បានប្រើខ្ញុំ ខ្ញុំមិនដែល

ហ៊ានប្រកែកទេ ខ្ញុំតែងតែព្យាយាម និងខិតខំធ្វើយ៉ាងណាឲ្យការងាររួចរាល់តាមការកំណត់របស់ខ្មែរក្រហម ព្រោះតែមិនចង់ឲ្យខ្មែរក្រហមយកទៅរៀនសូត្រៗ កាលនៅពីតូចខ្ញុំបានចូលរៀនសូត្រនៅសាលាវត្តបារាច ហើយបានឈប់រៀនត្រឹមថ្នាក់ទី១០ នៅចុងឆ្នាំ១៩៦៩។ មូលហេតុនៃការឈប់រៀនរបស់ខ្ញុំ គឺដោយសារតែស្រុកទេសចាប់ផ្ដើមកើតមានសង្គ្រាមរវាង លន់ នល់ និងកងកម្លាំងខ្មែររំដោះ។ សង្គ្រាមនេះបានបង្កឲ្យមានការភ័យខ្លាចដល់ប្រជាជនត្រូវរត់ចេញពីភូមិ ទៅតំបន់សុវត្ថិភាពផ្សេងៗ ហើយជាពិសេសធ្វើឲ្យមនុស្សស្លាប់ និងរងរបួស ព្រមទាំងបន្សល់ទុកនូវរណ្ដៅដីធំៗពីការទម្លាក់គ្រាប់បែក។

ចាប់តាំងពីឆ្នាំ១៩៧៣មក ការទម្លាក់គ្រាប់បែកលែងមានតទៅទៀត។ នៅក្នុងភូមិត្រូវបានគ្រប់គ្រងដោយកងកម្លាំងខ្មែររំដោះ ហើយជាពេលដែលខ្មែរក្រហមបានបែងចែកការងារឲ្យប្រជាជននៅក្នុងភូមិធ្វើការងារជាបណ្ដើរៗដែរ។ ការងារដំបូងដែលខ្មែរក្រហមបានប្រើខ្ញុំនោះ គឺការដើរល្បាតពេញភូមិដើម្បីការពារភូមិពីសត្រូវឈ្លានពាន។ ខ្ញុំធ្វើកិច្ចការនេះរហូតដល់ឆ្នាំ១៩៧៥ ទើបឈប់ធ្វើ។ មានថ្ងៃមួយខណៈពេលដែលខ្ញុំកំពុងយាមល្បាតនៅពេលយប់ ខ្ញុំឃើញខ្មែរក្រហមវាយសម្លាប់មនុស្សទម្លាក់ចូលទៅក្នុងត្រពាំងដងទឹកជាច្រើននាក់ដែលសុទ្ធតែជាអ្នកជម្លៀសមកពីទីក្រុងភ្នំពេញដែលត្រូវបានខ្មែរក្រហមស្រាវជ្រាវដឹងថា អ្នកទាំងអស់នោះមានចំណេះដឹងខ្ពង់ខ្ពស់។ ខ្ញុំភ័យណាស់។ បើទោះជាដឹងថាខ្មែរក្រហមបានយកមនុស្សទៅវាយសម្លាប់អស់ជាច្រើននាក់ក៏ខ្ញុំមិនហ៊ានមាត់ដែរ។ ខ្ញុំតែងតែធ្វើមិនដឹងមិនឮនូវរឿងទាំងអស់នេះ។

នៅឆ្នាំ១៩៧៥ដដែល ក្នុងពេលដែលខ្មែរក្រហមដណ្ដើមអំណាចពី សេនាប្រមុខ លន់ នល់ បានទាំងស្រុង ខ្មែរក្រហមប្រើឲ្យប្រជាជនធ្វើស្រែរួមគ្នា។ នារដូវប្រាំង ខ្ញុំត្រូវចល័តទៅតំបន់ឆ្ងាយៗដើម្បី ជីកប្រឡាយ និងលើកប្រព័ន្ធភ្លឺស្រែ។ រីឯរដូវវស្សាវិញ ខ្ញុំត្រូវបានចាត់ចែងឲ្យស្ទូង។ ក្នុងខែស្រូវទុំខ្ញុំក៏ដឹកនាំក្រុមទៅប្រូតទៀត។ ចំណែកឯអាហារហូបចុកវិញ ពេលណាដែលធ្វើស្រែសល់ស្រូវច្រើនក៏បានបាយហូប ពេលណាដែលមិនមានស្រូវ គឺយើងហូបបបរ។ ក្នុងសម័យនោះខ្ញុំឆ្ងល់ណាស់ ស្រូវនាសម័យនោះប្រជាជនខិតខំប្រឹងប្រែងធ្វើណាស់ ហើយស្រូវក៏ទទួលបានផលច្រើនដែរ តើហេតុអ្វីបានជាមិនឲ្យប្រជាជនហូបឲ្យបានឆ្អែតគ្រប់គ្នាដើម្បីមានកម្លាំងធ្វើការបន្ត? ខ្ញុំចេះតែឆ្ងល់ ហើយក៏ជាចម្ងល់រហូតមកដល់សព្វថ្ងៃនេះ។ ខ្ញុំធ្វើការបែបនេះ និងហូបចុកបែបនេះដដែលៗរហូតដល់ឆ្នាំ១៩៧៩។

នៅចុងឆ្នាំ១៩៧៨ ប្រធានសហករណ៍នៅក្នុងភូមិបានជម្លៀសប្រជាជនទាំងអស់ចេញពីភូមិ ក្នុងបំណងគេចពីកងកម្លាំងវៀតណាម។ ប្រធានសហករណ៍បានកៀរប្រជាជនពីកងធំរហូតទៅដល់ស្នេហ៍ ក៏ត្រូវបានត្រឡប់មកវិញ ដោយដឹងថានៅអ្នកលឿងមានការផ្ទុះអាវុធយ៉ាងខ្លាំង ហើយប្រទេសក៏ត្រូវបានរំដោះដែរ។ ក្រោយឆ្នាំ១៩៧៩ ខ្ញុំចាប់ផ្ដើមរកស៊ីទិញដំឡូងមកលក់និងដូរយកអង្ករ។ សព្វថ្ងៃខ្ញុំជាកសិករធ្វើស្រែនៅក្នុងភូមិបុស្សស្បាត។

## ៣) ឆន ម៉ន ៖ យោធាខ្មែរក្រហម



ឆន ម៉ន អាយុ៦៧ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិបារាច ឃុំព្រៃឃ្នេស ស្រុកមេសាងខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឆន ម៉ន គឺជាអតីតកងកម្លាំងយោធា និងជាអ្នករស់រានមានជីវិតម្នាក់ពីរបបខ្មែរក្រហម។

ខ្ញុំមានអាយុ ៦៧ឆ្នាំ។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិសន្ទួងលៀប ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូនចំនួន៧ នាក់ ដោយក្នុងនោះមានស្រី១នាក់។ ខ្ញុំបានចូលរៀននៅអាយុ៧ឆ្នាំ នៅវត្តសន្ទួងលៀប ត្រឹមថ្នាក់ទី៩។ ដោយសារតែមានសង្គ្រាមកើតឡើង ខ្ញុំបានផ្អាកការសិក្សាមួយរយៈ។ ក្រោយមក ខ្ញុំបួសជាព្រះសង្ឃ ដើម្បីបានរៀនសូត្របន្ត។ មិនយូរប៉ុន្មាន ខ្ញុំក៏សឹក ហើយចូលមកបម្រើនៅក្នុងជួរកងទ័ព។ នៅក្នុងក្រុមគ២ ។ កាលចូលដំបូង ខ្ញុំបានទៅរៀនក្បួនយុទ្ធសាស្ត្រ ជារៀងរាល់ថ្ងៃ នៅសាលាហ្វឹកហ្វឺនភូមិភ្នាត ដោយក្នុងនោះរៀនអំពីរបៀបគេចពីគ្រាប់ ការលូន និងការក្រាបជាដើម។ ខ្ញុំបានរៀននៅទីនោះ ចំនួន១វគ្គ ក្នុងរយៈពេល១ខែ ក៏ផ្លាស់ទៅតំបន់២០ ដើម្បីប្រយុទ្ធជាមួយនឹងកងទ័ព លន់ នល់ និងកងកម្លាំង ទាហានធីវគី នៅឆ្នាំ១៩៧៣។ គ្រានោះខ្ញុំ និងទាហានដទៃទៀតបានជីករណ្ដៅលេណដ្ឋានដើម្បីលាក់ខ្លួនពីការទម្លាក់គ្រាប់ និងធ្វើក្បួនលបវាយប្រហារទៅខាងទាហាន លន់ នល់ នៅពេលយប់។ ការប្រយុទ្ធគ្នានេះ ធ្វើឲ្យមានអ្នកស្លាប់និងរងរបួសជាច្រើននាក់។

នៅឆ្នាំ១៩៧៥ មេបញ្ជាការកងកម្លាំងខ្មែរក្រហមបានបញ្ជូន ខ្ញុំនិងទាហានដទៃទៀតឡើងទៅវាយយកទីក្រុងភ្នំពេញ។ គ្រាប់ផ្លោងរបស់យោធាខ្មែរក្រហមបានផ្លោងពីច្បារអំពៅចូលទៅក្នុងទីក្រុងភ្នំពេញនៅវេលាម៉ោង៩ព្រឹក។ គ្រាប់ផ្លោងបានបាញ់ចូលទៅទីក្រុងភ្នំពេញឥតឈប់ឈរក្នុងរយៈពេល២ថ្ងៃ ធ្វើឲ្យទាហាន លន់ នល់ លើកទង់ជ័យស សុំចុះចាញ់។ នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ទាហានខ្មែរក្រហមបានចូលមកពេញទីក្រុង និងបានបង្ខំឲ្យប្រជាជនចាកចេញពីរដ្ឋធានី ក្នុងរយៈពេល៣ថ្ងៃ។ ខ្ញុំមិនបាននៅក្នុងព្រឹត្តិការណ៍ជម្លៀសប្រជាជនទេ។ ខ្ញុំត្រូវបានមេបញ្ជាការរបស់ខ្ញុំបញ្ជូនឲ្យទៅការពារនៅទន្លេអ្នកលឿង រួចត្រឡប់មកស្រុកកំណើតវិញ។ មកដល់ស្រុកកំណើត ខ្ញុំបានមកធ្វើស្រែជាមួយទាហានដទៃទៀតដូចប្រជាជនដែរ។

នៅខែកញ្ញា ឆ្នាំ១៩៧៨ ដោយសារតែ ខ្ញុំជាកម្មាភិបាលនៅភូមិភាគបូព៌ា ខ្ញុំត្រូវបានខ្មែរក្រហមចោទប្រកាន់ថាជាក្បាលយួនខ្លួនខ្មែរ។ ខ្មែរក្រហមបានជម្លៀស ខ្ញុំទៅកាន់ពោធិ៍សាត់ បាត់ដំបង ក្នុងគោលបំណងសម្លាប់ចោលនៅទីនោះ។ មុននឹងទៅដល់ពោធិ៍សាត់ ខ្ញុំត្រូវខ្មែរក្រហមប្រើឲ្យធ្វើការនៅព្រលានយន្តហោះជាមួយជនជាតិចិនរយៈពេលមួយខែនៅខេត្តកំពង់ឆ្នាំង។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៨ ខ្មែរក្រហមបានបញ្ជូនខ្ញុំបន្តទៅកាន់ខេត្តបាត់ដំបង ហើយជាពេលដែលខ្ញុំស្ទើរតែបាត់បង់ជីវិតទៅហើយនៅពេលនោះ។ នៅលើភ្នំធិបតី នៅវេលាម៉ោង៩ព្រឹក ខ្ញុំត្រូវបានខ្មែរក្រហមវាយសម្លាប់ ដោយការកាប់ក្បាលខ្ញុំចំនួន ៥ពូថៅ ចាក់កខ្ញុំចំនួន ៣ដង រួចប្រានខ្ញុំទម្លាក់ចូលទៅក្នុងរណ្ដៅសព។ ដោយសេចក្ដីឈឺចាប់ខ្លាំងពេក ខ្ញុំក៏បានសន្លប់បាត់ស្មារតី។ លុះព្រឹកឡើងនៅវេលាប្រហែលម៉ោង៩ ដដែល ខ្ញុំក៏បានដឹងខ្លួនវិញ។ នៅជុំវិញខ្លួនខ្ញុំគឺសុទ្ធជាសាកសពរាប់រយនាក់ដែលខ្មែរក្រហមបានសម្លាប់។ ក្នុងគ្រានោះ ខ្ញុំក៏បានឃើញអ្នកដែលខ្ញុំស្គាល់ ក៏ទៅអង្រួនអ្នកទាំងនោះ ក្រែងលោបានរស់ តែគួរឲ្យស្ដាយ ហើយអស់សង្ឃឹម មិនមាននរណាម្នាក់នៅរស់រានមានជីវិតម្នាក់ឡើយ។ ខ្ញុំខំប្រឹងងើបចេញពីរណ្ដៅយ៉ាងត្រដាបត្រដួស។ ជីវិតហាក់គ្មានកោះត្រើយ ដោយមិនដឹងទៅទីណាបន្តទៀត ខ្ញុំបានទៅសម្ងំលាក់ខ្លួននៅក្នុងព្រៃ។ ខ្ញុំអង្គុយនៅក្រោមដើមឈើដែលសម្បូរទៅដោយសត្វអង្ក្រង។ សត្វអង្ក្រងជាច្រើនបានមករោមខាំខ្ញុំដោយសារតែធំក្លិនឈាម។ នៅវេលាភ្លឺស្រាងៗ ខ្ញុំឮសំឡេងមាន់អ្នកស្រុករងាវ។ ខ្ញុំហាក់មានសង្ឃឹមឡើងវិញ។ ខ្ញុំព្យាយាមដើរតាមសំឡេងមាន់រងាវ រហូតបានជួបជាមួយកងកម្លាំងវៀតណាម។ កងទ័ពវៀតណាមបានជួយសង្គ្រោះ ខ្ញុំនិងយកខ្ញុំទៅព្យាបាលចំនួន៣ខែ។ ខ្ញុំបានរស់នៅជាមួយកងទ័ពវៀតណាម រហូតដល់ឆ្នាំ១៩៨២ ទើបត្រឡប់មកភូមិកំណើតវិញ។ នៅឆ្នាំ១៩៨២ ដដែល ខ្ញុំបានរៀបការជាមួយភរិយា

ហើយមានកូនចំនួន៦នាក់ ក្រោយមកស្លាប់អស់ ២នាក់ៗ សព្វថ្ងៃ ខ្ញុំគឺជាកសិករ។

## ៤) ប៉ាវ លាភ ៖ កងចល័តនារី



ប៉ាវ លាភ អាយុ៧៥ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅ ភូមិបារាច ឃុំព្រៃឃ្នេស ស្រុកមេសាងខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ប៉ាវ លាភ រស់នៅក្នុងផ្ទះប្រក់ស័ង្កសីតូចល្មមមួយនៅភូមិសន្ទូង ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូនចំនួន៥នាក់ ប្រុស២ ស្រី៣ ស្លាប់២នាក់ៗ ខ្ញុំគឺជាកងចល័តនារីម្នាក់នៅក្នុងរបបខ្មែរក្រហម។ ខ្ញុំចល័តគ្រប់តំបន់ដើម្បីធ្វើការងារកសិកម្មតាមការបញ្ជារបស់ខ្មែរក្រហម។ ខ្ញុំខិតខំប្រឹងប្រែងធ្វើការណាស់ ដើម្បីមានជីវិតរស់ បើទោះជាត្រូវងើបពីយប់ធ្វើការ ក៏ខ្ញុំមិនហ៊ានប្រកែកដែរ។ ខ្ញុំចូលរៀនអក្ខរកម្មដំបូងនៅអាយុ១៥ ឆ្នាំ។

នៅក្នុងរបប លន់ នល់ ចន្លោះឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧២ យន្តហោះទម្លាក់គ្រាប់បែកយ៉ាងខ្លាំងមកលើភូមិសន្ទូងដែលខ្ញុំបានរស់នៅ។ ខ្ញុំត្រូវជម្លៀសខ្លួនមួយរយៈទៅកាន់ភូមិស្លា និងស្នាក់នៅទីនោះបណ្តោះអាសន្ន ដើម្បីគេចពីការទម្លាក់គ្រាប់បែក។ ការទម្លាក់គ្រាប់បែកបានបញ្ឈប់នៅឆ្នាំ១៩៧៣។

មកដល់សម័យខ្មែរក្រហម ចាប់ពីឆ្នាំ១៩៧៥ ខ្មែរក្រហមបានឲ្យប្រជាជនទាំងអស់ធ្វើស្រែរួមគ្នា។ សម្រាប់ ខ្ញុំខ្មែរក្រហមបានចាត់តាំងឲ្យធ្វើជាកងចល័តនារី។ ការងារដំបូងដែលអង្គការឲ្យខ្ញុំធ្វើនោះគឺលើកប្រឡាយ នៅដោរ ទន្ស្រាយដលហ៊ិប និងស្មោង។ ក្រៅពីនោះ ពេលដល់រដូវប្រមូលផលស្រូវ ខ្ញុំចល័តទៅប្រមូលផលរហូតដល់ស្វាយរៀង។ ខ្ញុំបានធ្វើកិច្ចការទាំងនេះរហូតដល់បែក។ ចំណែកឯអាហារហូបចុករបស់ខ្ញុំ មិនដែលបានហូបឆ្អែតម្តងណាឡើយ។ ខ្ញុំតែងតែទទួលបានរបបបបរ ព្រឹកល្ងាច ជារៀងរាល់ថ្ងៃ។

នៅចុងឆ្នាំ១៩៧៨ នៅពេលដែលកងទ័ពវៀតណាមរៀបវាយចូលមក ខ្ញុំត្រូវបានជម្លៀសទៅភូមិជក្រោក។ ខ្ញុំទៅទីនោះចំនួនមួយយប់ ក៏ឮប្រជាជនស្រែកបន្តបន្ទាប់គ្នាថា ឲ្យត្រឡប់មកក្រោយវិញ។ ចាប់ពីពេលនោះមក ប្រជាជនលែងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមតទៅទៀតហើយ។ រឿងរ៉ាវមួយចំនួនដែល ដែលខ្ញុំនៅតែចងចាំមិនភ្លេចនៅក្នុងរបបខ្មែរក្រហម នោះគឺ អង្គការប្រើឲ្យខ្ញុំធ្វើការងារធ្ងន់ៗ ឲ្យអាហារហូបចុកពុំបានគ្រប់គ្រាន់ និងប្រជាជនគ្មានសិទ្ធិសេរីភាព ដូចជាពាក្យមួយដែលគេនិយាយថា គុក ឥតជញ្ជាំង។

## ៥) ប៊ី ណារី ៖ កងកុមារ

នាងខ្ញុំឈ្មោះ ប៊ី ណារី។ ខ្ញុំមាន អាយុ៥៨ ឆ្នាំហើយ។ ខ្ញុំបានជួបរឿងរ៉ាវជាច្រើនស្ទើរតែមិនអាចរៀបរាប់អស់។ ខ្ញុំបាត់បង់សមាជិកគ្រួសាររហូតដល់ទៅ៨ នាក់នៅក្នុងរបបខ្មែរក្រហម។ ឪពុករបស់ខ្ញុំជាមេភូមិម្នាក់ក្នុងជំនាន់សោ ភឹម។ ឪពុកខ្ញុំបានធ្វើអត្តឃាតខ្លួនឯង ដោយការចងកសម្លាប់ខ្លួន ដើម្បីកុំឲ្យអង្គការយកខ្លួនទៅសម្លាប់។ រីឯបងប្អូនប្រុសទាំង៧ នាក់ទៀតរបស់ខ្ញុំ ត្រូវខ្មែរក្រហមយកទៅសម្លាប់នៅខេត្តពោធិ៍សាត់។ ខ្ញុំនៅសល់តែបងប្អូនចំនួន៣នាក់ ដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម រហូតមកដល់សព្វថ្ងៃនេះ។ ខ្ញុំរៀននៅសាលាបឋមសិក្សា ព្រៃឃ្នេស។ ខ្ញុំចូលរៀននៅ អាយុ១៣ឆ្នាំ។ ខ្ញុំអាចអានបានតិចតួច។



ប៊ី ណារី អាយុ៥៨ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិបារាច ឃុំព្រៃឃ្នេស ស្រុកមេសាងខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សម្រាប់ម៉ោងសិក្សានៅក្នុងរបបខ្មែរក្រហម គឺខ្ញុំរៀនរយៈពេលមួយម៉ោង ជារៀងរាល់ថ្ងៃ ក្នុងនោះខ្ញុំរៀនអំពីស្រៈ ព្យញ្ជនៈ និងពាក្យប្រកបបញ្ចូលគ្នា។ នៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់ខ្ញុំ ក្រៅពីការរៀនសូត្រ ខ្ញុំត្រូវទៅស្តាបាតស្រះ កាប់ទន្ទ្រានខែត្រ ដើររើសលាមកគោមកធ្វើជីជូនកាលត្រូវទៅជីកប្រឡាយ និងលើកប្រព័ន្ធភ្លឺស្រែនៅមេសាង។ ខ្ញុំតែងតែធ្វើបែបនេះតាមការបញ្ជារបស់អង្គការ។

មានថ្ងៃមួយនៅចុងឆ្នាំ១៩៧៨ ប្រធានកងពលតូចឈ្មោះ គន់ ប៊ុន បានដើរផ្សព្វផ្សាយពេញភូមិឲ្យប្រជាជនជម្លៀសទៅខេត្តពោធិ៍សាត់ ដោយនិយាយថាឲ្យប្រជាជនទៅរស់នៅលើទឹកដីថ្មី ធ្វើការងារលើទឹកដីថ្មី ដូចជាការដាំដំឡូងជាដើម និងមានរបស់ហូបចុកហូរហៀរមិនខ្វះឡើយ។ គ្រួសាររបស់ខ្ញុំបានទៅខេត្តពោធិ៍សាត់ទាំងអស់គ្នា ដោយពុំបានដឹងថាម្នាក់ៗកំពុងតែចាញ់បោកនូវគោលនយោបាយរបស់អង្គការឡើយ។ ទៅដល់ពោធិ៍សាត់ខ្មែរក្រហមបានវាយសម្លាប់មនុស្សទាំងខ្សែៗរួមជាមួយបងប្អូនប្រុសរបស់ខ្ញុំដែរ។ ខ្ញុំធ្វើដំណើរទៅកាន់ខេត្តពោធិ៍សាត់ក្នុងរយៈពេលពាក់ថ្ងៃ ដោយដំបូងឡើយ ខ្ញុំ និងគ្រួសារបានដើរទៅដល់អ្នកលឿង ដើម្បីឡើងជិះកប៉ាល់ និងត្រូវជិះរថភ្លើងបន្តដើម្បីបានមកដល់ខេត្តពោធិ៍សាត់។ ខ្ញុំនិងគ្រួសារបានបែកគ្នានៅពេលនោះតែម្តង។ ខ្ញុំត្រូវបានអង្គការបញ្ជូនទៅព្រៃធំ ដើម្បីទៅលើកដី និងជីកប្រឡាយ។ សម្រាប់អាហារហូបចុក ខ្ញុំពុំដែលហូបឆ្អែតទេ។ ខ្ញុំបានលួចបេះស្លឹកឈើខ្លះៗ គ្រាន់ទុកសម្រាប់ហូបនៅពេលយប់ដើម្បីបំបាត់ភាពស្រេកឃ្លាន។ នៅក្នុងព្រៃខ្ញុំដេកនៅក្រោមដើមឈើជារៀងរាល់យប់ជាមួយនឹងអ្នកឯទៀតដែរ។ សមាជិកដែលមកដេកក្រោមដើមឈើជាមួយគ្នា ក៏បានបាត់អស់ជាច្រើននាក់ដែរពីមួយថ្ងៃទៅមួយថ្ងៃ បន្ទាប់ពីស្រាវជ្រាវដឹងថាពួកគេមកពីភូមិភាគបូព៌ា និងត្រូវបានសង្ស័យថាជាជនជាតិវៀតណាម។ ក្រៅពីនេះខ្ញុំក៏ដឹងទៀតដែរអំពីការយកមនុស្សទៅសម្លាប់របស់ខ្មែរក្រហម។ ខ្ញុំបានឃើញខ្មែរក្រហមយកកាំភ្លើងភ្ជង់មនុស្សរួចបណ្តើរយកទៅរៀនសូត្រដោយផ្ទាល់នឹងភ្នែក។ ពេលនោះ ខ្ញុំភ័យណាស់ ហើយក៏រន្ធត់ខ្លាំងណាស់ដែរ។ ខ្ញុំបានឃើញសាកសព។ ខ្ញុំគិតតែពីខិតខំប្រឹងធ្វើការ ដោយពុំហ៊ាននិយាយអ្វីចេញមកក្រៅឡើយ ទាក់ទងនឹងរឿងទាំងនេះ។

ប៉ុន្មានខែកន្លងផុតទៅ នៅក្នុងខេត្តពោធិ៍សាត់ ខ្មែរក្រហមបានជម្លៀសប្រជាជនរួមទាំងខ្ញុំ ឲ្យបន្តដំណើរទៅមុខទៀត ប៉ុន្តែក៏ជួបជាមួយនឹងកងកម្លាំងវៀតណាម ប្រាប់ឲ្យបកក្រោយវិលមកភូមិកំណើតវិញ។ ខ្ញុំនិងគ្រួសារបានជួបជុំគ្នាហើយបានដើរមកដល់ភ្នំពេញក្នុងរយៈពេល១៥ថ្ងៃ។ ខ្ញុំនិងគ្រួសារបានស្នាក់នៅទីក្រុងភ្នំពេញចំនួន២ថ្ងៃ ដោយសារតែនៅទីក្រុងភ្នំពេញមានការទទួលប្រជាជនដោយការចែកជូននូវទឹកដោះគោ និងអាហារហូបចុកផ្សេងៗ។ បន្ទាប់មកខ្ញុំបានមកដល់ស្រុកកំណើតវិញហើយចាប់ផ្តើមរកស៊ីលក់នំបញ្ចុក។ សព្វថ្ងៃខ្ញុំគឺជាកសិករធ្វើចម្ការនៅក្នុងភូមិព្រៃឃ្នេស ខ ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។

## ៦) វ័ន្ត សារឿន ៖ យោធាខ្មែរក្រហម



វ័ត្ត សារឿន អាយុ៧៨ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិបារាច ឃុំព្រៃឃ្នេស ស្រុកមេសាងខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ វ័ត្ត សារឿន មានអាយុ៧៨ឆ្នាំ។ សព្វថ្ងៃខ្ញុំរស់នៅជាមួយនឹងភរិយារបស់ខ្ញុំឈ្មោះ ឡេ ហឿន នៅក្នុងភូមិគ្រួស ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង ។ ខ្ញុំមានបងប្អូនចំនួន៥នាក់ និងស្លាប់អស់ចំនួន៣នាក់។ ខ្ញុំធ្លាប់រៀននៅវត្តស្វាយ ក្រោយមកបានប្តូរទៅរៀននៅសាលាសំបួរ។ ដោយសារតែជីវភាពក្រីក្រ ខ្ញុំបានឈប់រៀន ត្រឹមថ្នាក់ទី៩។ ខ្ញុំត្រូវជួយឪពុកម្តាយដើរលក់នំបញ្ចុកដើម្បីចិញ្ចឹមជីវិត។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ខ្ញុំក៏បានស្ម័គ្រចូលបម្រើនៅក្នុងជួរកងទ័ពតាមភូមិស្រុក។ ខ្ញុំបានហាត់រៀនក្បួនយុទ្ធសាស្ត្រ លូន និងក្រាប។ រហូតដល់ឆ្នាំ១៩៧៥ អង្គការបានស្នើឲ្យខ្ញុំដឹកនាំកងចល័តទៅធ្វើស្រែនៅតំបន់ផ្សេងៗ។ ភាគច្រើន ខ្ញុំដឹកនាំក្រុមអ្នកធ្វើស្រែទៅ ខាងព្រៃទទឹង។ ខ្ញុំត្រូវរាយការណ៍ឲ្យឃុំជារៀងរាល់ថ្ងៃអំពីការធ្វើស្រែរបស់ប្រជាជន។ នៅចុងឆ្នាំ១៩៧៨ ខ្ញុំត្រូវបានអង្គការជម្លៀសទៅកាន់ពោធិ៍សាត់។ ពេលនោះ គឺជាពេលដែលខ្ញុំពិបាកជាងគេ ព្រោះពុំមានអាហារហូបចុកគ្រប់គ្រាន់ឡើយ។ ការងារនៅតំបន់ពោធិ៍សាត់របស់ខ្ញុំ គឺឡើងត្នោត និងកាប់ភ្លឺស្រែ។ ខ្ញុំធ្វើការបែបនេះដដែលៗជារៀងរាល់ថ្ងៃរហូតដល់ថ្ងៃខ្មែរក្រហមដួលរលំ។

ក្រោយបែកឆ្នាំ១៩៧៩ ខ្ញុំបានវិលមកភូមិកំណើតវិញ។ រឿងរ៉ាវដែលខ្ញុំចាំមិនភ្លេចនៅក្នុងរបបខ្មែរក្រហមគឺអង្គការបានប្រើឲ្យខ្ញុំធ្វើការ ទាំងថ្ងៃទាំងយប់ និងហូបចុកពុំគ្រប់គ្រាន់។

## ៧) អោ ព្រឿង ៖ ពេទ្យ



អោ ព្រឿង អាយុ៧០ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិបារាច ឃុំព្រៃឃ្នេស ស្រុកមេសាងខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំ២០២២ នេះ អោ ព្រឿង មានអាយុ៧០ឆ្នាំហើយ។ សព្វថ្ងៃ អោ ព្រឿង រស់នៅភូមិត្រពាំងដូង ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ អោ ព្រឿង បាននិយាយរៀបរាប់ថា កាលនៅក្មេង ខ្ញុំពុំសូវរៀនបានជិតដល់ទេ ក៏ព្រោះតែជីវភាពក្រីក្រលំបាក។ ខ្ញុំបានរៀនត្រឹមថ្នាក់ទី១១ ពីសង្គមចាស់ នៅសាលាបឋមសិក្សាព្រែកជ្រៃ។ ម្តាយរបស់ខ្ញុំ ឈ្មោះ យន់ ទន់ គឺជាអ្នកលក់នំបញ្ចុកក្នុងភូមិព្រែកជ្រៃ។

នៅឆ្នាំ១៩៦៩ ខ្ញុំមានអាយុ១៥ឆ្នាំ ម្តាយរបស់ខ្ញុំបានស្លាប់ដោយសារជំងឺ។ ខ្ញុំមិនដឹងទៅណាបន្តទៀតទេ។ ខ្ញុំសម្រេចចិត្តទៅស៊ីឈ្នួលឲ្យជនជាតិចិននៅក្នុងភូមិព្រែកជ្រៃ។ ជនជាតិចិននោះគឺជាអ្នករកស៊ី ជួលកាណូតពីព្រៃវែងទៅអ្នកលឿង និងទៅភ្នំពេញ។

ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រទេសជាតិចាប់ផ្តើមកើតមានសង្គ្រាម។ កាណូតរបស់ជនជាតិចិនក៏ចេញរកស៊ីពុំបានតទៅទៀត។ ខ្ញុំក៏បានឈប់ពីការងារ

កាណូត។ ក្នុងគ្រានោះមានប្រជាជនជាច្រើនព្រមទាំងមេភូមិបានចុះចូលជាមួយនឹងក្រុមខ្មែររំដោះ ហើយខ្ញុំត្រូវបានមេភូមិលើកឲ្យធ្វើជាសេនាជន ដើម្បីការពារភូមិ។

នៅឆ្នាំ១៩៧១ ខ្ញុំបួសជាព្រះសង្ឃ។ ក្នុងពេលបួសជាព្រះសង្ឃ ខ្ញុំអាចរៀនសូត្រចេះដឹងបានជ្រៅជ្រះដែរ។ ខ្ញុំបួសបានរយៈពេលមួយឆ្នាំ ក៏បានសឹកដោយសារតែមានការទម្លាក់គ្រាប់បែកយ៉ាងខ្លាំង នៅក្នុងភូមិរបស់ខ្ញុំ។ បន្ទាប់ពីសឹករួច មេភូមិបានមើលឃើញថា ខ្ញុំទើបតែសឹកពីបួសហើយក៏មានចំណេះដឹងគ្រាន់បើដែរ ខ្ញុំក៏ត្រូវបានបញ្ជូនឲ្យទៅរៀនផ្នែកពេទ្យក្នុងភូមិបារាច។ ខ្ញុំយល់ព្រមទៅដោយពុំមាននរណាម្នាក់បង្ខំឡើយ ដោយសារតែគ្មានឪពុកគ្មានម្ដាយ ម្ល៉ោះហើយទើបបានជា ខ្ញុំស្ម័គ្រចិត្តចូលរៀនផ្នែកពេទ្យ ។ ខ្ញុំរៀនពេទ្យបានរយៈពេល៣ខែ ដោយប្រធានពេទ្យឈ្មោះ ស៊ន គឺជាអ្នកបង្រៀន។ អ្នករៀនពេទ្យពេលនោះមានគ្នា៥នាក់បូករួមទាំងខ្ញុំផងដែរ។ កាលរៀនពេទ្យដំបូង ប្រធាន ស៊ន បានឲ្យខ្ញុំរៀនចាក់ម្ជុលលើខ្នើយ ដែលគូររាងជាត្រគាកមនុស្ស រៀនផ្សំថ្នាំចាក់ ផ្សំថ្នាំទឹកដបពណ៌ទឹកក្រូច និងថ្នាំអំពូល។ ក្រៅពីនេះ មានអាស្ពីរីន វីតាមីនកា វីតាមីនបេ ជាដើម ដែលកុម្ម៉ង់ពីប្រទេសចិន។ រយៈពេល៣ខែក្រោយមក វគ្គសិក្សាពេទ្យបានបញ្ចប់ ខ្ញុំក៏បានទៅរៀននយោបាយចំនួនរយៈពេល៣ខែទៀត នៅភូមិពោធិ៍ស្វាយ។ បន្ទាប់ពីចប់វគ្គនយោបាយ ខ្ញុំមិនបានត្រឡប់ទៅស្រុកវិញទេ ចំណែកឯអ្នកផ្សេងទៀត ដែលបានរៀនជាមួយ ខ្ញុំគ្រប់វគ្គគ្រប់ម៉ោងនោះ ពួកគេបានត្រឡប់ទៅផ្ទះវិញ ហើយដោយសារតែពួកគេមានគ្រួសារដែលត្រូវមើលថែ។ ចំណែកឯខ្ញុំវិញ មិនមានគ្រួសារដែលត្រូវមើលថែដូចអ្នកឯទៀតទេ អង្គការក៏បញ្ជូន ខ្ញុំទៅធ្វើពេទ្យទាហានបន្តនៅវត្តប្រស្វានៅឆ្នាំ១៩៧៥។ នៅវត្តប្រស្វា ខ្ញុំបានរៀនពីវិធីធ្វើថ្នាំអាចម៍ទន្សាយ និងកាប់ឈើព្រៃមកកិនធ្វើថ្នាំជាដើម។

នៅឆ្នាំ១៩៧៦ ខ្ញុំក៏ផ្លាស់ទៅប្រចាំការនៅកោះស្លុ។ ខ្ញុំបានប្រចាំការនៅទីនោះ រហូតដល់ដើមឆ្នាំ១៩៧៩។ នៅដើមឆ្នាំ១៩៧៩ វៀតណាម បានវាយចូលមកដល់កោះស្លុ នៅត្រើយម្ខាង។ ខ្ញុំក៏បានចេញទៅច្បាំងនៅសមរភូមិដែរ។ ខ្ញុំត្រូវវៀតណាមបាញ់ចំត្រង់ភ្លៅ។ ខ្ញុំបានរត់មកស្រុកខាងឪពុក នៅឯស្រុកបាភ្នំ ដើម្បីព្យាបាលរបួស ប៉ុន្តែពុំមាននរណាម្នាក់ហ៊ានព្យាបាលរបួសខ្ញុំឡើយ។ ខ្ញុំបានរត់មកអ្នកលឿង បន្តទៀតក៏ជួបជាមួយកងទ័ពនារី ហើយខ្ញុំក៏បានទទួលការព្យាបាលនៅគ្រានោះតែម្ដង។ ក្រោយបែកឆ្នាំ១៩៧៩ ខ្ញុំរៀបការជាមួយនឹងភរិយារបស់ខ្ញុំ និងមានកូនចំនួន៣នាក់ ប្រុស២ ស្រី១។ នៅឆ្នាំ២០២០ ភរិយារបស់ ខ្ញុំបានស្លាប់ដោយសារជំងឺ។ ខ្ញុំស៊ីឈ្នួលដុត ឡផ្ដង រហូតមកដល់សព្វថ្ងៃ។

## ៨) លាស់ សុខា ៖ ក្រុមកុមារឈានមុខ



លាស់ សុខា គឺជាប្រជាពលរដ្ឋរស់នៅភូមិត្រពាំងព្រះ ឃុំព្រៃឃ្នេស ស្រុកមេសាងខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នាងខ្ញុំមានឈ្មោះ លាស់ សុខា ។ នៅក្នុងឆ្នាំ២០២២ នេះ ខ្ញុំមានអាយុ ៥៨ ឆ្នាំ។ ខ្ញុំរស់នៅភូមិត្រពាំងព្រះ២ ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំបានរៀនត្រឹមថ្នាក់ទី៣ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សម័យនោះពុំមានបន្ទប់រៀនត្រឹមត្រូវទេ ការរៀនសូត្រគឺបានប្រព្រឹត្តទៅនៅក្រោមដើមឈើ។ មួយថ្ងៃខ្ញុំរៀនបាន២ ម៉ោង គឺចាប់ពីម៉ោង ៧ដល់ម៉ោង ៩ ព្រឹក។ បន្ទាប់ពីចប់ម៉ោងរៀន ខ្ញុំត្រូវទៅធ្វើការបន្តទៀត។ ជីវិតនៅពេលនោះគឺពិបាកណាស់។ កាលនៅក្នុងរបប លន់ នល់វិញ ស្រុកទេស ក៏មានការលំបាកខ្លាំង

ណាស់ដែរ។ មានការទម្លាក់គ្រាប់បែកមកលើភូមិខ្ញុំ បណ្តាលឲ្យខ្ញុំរត់គេចខ្លួនជាច្រើនកន្លែង។ កាលនោះខ្ញុំទើបតែមានអាយុ១២ឆ្នាំប៉ុណ្ណោះ។ គ្រួសាររបស់ខ្ញុំបានបែកផ្លូវគ្នា ក្នុងអំឡុងពេលទម្លាក់គ្រាប់បែក។ ខ្ញុំមានបងប្អូនចំនួន៦នាក់ ប្រុស២និង ស្រី៤។ ខ្ញុំនិងបងស្រីរបស់ខ្ញុំឈ្មោះ លាស់ សម្បត្តិបានរត់គេចទៅភូមិស្វាយដើម្បីរកកន្លែងសុវត្ថិភាពមួយរយៈ។ ខ្ញុំជាមួយបងស្រីភ័យ និងយំខ្លាំងណាស់នៅពេលដែលមិនមានម្តាយនៅក្បែរ។ ពីរនាក់បងប្អូនខ្ញុំ បានទៅសុំផ្ទះអ្នកភូមិ ដើម្បីសុំស្នាក់អាស្រ័យជាបណ្តោះអាសន្ន។ ពេលសភាពការណ៍ស្ងប់ស្ងាត់មួយខែក្រោយមក យើងក៏បានរកគ្នាឃើញវិញ។

ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលខ្មែរក្រហមបានវាយបែកទីក្រុងភ្នំពេញ អង្គការបានកំណត់ឲ្យប្រជាជនធ្វើការគ្រប់ៗគ្នា។ សម្រាប់ខ្ញុំការងារដំបូង ស្ថិតនៅក្នុងរដូវប្រាំង ខ្មែរក្រហម បានប្រើឲ្យខ្ញុំទៅលើកអាងទឹក ស្រោចដំណាំក្រចៅ រែកដី និងជីកប្រឡាយ។ ភាគច្រើនយើងទៅព្រៃឃ្នេស ជិនទ័យ និងមេសាង ដើម្បីធ្វើកិច្ចការនេះ។ ខ្ញុំស្ថិតក្នុងក្រុមកុមារឈានមុខ មានសមាជិកក្រុមចំនួន ១៥នាក់ ដែលមានតា ធិន ជាអ្នកគ្រប់គ្រង។ តា ធិន ជាមនុស្សកាចណាស់។ ខ្ញុំខ្លាចគាត់។ ខ្ញុំមិនហ៊ានមកធ្វើការយឺតមួយថ្ងៃណាឡើយ។ នៅពេលដែលដល់រដូវវស្សា អង្គការបានបញ្ជូនខ្ញុំមកក្នុងភូមិវិញ ដើម្បីមកធ្វើបង្គន់អនាម័យ ធ្វើជីលេខ១ ទូលជីយកទៅដាក់ស្រែ និងស្ទូងស្រូវ។ ការងារស្ទូងនោះជួនកាលខ្ញុំបន្តធ្វើរហូតដល់យប់ជ្រៅទៀតក៏មាន ដើម្បីឲ្យទាន់ផែនការកំណត់ ១ហិកតា ២០នាក់ ក្នុង១ថ្ងៃ។ ខ្ញុំធ្វើការបែបនេះរហូតដល់ថ្ងៃខ្មែរក្រហមដួលរលំ។ សម្រាប់អាហារហូបចុកវិញ កាលពីដំបូងឡើយមានគ្រប់គ្រាន់ ប៉ុន្តែចាប់ពីឆ្នាំ ១៩៧៧ ដល់ ១៩៧៨ ទៅ គឺចាប់ផ្តើមរឹតបន្តឹងទៅៗ ទាំងការហូបចុក ទាំងការងារ និងការរស់នៅ។ ការហូបចុកទទួលបានរបបអាហារតិចជាងមុន ការងារក៏កាន់តែច្រើនជាងមុន និងប្រជាជនរស់នៅគ្មានសិទ្ធិសេរីភាព។

នៅចុងឆ្នាំ១៩៧៨ ពេលវៀតណាមវាយជិតចូលមកដល់ភូមិ ប្រជាជនមានភាពចលាចល។ ប្រធានសហករណ៍បានជម្លៀសប្រជាជនចេញពីភូមិដើម្បីការពារកុំឲ្យកងទ័ពវៀតណាមកៀរយក ប៉ុន្តែដោយសារនៅអ្នកលឿងមានការបំផ្ទុះគ្រាប់បែកយ៉ាងខ្លាំងទើបខ្ញុំត្រូវវិលត្រឡប់ចូលមកភូមិវិញ។ ក្រោយបែកឆ្នាំ១៩៧៩ ខ្ញុំបានដើរប្រមូលស្រូវទុកហូបនៅផ្ទះ។ ខ្ញុំដាំដំណាំដើម្បីទុកហូបខ្លួនឯង មិនមានការភ័យខ្លាចដូចនៅក្នុងរបបខ្មែរក្រហមទៀតឡើយ។ ក្រោយខ្មែរក្រហមដួលរលំ ខ្ញុំបានរៀបការជាមួយនឹងស្វាមីរបស់ខ្ញុំ ឈ្មោះ ស្រី ពៅ។ ខ្ញុំរៀបការហើយ មានកូនប្រុសចំនួន១នាក់។ សព្វថ្ងៃខ្ញុំជាកសិករធ្វើស្រែ និងនៅមើលថែឪពុកចាស់ជរានៅផ្ទះ។ សម្រាប់បទពិសោធន៍របស់ខ្ញុំ ដែលខ្ញុំចាំមិនភ្លេចនៅក្នុងរបបខ្មែរក្រហមនោះគឺ ខ្មែរក្រហមបានប្រើឲ្យខ្ញុំធ្វើការទាំងថ្ងៃទាំងយប់ មិនមានសម្លៀកបំពាក់ហូបចុកពុំបានគ្រប់គ្រាន់ ហើយមិនមានសិទ្ធិធ្វើអ្វីដែលខ្លួនឯងចង់ធ្វើ។



ទេសភាពវាលស្រែក្នុងឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវរបស់អ្នករស់រានមានជីវិត
## ពីរបបខ្មែរក្រហមនៅភូមិបឹងជ្រោង ឃុំជាំ ស្រុកមេមត់ ខេត្តកំពង់ចាម

ឈឿង ចាន់ធី, គាត ស្រីឡែន និង ឈុំ រ៉ា

ភូមិបឹងជ្រោងស្ថិតនៅចម្ងាយប្រមាណ ២៣ គីឡូម៉ែត្រពីទីរួមស្រុកមេមត់ និងប្រមាណ ១៣ គីឡូម៉ែត្រប៉ែកខាងកើតផ្លូវជាតិលេខ៧។ ភូមិសាស្ត្រភូមិបឹងជ្រោងស្ថិតនៅជាប់ព្រំដែននៃប្រទេសវៀតណាម។ បើតាមលោក មើក នូវ មេឃុំជាំ បានឲ្យដឹងថា ចាស់ៗជំនាន់មុនដំណាលតៗគ្នាមកថាភូមិបឹងជ្រោងនេះកាលពីដើមឡើយមានឈ្មោះថា ភូមិសាងជ្រោង គឺជំនាន់អាណានិគមនិយមបារាំងនៅប្រមាណជាឆ្នាំ១៨៨០មានកូនប្រុសលោក ពោធិ៍កំបោរ ឈ្មោះ វិន ស្វា បានមករៀបចំកសាងកងទ័ពដើម្បីតស៊ូប្រឆាំងអាណានិគមនិយមបារាំងនៅតំបន់នេះ។ បន្ទាប់មកអ្នកស្រុករស់នៅតំបន់នេះដែលមានពូជពង្សជាអ្នកងារ និងបានភៀសខ្លួនពីត្បូងឃ្មុំជំនាន់ទុំទាវមករស់នៅទីនេះបាននាំគ្នាហៅឈ្មោះតំបន់នេះថា ភូមិសាងជ្រោង។ ក្រោយៗមកភូមិសាងជ្រោងនេះត្រូវបានអ្នកភូមិហៅជាភូមិបឹងជ្រោងវិញដោយសារប៉ែកខាងត្បូងនៃភូមិនេះជាប់នឹងបឹងធំមួយមានឈ្មោះបឹងជ្រោង។

នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ ភូមិបឹងជ្រោងបានធ្លាប់ចូលក្នុងសង្គ្រាមវៀតណាម ដោយសារកងទ័ពវៀតកុងបានឆ្លងចូលមករស់នៅ និងធ្វើសកម្មភាពប្រឆាំងសហរដ្ឋអាមេរិកនៅក្នុងទឹកដីកម្ពុជា ទាហានសហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកមកលើភូមិបឹងជ្រោង និងភូមិដទៃទៀតដែលស្ថិតនៅតាមបណ្ដោយព្រំដែនវៀតណាម។ ការទម្លាក់គ្រាប់បែកដ៏ច្រើនសន្ធឹកសន្ធាប់មកលើភូមិបឹងជ្រោងនោះបានធ្វើឲ្យអ្នកភូមិបឹងជ្រោងរត់ភៀសខ្លួនទៅរស់នៅភូមិផ្សេងៗទៀតអស់។ ភូមិបឹងជ្រោងត្រូវបានបោះបង់ចោលនៅកំឡុងសង្គ្រាមឆ្នាំ១៩៧០- ១៩៧៥។

នៅពេលរបបខ្មែរក្រហមឡើងកាន់កាប់អំណាចនៅចន្លោះឆ្នាំ(១៩៧៥-១៩៧៩) ភូមិបឹងជ្រោងបានក្លាយជាសមរភូមិប្រយុទ្ធដណ្ដើមទឹកដីគ្នា រវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម។ នៅពេលនោះទីធ្លា និងវិហារវត្តបឹងជ្រោងបានក្លាយជាតំបន់ប្រទាញប្រទង់រវាងកងទ័ពនៃប្រទេសទាំងពីរ។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំទៅនៅឆ្នាំ១៩៧៩ អ្នកភូមិបឹងជ្រោងបានត្រឡប់មករស់នៅភូមិកំណើតវិញ ប៉ុន្តែនៅគ្រាដំបូងអាជ្ញាធរវៀតណាមមិនអនុញ្ញាតឲ្យប្រជាជនមករស់នៅក្នុងភូមិបឹងជ្រោងឡើយ ដោយភាគីវៀតណាមបានអះអាងថា ភូមិបឹងជ្រោងជាតំបន់ព្រំដែន ប្រជាជនមិនអាចរស់នៅបានឡើយ ប៉ុន្តែអ្នកភូមិបឹងជ្រោងបានតវ៉ា ដោយសំអាងថាពួកគាត់បានរស់នៅក្នុងភូមិនេះតាំងពីជីដូនជីតាតៗមក។ ម្យ៉ាងទៀតអ្នកភូមិក៏បានបង្ហាញដល់អាជ្ញាធរវៀតណាម នូវសេចក្ដីថ្លែងការណ៍ចំនួន ១១ (ខ) របស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ចំណុច (ខ) ទី៤ ដែលបាននិយាយអំពីការអនុវត្តសិទ្ធិសេរីភាព លទ្ធិប្រជាធិបតេយ្យពិតប្រាកដ។ គោរពសិទ្ធិ និងតម្លៃមនុស្សរបស់ប្រជាជនគ្រប់ជាន់ថ្នាក់។ បើកសិទ្ធិជូនប្រជាជនឲ្យវិលត្រឡប់មករស់តាមភូមិឋានចាស់របស់ខ្លួន និងកសាងជីវភាពរស់នៅប្រកបដោយសុភមង្គលក្នុងគ្រួសារឡើងវិញ។ ធានាសិទ្ធិក្នុងការស្នាក់អាស្រ័យ នូវការធ្វើដំណើរក្នុងប្រទេសដោយសេរី មានសិទ្ធិក្នុងការឈរឈ្មោះជាបេក្ខជនបោះឆ្នោត

ជ្រើសតាំង មានសិទ្ធិសេរីភាពក្នុងការនិយាយស្តី មានសិទ្ធិសេរីក្នុងការបង្កើតសមាគម មានសិទ្ធិសេរីភាពក្នុងជំនឿសាសនា មានសិទ្ធិប្រកបពលកម្មសម្រាកនិងរៀនសូត្រ។ ធានាអះអាងនូវសិទ្ធិសេរីភាពខាងរូបកាយរបស់ប្រជាជនគ្រប់រូប។ មានសិទ្ធិរស់នៅស្មើភាព។ មានកាតព្វកិច្ច និងមានផលប្រយោជន៍ដូចគ្នា។ ទើបភាគីវៀតណាមយល់ព្រមឲ្យអ្នកភូមិចូលមករស់នៅក្នុងភូមិបឹងជ្រោងជាធម្មតាវិញ។

***ខាងក្រោមគឺជាការរៀបរាប់របស់ប្រជាជននូវរឿងរ៉ាវដែលបានឆ្លងកាត់របបខ្មែរក្រហម ៖***

## ១) ខេន ដេន ៖ កងទ័ពខ្មែរក្រហមតំបន់២១



*ខេន ដេន អាយុ៦៩ឆ្នាំ រស់នៅភូមិលាជក្រោម ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ខេន ដេន ភេទប្រុស អាយុ ៦៩ឆ្នាំ កើតនៅភូមិលាជក្រោម (ភូមិថ្នល់ថ្មី) ឃុំជាំ ស្រុកមេមត់ ខេត្តកំពង់ចាម បច្ចុប្បន្នរស់នៅភូមិលាជក្រោម ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឪពុករបស់ខ្ញុំឈ្មោះ អើប ខេន បានស្លាប់ក្នុងឆ្នាំ២០១៩ ដោយសារចាស់ជរា ចំណែកម្តាយឈ្មោះ ស៊ីវ តូច ស្លាប់ឆ្នាំ២០១០ ដោយសារជំងឺ។ ប្រពន្ធខ្ញុំឈ្មោះ ពូ សុគន្ធ មានអាយុ ៧២ឆ្នាំ និងមានកូនប្រុស២នាក់។ ខ្ញុំមានបងប្អូនចំនួន២នាក់ (ស្រី១ និងប្រុស១)។ ខ្ញុំជាកូនទី២ក្នុងគ្រួសារ។ នៅអាយុ១០ឆ្នាំ ឪពុកខ្ញុំបានយកខ្ញុំទៅរៀននៅវត្ត។ កាលនោះគ្មានសាលារៀនទេ គឺក្មេងៗត្រូវទៅរៀននៅវត្តជាមួយព្រះសង្ឃ។ ខ្ញុំបានរៀនជាមួយលោកពីឆ្នាំ១៩៦៣ រហូតដល់ឆ្នាំ១៩៦៨។

ពេលទាហានអាមេរិកទម្លាក់គ្រាប់បែកនៅក្នុងភូមិ អ្នកភូមិក៏រត់ចេញពីភូមិអស់ ខ្ញុំក៏បានរត់ទៅតាមពុកម្តាយខ្ញុំដែរ។ រស់នៅស្រុកមេមត់បានរយៈពេល ១ឆ្នាំ ខ្ញុំ និងឪពុកម្តាយបានចេញពីមេមត់ទៅរស់នៅភូមិម្លោរ។ បន្ទាប់មកបន្តទៅរស់នៅភូមិត្រពាំងឫស្សី ឃុំរូង ស្រុកមេមត់។ ពេលទៅនៅស្រុកគេដំបូងគ្មានផ្ទះសំបែងឡើយ គ្រួសារខ្ញុំបានសុំផ្ទះអ្នកភូមិស្នាក់នៅបណ្តោះអាសន្នទម្រាំតែធ្វើខ្ទមរួចរាល់។ នៅពេលនោះអ្នកភូមិហៅគ្រួសារខ្ញុំថា អ្នកបាក់គ្រួ គឺមានន័យថាអ្នករត់ភៀសខ្លួន។ ឪពុកខ្ញុំបានធ្វើផ្ទះសម្រាប់ស្នាក់នៅរួចក៏ទៅកាប់ព្រៃគាស់រានដីសម្រាប់ដាំស្រូវ ដាំពោត ដាំសណ្តែកខ្លះ។ គ្រួសារខ្ញុំនៅភូមិត្រពាំងឫស្សីបាន ៣ឆ្នាំ ដាំស្រូវបាន ៣ ជម្រុក។ ក្រោយមកគ្រួសារខ្ញុំត្រឡប់មកនៅភូមិកំណើតវិញ។ ពេលខ្ញុំដល់ភូមិគ្មានសេសសល់អ្វី សូម្បីតែកន្ទេលមួយគ្មានផង។ ពេលដេក ខ្ញុំយកស្លឹកឈើមកធ្វើជាកម្រាលជំនួសកន្ទេលវិញ។ នៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានជ្រើសរើសយុវជនឲ្យធ្វើយោធារំដោះជាតិនៅក្នុងភូមិខ្ញុំ។ ខ្ញុំបានចុះឈ្មោះធ្វើយោធាតែម្នាក់ឯង។ ដំបូងខ្មែរក្រហមឲ្យខ្ញុំធ្វើយោធាស្រុកមេមត់រយៈពេល ៣ខែ បន្ទាប់មកខ្មែរក្រហមបានបញ្ជូនខ្ញុំទៅខាងទន្លេបិទវិញ។ ពេលនោះខ្ញុំស្ថិតនៅក្នុងកងវរសេនាតូចលេខ ៥៩ តំបន់ ២១ ភូមិភាគបូព៌ា។ ប្រធានវរសេនាតូចលេខ៥៩ មានឈ្មោះ សឿង ឈ្មោះ លី សុភាព តែក្រោយមកឈ្មោះ លី សុភាព ត្រូវបានខ្មែរក្រហមសម្លាប់ចោល។ កងវរសេនាតូចលេខ ៥៩ មានកងអនុសេនាធំចំនួន ៣ជាចំណុះ គ៩៥ គ៩៦ និងគ៩៧។ ខ្ញុំស្ថិតនៅក្នុងកងអនុសេនាធំលេខ៩៧ ដែលមានឈ្មោះ សិលា ជាប្រធាន។ ពេលវាយប្រយុទ្ធជាមួយទាហាន លន់ នល់ នៅទន្លេបិទ នោះកងទ័ពតំបន់២១ មាន៣ កងវរសេនាតូច គឺ កងវរសេនាលេខ៥៥ កងវរសេនាតូចលេខ ៥៩ និងកងវរសេនាតូចលេខ៣១។

ពេលខ្មែរក្រហមដណ្តើមបានទីក្រុងភ្នំពេញនៅ

ឆ្នាំ១៩៧៥។ អង្គភាពខ្ញុំត្រូវបានដកមកធ្វើស្រែនៅក្នុងស្រុកដំបែរ។ នៅចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦ អង្គភាពខ្ញុំត្រូវបញ្ជូនមកបោះទីតាំងនៅភូមិរំដេងក្បែរភូមិកោះថ្មក្នុងឃុំទន្លូង។ នៅឆ្នាំ១៩៧៧ អង្គភាពខ្ញុំត្រូវបញ្ជូនទៅលើកអាងនៅបឹងកញ្ចប់ ក្បែរស្ពានមាត់ឃ្មុំង។ នៅឆ្នាំ១៩៧៨ អង្គភាពខ្ញុំត្រូវបានរំសាយដោយកងទ័ពមជ្ឈិម ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនទៅរស់នៅខាងភ្នំព្រិច ស្រុកសំបូរ ខេត្តក្រចេះ ប្រហែលគាត់បានរយៈពេល៣ខែ ក៏បន្តមករស់នៅតាមមាត់ទន្លេ ខាងបុស្សលាវ។ ចុងក្រោយ ខ្ញុំត្រូវខ្មែរក្រហមបញ្ជូនឡើងកាណូតពីក្រចេះទៅស្រុកស្ទឹងត្រង់ និងជិះឡានបន្តទៅស្រុកចម្ការលើទៀត។ នៅចម្ការលើមិនយូរប៉ុន្មាន កងទ័ពវៀតណាមក៏ចូលមកដល់ និងបានប្រកាសឲ្យយើងត្រឡប់មកស្រុកកំណើតរៀងៗខ្លួនវិញ។

## ២) ខេន ឃឿនៈ នារីកងចល័តសម័យខ្មែរក្រហម



ខេន ឃឿន អាយុ៧០ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិថ្នល់ថ្មី ឃុំដាំ ស្រុកមេមត់ ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ខេន ឃឿន ភេទស្រី អាយុ៧០ឆ្នាំ មានស្រុកកំណើតនៅភូមិថ្នល់ថ្មី ឃុំដាំ ស្រុកមេមត់ ខេត្តកំពង់ចាម បច្ចុប្បន្ននៅភូមិលាជលើ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានបងប្អូនចំនួន២នាក់ (ស្រី១នាក់ និងប្រុស១នាក់) រាល់ថ្ងៃខ្ញុំរស់នៅតែម្នាក់ឯង ហូបបាយតែម្នាក់ឯង ព្រោះខ្ញុំមិនធ្លាប់មានគ្រួសារនឹងគេ។ កាលពីកុមារភាពខ្ញុំមិនដែលបានរៀនសូត្រទេ។ កាលពីក្មេងម៉ែឲ្យតែមើលគោ និងក្របី។ ម្យ៉ាងទៀតកាលជំនាន់ពីដើមមិនមានសាលារៀនច្រើនដូចឥឡូវទេ ចាស់ៗនិយាយថាមនុស្សស្រីមិនចាំបាច់រៀនសូត្រចេះដឹងទេ ទោះបីជារៀនបានចេះដឹងក៏មិនដឹងយកធ្វើអីកើតដែរ។ សព្វថ្ងៃខ្ញុំមិនចេះអក្សរទេ។ អ្នកបានរៀនសូត្រចេះដឹងកាលពីសម័យមុនភាគច្រើនជាមនុស្សប្រុស ដោយសារតែពួកគាត់អាចបួសរៀននៅក្នុងវត្តបាន។

ចុងឆ្នាំ១៩៦០ និងដើមឆ្នាំ១៩៧០ អាមេរិកទម្លាក់គ្រាប់បែក និងចូលមកបាញ់យៀកកុង ខ្ញុំនិងអ្នកភូមិបានរត់ចូលក្នុងរណ្ដៅដើម្បីលាក់ខ្លួនពីគ្រាប់បែក។ ថ្ងៃមួយ ខ្ញុំឃើញយន្តហោះរបស់អាមេរិកចុះចត ខ្ញុំមានការភ័យខ្លាច បានរត់ចេញពីរណ្ដៅ ហើយត្រូវបានទាហានអាមេរិកចាប់ខ្លួន។ ចំណែកម្ដាយខ្ញុំនៅក្នុងភូមិមិនត្រូវបានអាមេរិកចាប់ទេ ពីព្រោះទាហានអាមេរិកមិនបានចូលភូមិឡើយ។ ទាហានអាមេរិកចាប់ខ្ញុំដោយស្មានថាខ្ញុំជាអ្នកយកការណ៍ឲ្យកងទ័ពយៀកកុង។ ដំបូងទាហានអាមេរិកចាប់ខ្ញុំទៅប៉ុស្តិ៍សាឡៅនៅក្នុងឃុំដាំ។ អ្នកបកប្រែភាសាបានសួរខ្ញុំថា តើមានបានចូលដៃជើងជាមួយយៀកកុងទេ? ខ្ញុំឆ្លើយថាមិនដឹងទេ ទើបគេឈប់សួរនាំទៀត។ ទាហានអាមេរិកឲ្យខ្ញុំហូបបាយឆ្អែត។ ខ្ញុំនៅទីនោះបានមួយខែ ទើបអាមេរិកបញ្ជូនខ្ញុំទៅនៅជាមួយដោយបោះទីតាំងនៅតាមព្រៃក្បែរភូមិម្រាន់ ភូមិជ្រឡើង ក្នុងឃុំដាំក្រវៀនបន្តទៀត។ ទាហានអាមេរិកបានឲ្យខ្ញុំដាំបាយឲ្យទាហានហូប តែមុនពេលចូលទៅកន្លែងដាំបាយ ទាហានអាមេរិកឆែកឆេរក្រែងលោខ្ញុំមានលាក់កាំភ្លើងឬគ្រាប់បែក។ ទាហានអាមេរិកចិត្តល្អណាស់ បានចែកនំឲ្យប្រជាជនហូបទៀតផង។ ខ្ញុំទទួលបានត្រីងៀត ត្រីខ និងអង្ករ គេចែកនៅភូមិម្រាន់។

ក្រោយមក ខ្ញុំបានទៅរស់នៅទីរួមស្រុកមេមត់។ ចំណែកយាយ និងម្ដាយខ្ញុំបានរស់នៅស្រុកកំណើតជាមួយគ្នា។ ក្រោយមក ម្ដាយខ្ញុំបានទុកយាយខ្ញុំចោលឲ្យនៅក្នុងផ្ទះម្នាក់ឯង ព្រោះយាយខ្ញុំមានជំងឺ

មិនអាចដើរបានៗ ម្យ៉ាងទៀត គាត់មិនមានអ្វីសម្រាប់ដឹកយាយខ្ញុំរត់ទៅជាមួយគ្នា។ ម្តាយខ្ញុំបានរត់ទៅរស់នៅភូមិកន្ទួត ឃុំជាំតាម៉ៅ ក្រោយមកទើបគាត់មកមេមត់ ជួបខ្ញុំ និងរស់នៅមេមត់ជាមួយគ្នា។ ខ្ញុំនៅមេមត់បានមួយឆ្នាំ ក៏រត់មករស់នៅភូមិត្រពាំងឫស្សី ឃុំរូង។ នៅទីនោះ យើងគ្មានផ្ទះសំបែងឡើយ គឺសុំអ្នកភូមិជ្រកកោនបណ្តោះអាសន្ន។ បន្ទាប់មកយើងបានចាកចេញពីភូមិត្រពាំងឫស្សី ឃុំរូង ត្រឡប់មកភូមិលាជក្រោមវិញ។ ក្នុងឆ្នាំ១៩៧៤ ខ្ញុំ និងម្តាយបានរស់នៅផ្ទះជាមួយឪពុកមា ធ្វើស្រែចម្ការដាំស្រូវ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកដល់ក្នុងភូមិ និងបានចាត់តាំង ខ្ញុំ និងអ្នកភូមិឲ្យធ្វើការងារស្រែចម្ការប្រវាស់ដៃ។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានចាត់តាំងអ្នកភូមិ និងខ្ញុំហូបបាយរួមគ្នា។ នៅពេលនោះខ្ញុំមានអាយុ២៥ឆ្នាំ ត្រូវខ្មែរក្រហមចាត់តាំងឲ្យធ្វើការងារនៅក្នុងកងចល័ត។ យុវជនយុវនារីដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ ត្រូវជ្រើសរើសឲ្យធ្វើការងារនៅក្នុងកងចល័តទាំងអស់។ កាលនោះប្រធានសហករណ៍នៅក្នុងភូមិលាជក្រោមមានឈ្មោះខេង។ ក្រោយមកខ្មែរក្រហមបានបញ្ជូនកងចល័តខ្ញុំទៅធ្វើស្រែនៅស្បែកគឺ ឃុំកណ្តុរជ្រុំ ស្រុកពញាក្រែក។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានបញ្ជូនកងចល័តខ្ញុំចេញពីភូមិស្បែកគឺទៅលើកដីធ្វើទំនប់នៅបឹងកញ្ចប់។

ខ្ញុំនៅក្នុងក្រុមទី២។ ពេលនោះមិនមានអាហារការហូបចុកគ្រប់គ្រាន់ទេ មានតែបបរលាយជាមួយពោតតែប៉ុណ្ណោះ។ ដោយសារតែអង្គការខ្មែរក្រហមឃើញខ្ញុំប្រឹងប្រែងធ្វើការ និងមិនសូវចេះមាត់កនោះ ខ្មែរក្រហមបានអនុញ្ញាតឲ្យខ្ញុំមកដាំបាយឲ្យសមាជិកក្នុងកងចល័តហូបវិញ។ ចាប់ពីពេលនោះមកខ្ញុំមិនបានទៅលើកភ្លឺស្រែ និងទំនប់ទៀតឡើយ។ នៅពេលលើកទំនប់ក៏មានសមាជិកកងចល័តឈឺស្លាប់ពីព្រោះមិនមានពេទ្យ និងថ្នាំព្យាបាលត្រឹមត្រូវ។ នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានបញ្ជូនមកលើកភ្លឺស្រែនៅភូមិតាម៉ៅ ឃុំជាំតាម៉ៅ។ ក្រុមខ្ញុំជាអ្នកលើកដី ចំណែកក្រុមប្រុសៗជាអ្នកកាប់ដី។ បន្ទាប់មក ខ្មែរក្រហមបានជម្លៀសខ្ញុំ និងអ្នកភូមិជាច្រើនទៀតទៅនៅភូមិអាលួច ស្រុកស្នួល និងបន្តទៅនៅសម្បុកសំបូរ ខេត្តក្រចេះ។ នៅទីនោះមានការលំបាកខ្លាំងណាស់ ធ្វើការធ្ងន់ និងមិនមានអាហារហូបចុកគ្រប់គ្រាន់។ ចុងក្រោយ ខ្ញុំ និងអ្នកភូមិត្រូវបានដឹកតាមកាណូតពីខេត្តក្រចេះទៅស្រុកស្ទឹងត្រង់ និងបន្តទៅរស់នៅស្រុកចម្ការលើ។ នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមចូលមកដល់ប្រទេសកម្ពុជា ទើបខ្ញុំបានរួចផុតពីសេចក្តីស្លាប់ និងបានត្រឡប់មករស់នៅស្រុកកំណើតវិញ។

## ៣) ទន់ ញ៉ោះ កងចល័តលើកទំនប់ទឹកប្រឡាយ



ទន់ ញ៉ោ អាយុ៧៧ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិលាជក្រោម ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទន់ ញ៉ោ ភេទប្រុស អាយុ៧៧ឆ្នាំ មានស្រុកកំណើតនៅភូមិ ឆ្កក់កណ្តាល ឃុំដារ ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃរស់នៅភូមិលាជក្រោម ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ទន់ ញ៉ោ បានរៀបរាប់ថា៖ «ខ្ញុំមានឪពុកឈ្មោះ ទន់ និងមានម្តាយឈ្មោះ ទឹម។ ខ្ញុំមានបងប្អូន ៣នាក់ ស្រី១ នាក់ និងប្រុស២នាក់។ ខ្ញុំមានប្រពន្ធឈ្មោះ ឡាក បុិ អាយុ៥៥ឆ្នាំ និងមានកូន៩ នាក់ ស្រី៥ នាក់ និងប្រុស ៤ នាក់។

កាលពីក្មេង ខ្ញុំរៀនបន្តិចបន្តួចនៅតាមផ្ទះ ពីព្រោះអត់ទាន់មានសាលារៀន។ ខ្ញុំរៀបការនៅឆ្នាំ១៩៧០។ កាលខ្ញុំអាយុ១៨ឆ្នាំមានសង្គ្រាមរវាងកងទ័ពវៀតកុង និងទាហានសហរដ្ឋអាមេរិក និងមានការទម្លាក់គ្រាប់បែកធ្វើឲ្យខូចខាតទ្រព្យសម្បត្តិនៅក្នុងភូមិ។ នៅពេលនោះឪពុកខ្ញុំបានត្រូវគ្រាប់ផ្លោងត្រូវចំកជើង។ គាត់បានស្លាប់បន្ទាប់ពីបញ្ជូនទៅមន្ទីរពេទ្យបាន ២ថ្ងៃ ពីព្រោះនៅមន្ទីរពេទ្យគ្មានពេទ្យប្រចាំការ និងព្យាបាលអ្នកជំងឺ។

ក្រោយមកទៀតខ្មែរក្រហមបានចូលក្នុងភូមិរបស់ខ្ញុំ ខ្មែរក្រហមបានឲ្យអ្នកភូមិធ្វើស្រែប្រវាស់ដៃនិងមួយរយៈក្រោយមកខ្មែរក្រហមបានឲ្យអ្នកភូមិហូបរួម។ កាលនោះមានប្រជាជនដែលជម្លៀសមកពីភ្នំពេញមកធ្វើការនៅភូមិរបស់ខ្ញុំនិងធ្វើស្រែចម្ការដូចអ្នកភូមិដទៃទៀតដែរ។ ប្រធានឃុំជាំឈ្មោះ ម៉ន, តា យន់, បង ផល។ ប្រជាជនថ្មី ដែលជម្លៀសមកពីភ្នំពេញអ្នកខ្លះត្រូវខ្មែរក្រហមយកទៅរៀនសូត្រ ខ្លះទៀតស្លាប់ ចំណែកប្រធានឈ្លបឈ្មោះ យឹម។ នៅឆ្នាំ១៩៧៦ ឬ១៩៧៧ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យទៅលើកទំនប់ លើកប្រព័ន្ធភ្លឺស្រែនៅបឹងក្រចាប់។ ចំណែកប្រពន្ធខ្ញុំមិនបានទៅជាមួយខ្ញុំទេ គឺនៅធ្វើស្រែចម្ការនៅស្រុកកំណើតជាមួយកូនៗ។ ពេលនៅបឹងក្រចាប់ ការហូបចុកមិនគ្រប់គ្រាន់ទេ។

នៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ ខ្មែរក្រហមជម្លៀសខ្ញុំទៅស្នួល រយៈពេល ៤ទៅ៥ខែ ក៏បន្តជម្លៀសទៅថ្មក្រែ ខេត្តក្រចេះ។ បន្ទាប់មកទៀត ខ្មែរក្រហមជម្លៀសខ្ញុំទៅស្រុកស្ទឹងត្រង់ និងស្រុកចម្ការលើ។ នៅចម្ការលើមិនបានប៉ុន្មានផង ក៏មានការប្រកាសតាមយន្តហោះឲ្យត្រឡប់ទៅស្រុកវិញ។ ខ្ញុំក៏ត្រឡប់មកស្រុកវិញ ផ្ទះរបស់ខ្ញុំបាក់បែកខូចខាតគ្មានសល់។ ខ្ញុំនិងប្រពន្ធបានធ្វើផ្ទះថ្មី និងធ្វើចម្ការដាំស្រូវរហូតមកដល់សព្វថ្ងៃ»។

## ៤) ជា ម៉ុង ៖ ខ្មែរក្រហមសម្លាប់ម្តាយរបស់ខ្ញុំ



ជា ម៉ុង កើតឆ្នាំ១៩៦២ បច្ចុប្បន្នរស់នៅភូមិលាជលើ ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ជា ម៉ុង ភេទប្រុស កើតឆ្នាំ១៩៦២។ ខ្ញុំមានស្រុកកំណើតនៅភូមិលាជក្រោម ឃុំជាំ ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅភូមិលាជលើ ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ជា បានស្លាប់ក្នុងសម័យ ប៉ុល ពត ដោយសារតែមានជំងឺ កាលនោះអង្គការខ្មែរក្រហមបានយកពុកខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យ ៣២ នៅខាងស្រុកអូររាំងឪ។ ចំណែកម្តាយខ្ញុំឈ្មោះ ខ្វីង ត្រូវបានខ្មែរក្រហមសម្លាប់ដោយខ្មែរក្រហមចោទថាលួចកាប់មាន់ហូបនៅផ្ទះ។ ខ្ញុំមានប្រពន្ធឈ្មោះ ទិត្យ សឿន អាយុ៦០ឆ្នាំ និងមានកូនចំនួន៦នាក់ (ស្រី១នាក់និងប្រុស៥នាក់)។ កាលពីជំនាន់សង្គមរាស្ត្រនិយម ពុកក្មេកខ្ញុំជាមេឃុំជាំ ស្រុកមេមត់។ បងប្អូនសាច់ញាតិខាងពុកក្មេកខ្ញុំសព្វថ្ងៃរស់នៅភូមិជើង និងភូមិជាំ ឃុំជាំ ស្រុកមេមត់។

ខ្ញុំមានបងប្អូនចំនួន៣នាក់ (ប្រុស១នាក់ និងស្រី ២នាក់)។ ខ្ញុំជាកូនទី៣នៃគ្រួសារ។ បងខ្ញុំពីរនាក់បានស្លាប់។ បងទី១ត្រូវខ្មែរក្រហមចាត់ឲ្យធ្វើកងទ័ពខ្មែរក្រហម ក្រោយមកបានបាត់ដំណឹងគាត់រហូត។ ខ្ញុំគិតថាគាត់បានស្លាប់ បើសិននៅរស់ ច្បាស់ជាគាត់ត្រឡប់មកស្រុកកំណើតមិនខាន។ ចំណែកបងស្រីទី ២ បានស្លាប់ ដោយសារផ្ទុះគ្រាប់មីននៅក្រោយឆ្នាំ១៩៧៩ នៅស្រុកកំណើត។

ចាស់ៗ បាននិយាយតៗគ្នាថា នៅឆ្នាំ១៩៦៨ ទាហានអាមេរិកបានទម្លាក់គ្រាប់បែកនៅភូមិម៉ង់ ឃុំជាំនេះ បណ្តាលឲ្យអ្នកភូមិបានស្លាប់និងខូចខាតផ្ទះសំបែងអស់មួយចំនួនធំៗ ក្រោយមកសម្តេចសីហនុបានឲ្យសហរដ្ឋអាមេរិកសងផ្ទះ និងសងថ្លៃខូចខាតដល់អ្នកភូមិម៉ង់វិញៗ ផ្ទះទាំងនោះត្រូវបានសាងសង់អំពីឈើដំបូលប្រក់ស៊ីប្រូស៊ីម៉ង់ៗ នៅអំឡុងឆ្នាំ១៩៧០ ទាហានអាមេរិកបានទម្លាក់គ្រាប់បែកនៅភូមិលាជក្រោម និងភូមិផ្សេងៗទៀត និងទម្លាក់តាមវាលស្រែតាមចម្ការកៅស៊ូៗ មកដល់សព្វថ្ងៃមាននៅសេសសល់រណ្តៅបេ ៥២ ជាច្រើនកន្លែងៗ នៅក្នុងឆ្នាំ១៩៧០នេះដែរ គ្រួសារខ្ញុំបានរត់ចេញពីភូមិលាជក្រោម ទៅរស់នៅស្រុកមេមត់ៗ ខ្ញុំរស់នៅភូមិត្បូងវត្តទៅមុខបន្តិចភូមិម្ពោរ ទៅខាងលើភូមិខ្នងក្រពើៗ នៅស្រុកមេមត់ ទាហានសហរដ្ឋអាមេរិកសហការជាមួយទាហានធៀវគីបានប្រយុទ្ធជាមួយកងទ័ពវៀតកុងយ៉ាងខ្លាំងក្លា ពេលនោះគ្រួសារខ្ញុំបានរត់ចេញពីមេមត់ៗ កងទ័ពយៀកកុងបានបាញ់យន្តហោះធៀវគីធ្លាក់អស់មួយគ្រឿងនៅភូមិខ្នងក្រពើ និងបានធ្វើឲ្យទាហានធៀវគីស្លាប់និងរបួសជាច្រើននាក់ៗ

នៅក្នុងឆ្នាំ១៩៧០នេះដែរអ្នកភូមិបានធ្វើបាតុកម្មប្រឆាំង លន់ នល់ ដែលទម្លាក់សម្តេចឪៗ អ្នកដែលបានទៅធ្វើបាតុកម្មបាននិយាយថា ជយោ សម្តេចឪ អ្នកណាមិនទៅកាប់ចោលៗ ពេលធ្វើបាតុកម្មនោះមានមនុស្សស្លាប់ និងរបួសមួយចំនួនដែរៗ

នៅឆ្នាំ១៩៧៦ខ្ញុំបានរត់ចេញពីស្រុកមេមត់ ទៅរស់នៅខាងឃុំគគីរ ដោយសារតែមានការប្រយុទ្ធគ្នាខ្លាំងរវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាមនៅតាមព្រំដែនៗ នៅពេលនោះឪពុកខ្ញុំបានឈឺខ្មែរក្រហមមិនឲ្យយើងទៅសួរសុខទុក្ខឡើយៗ ពេលឪពុកខ្ញុំស្លាប់ សូម្បីតែឆ្អឹងក៏ខ្ញុំមិនឃើញនិងដឹងថានៅកន្លែងណាដងៗ ចំណែកម្តាយខ្ញុំត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលដោយប្រធានសហករណ៍បានចោទគាត់ថាបានកាប់មាន់ហូបដោយមិនចែកសមូហភាពៗ ក្មេងៗនិយាយថាបានឃើញម្តាយខ្ញុំចាប់មាន់ទៅស៊ីដោយសារតែឃ្លានខ្លាំងពេកៗ ព្រឹកឡើងប្រធានសហករណ៍បានមកដល់ផ្ទះខ្ញុំ និងបាននិយាយថាយកម្តាយខ្ញុំទៅរៀនសូត្រៗ ពេលនោះខ្ញុំមិនបានដឹងរឿងទេៗ ស្រាប់តែបាត់ម្តាយ ខ្ញុំក៏ទៅសួរអ្នកភូមិហើយអ្នកភូមិប្រាប់ថាខ្មែរក្រហមចាប់យកទៅរៀនសូត្របាត់ហើយៗ ចាប់ពីពេលនោះមកខ្ញុំលែងបានឃើញ និងដឹងដំណឹងពីម្តាយខ្ញុំទៀត ខ្ញុំគិតក្នុងចិត្តថាខ្មែរក្រហមបានយកម្តាយខ្ញុំទៅសម្លាប់ហើយៗ

នៅឆ្នាំ១៩៧៨ខ្មែរក្រហមបានជម្លៀសខ្ញុំឲ្យទៅរស់នៅភូមិទ្រាស់ ឃុំសរព្រះច័ន្ទ ស្រុកពារាំង ខេត្តព្រៃវែងៗ នៅទីនោះខ្ញុំត្រូវខ្មែរក្រហមចាត់តាំងឲ្យខ្ញុំជាន់រហាត់ទឹក ប៉ុន្តែដោយសារតែខ្ញុំមិនធ្លាប់ធ្វើការងារនេះពីមុនមក ខ្ញុំបានសុំខ្មែរក្រហមទៅមើលក្របីវិញៗ នៅចុងឆ្នាំ១៩៧៨ ពេលកងទ័ពមជ្ឈិមនិងកងទ័ព ០៩ កំពុងប្រយុទ្ធគ្នាខ្លាំងនោះ ខ្ញុំជាប់នៅខាងទន្លេ ពីព្រោះទឹកទន្លេមេគង្គបានឡើងខ្លាំងៗ នៅឆ្នាំ១៩៧៩ ប្រទេសជាតិត្រូវបានរំដោះ ខ្ញុំបានត្រឡប់មកនៅស្រុកកំណើតនៅភូមិលាជក្រោមវិញៗ

## ៥) ស៊ិត ឌុយ



ស៊ិត ឌុយ អាយុ ៦៨ឆ្នាំ បច្ចុប្បន្នរស់នៅភូមិតាម៉ៅ ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំៗ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ស៊ិត ឌុយ ភេទប្រុស អាយុ ៦៨ឆ្នាំ មានស្រុកកំណើតនៅភូមិតាពួកចាស់ ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម បច្ចុប្បន្នរស់នៅភូមិតាម៉ៅ ឃុំ

ដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឪពុកខ្ញុំឈ្មោះ ផែ ស៊ិត បានស្លាប់ដោយជំងឺក្រោយឆ្នាំ១៩៧៩ ឯម្តាយខ្ញុំឈ្មោះ ខ្លុប បានស្លាប់ដោយជំងឺប្រហែលបានជាង១០ឆ្នាំមុន។ ខ្ញុំមានប្រពន្ធឈ្មោះ យ៉ោយ ហឿន និងមានកូនចំនួន៩នាក់ (ស្រី៤នាក់ និងប្រុស៥នាក់) សព្វថ្ងៃរៀបការបាន៦នាក់ហើយ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់ (ស្រី២នាក់ និងប្រុស៣នាក់) បងប្អូនខ្ញុំ៤នាក់បានស្លាប់ដោយសារគ្រាប់ ១២,៧ ក្នុងសម័យអាមេរិកមកធ្វើបន្ទាយនៅតាមវាលស្រែក្នុងភូមិតាម៉ៅ ដើម្បីស្វែងរកកងទ័ពយៀកកុង។ ពេលទាហានអាមេរិកបាញ់គ្រាប់១២,៧ នោះបានត្រូវមនុស្សនិងផ្ទះសម្បែងខូចខាត។ ទាហានអាមេរិកមិនដែលចូលមកនៅក្នុងភូមិទេ គឺមានតែពួកយៀកកុង ដែលបានចូលមករកទិញ មាន់ ទា។ វៀតកុងភាគច្រើនចូលក្នុងភូមិនៅវេលាម៉ោង៥ពេលល្ងាច។ ទាហានអាមេរិករាប់រយនាក់បានមកបោះបន្ទាយនៅវាលស្រែក្នុងភូមិតាម៉ៅរយៈពេលប្រមាណ ៣ខែ ទើបដកទ័ពចេញទៅនៅខាងភូមិតាអឹមវិញ។ នៅភូមិតាអឹម ជិតមួយខែទើបបន្តទៅតាំងបន្ទាយនៅភូមិទូលគ្រួស ឃុំដាំតាម៉ៅ។ ពេលទាហានអាមេរិកវាយជាមួយកងទ័ពយៀកកុង គ្រាប់កាំភ្លើងអាមេរិកបានមកទម្លុះដើមដូង និងផ្ទះខ្ញុំធ្លាយពីម្ខាងទៅម្ខាងទៀត។ ដើមដូងនោះនៅរស់ដល់សព្វថ្ងៃនោះ។ ក្រោយមក ខ្ញុំលែងបានឃើញទាហានអាមេរិកនិងកងទ័ពយៀកកុងទៀតហើយ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកដល់ភូមិខ្ញុំ និងបានចាត់ឲ្យប្រជាជនធ្វើការងារប្រវាស់ដៃ និងដាំបាយហូបនៅតាមផ្ទះនៅឡើយ។ នៅចុងឆ្នាំ១៩៧៥ ខ្ញុំឃើញខ្មែរក្រហមជម្លៀសប្រជាជនថ្មី ឬប្រជាជន១៧មេសា មករស់នៅភូមិតាម៉ៅ ឃុំដាំតាម៉ៅ។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានឲ្យប្រជាជនទាំងអស់ហូបបាយរួម រួមទាំងគ្រួសារខ្ញុំដែរ។ ចំណែកផលស្រូវអង្ករធ្វើបានត្រូវយកទៅដាក់រួមទាំងអស់ សូម្បីតែរបស់របរប្រើប្រាស់ដូចជាឆ្នាំង ចាន សត្វគោ ក្របី រទេះ ក៏ខ្មែរក្រហមឲ្យខ្ញុំដាក់ជាសមូហភាពទាំងអស់។ បើយើងមិនយករបស់របរទៅដាក់រួមទេខ្លាចខ្មែរក្រហមអត់ឲ្យបាយហូប។ ខ្ញុំខ្លាចខ្លាំងជាងគេ គឺខ្លាចខ្មែរក្រហមយកទៅសម្លាប់ចោល។ ខ្ញុំឮអ្នកភូមិនិយាយថា គណៈឃុំដាំតាម៉ៅឈ្មោះ តាផែ ត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់ចោលនៅភូមិកន្ទួត ឃុំដាំតាម៉ៅ។ ដោយសារការហូបចុកមិនគ្រប់គ្រាន់ មេភូមិមួយចំនួនបាននាំគ្នាទៅលួចស្រូវពីជង្រុក សហករណ៍យកទៅលាក់នៅក្នុងព្រៃឬស្សីដើម្បីទុកហូប។ ខ្ញុំបានយកអង្ករទៅទុកក្នុងផ្ទះខ្លះ តែត្រូវលាក់ឲ្យជិតកុំឲ្យខ្មែរក្រហមមានការសង្ស័យ។ បើសិនខ្មែរក្រហមចាប់បានគេឲ្យយើងទៅរៀនសូត្រហើយ។

នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវជម្លៀសចេញពីភូមិដាំតាម៉ៅទៅនៅភូមិទោល ស្រុកស្នួល ខេត្តក្រចេះ។ ខ្ញុំនៅភូមិទោលបានរយៈពេលប្រហែល៤ទៅ៥ខែ ទើបខ្មែរក្រហមជម្លៀសខ្ញុំទៅនៅភូមិអាលូចទៀត។ នៅភូមិអាលូចមានមនុស្សស្លាប់ច្រើនណាស់ ភាគច្រើនពួកគាត់ស្លាប់ដោយសារអត់បាយហូប។ នៅទីនោះខ្មែរក្រហមប្រើគោឲ្យបែនស្រូវ ដោយដឹកគោឲ្យឡើងលើពំនូកស្រូវរួចគោដើរជាន់ឲ្យជ្រុះគ្រាប់ស្រូវពីដើម។ ចុងក្រោយខ្ញុំត្រូវខ្មែរក្រហមដឹកតាមកាណូតពីខេត្តក្រចេះទៅស្រុកស៊ឹងត្រង់ និងបន្តទៅរស់នៅស្រុកចម្ការលើ។ ខ្ញុំនៅចម្ការលើបានមួយរយៈខ្ញុំក៏បានឃើញយន្តហោះហោះនៅលើមេឃ ហើយបានប្រកាសឲ្យប្រជាជនត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញ។ ខ្ញុំបានធ្វើដំណើរមកតាមកំពង់ចាមឡើងសាឡាងឆ្លងមកខាងទន្លេបិទ។ ខ្ញុំដើររហូតមកដល់ស្រុកមេមត់វិញ។ បន្ទាប់មក ខ្ញុំបានចេញពីមេមត់បន្តមកភូមិខ្ញុំវិញ ពេលដល់ភូមិគ្មានផ្ទះសម្បែងទេ ព្រោះភ្លើងឆេះនិងបាក់បែកខូចខ្ទីគ្មានសល់។

## ៦) ប៊ិន ឆក ៖ ប្រធានភូមិរបបខ្មែរក្រហម



ប៊ិន ឆក អាយុ៧១ឆ្នាំ សព្វថ្ងៃរស់នៅ ភូមិថ្នល់កែង ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ប៊ិន ឆក ភេទប្រុស អាយុ៧១ ឆ្នាំ។ មានស្រុកកំណើតនៅភូមិថ្នល់កែង ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃរស់នៅភូមិថ្នល់កែង ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ទូច ប៊ិន និងម្តាយ អ៊ុន អៀន ខ្ញុំមានបងប្អូន ៩ នាក់ ស្រី៣ នាក់ ប្រុស៧ នាក់។ ខ្ញុំមានប្រពន្ធឈ្មោះ គុយ ជូ អាយុ៦៨ឆ្នាំ ខ្ញុំមានកូន ៧ នាក់ ស្រី៣ នាក់ ប្រុស៤ នាក់។ កាលពីសម័យមុនភូមិរបស់ខ្ញុំមានមនុស្ស ១០០គ្រួសារតែប៉ុណ្ណោះ មិនសូវមានមនុស្សច្រើនរស់នៅដូចសព្វថ្ងៃនេះទេ។

កាលពីខ្ញុំនៅក្មេង ខ្ញុំបានរៀនបន្តិចបន្តួចនៅសាលាវត្តកន្ទួត គឺចប់ត្រឹមថ្នាក់ទី១០ចាស់។ ក្រោយមកខ្ញុំបានបួសរៀន ខ្ញុំចេះអាន សរសេរខ្លះៗ បន្ទាប់មក ខ្ញុំឈប់រៀនព្រោះមានជំងឺ។ នៅឆ្នាំ១៩៧០ មានរដ្ឋប្រហារទម្លាក់សម្តេចព្រះសីហនុ ខ្ញុំបានទៅចូលរួមធ្វើបាតុកម្ម ដើម្បីទាមទារសម្តេចឪ មកកាន់អំណាចវិញនៅទីរួមស្រុកមេមត់។ ម្នាក់ៗមានដំបងជាប់ដៃ ប៉ុន្តែមិនមានកាំភ្លើងទេ។ យើងបានរើសអង្ករមកសម្រាប់ដាំបាយហូបទៀតផង។ ពេលធ្វើបាតុកម្មរយៈពេល ៤ថ្ងៃនោះ មានប្រជាជនរបួសច្រើន បន្ទាប់មកអ្នកភូមិបានត្រឡប់មកផ្ទះវិញរៀងៗខ្លួន។

ខ្ញុំបានរៀបការនៅឆ្នាំ១៩៧០។ កាលនោះឪពុកក្មេករបស់ខ្ញុំបានរៀបចំសែនព្រេនខ្ញុំ និងប្រពន្ធទាំងយប់។ ឆ្នាំ១៩៧១ មានការទម្លាក់គ្រាប់បែកតាមព្រៃ។ ពេលនោះគ្មានប្រជាជនត្រូវរបួសទេ ព្រោះប្រជាជននាំគ្នារត់ចូលរណ្តៅ។ អាមេរិកតាមរកយៀកកុង បើទាហានយៀកកុងរត់ចូលភូមិ គឺទាហានអាមេរិកបានចូលមកចាប់យៀកកុងដល់ក្នុងភូមិ។ ក្រោយមក ការទម្លាក់គ្រាប់បែកបានបញ្ចប់ទៅ ស្រាប់តែមានខ្មែរក្រហមចូលមកដល់ក្នុងភូមិតែម្តង។ នៅឆ្នាំ១៩៧៣ ខ្មែរក្រហមតម្រូវឲ្យប្រជាជននៅតាមភូមិធ្វើស្រែប្រវាស់ដៃ។ កាលនោះ គណៈស្រុកត្រមូង ឈ្មោះ ស្រេង គណៈឃុំជាំតាម៉ៅ ឈ្មោះ នួប វីល្ល, ឡាច។ នៅឆ្នាំ១៩៧៣ ខ្ញុំត្រូវបានរើសឲ្យធ្វើប្រធានភូមិ។ កាលនោះ ខ្មែរក្រហមបានកាន់កាប់ភូមិរបស់ខ្ញុំទាំងមូលហើយ។

នៅឆ្នាំ១៩៧៦ អ្នកភូមិត្រូវបានតម្រូវឲ្យហូបរួម។ នាពេលនោះមានប្រជាជន១៧ មេសា ជម្លៀសមករស់នៅក្នុងភូមិរបស់ខ្ញុំដែរ។ ប្រជាជនថ្មីធ្វើការងារ និងហូបបាយដូចប្រជាជនមូលដ្ឋានដែរ។ កាលនោះមានប្រជាជន១៧ មេសាចំនួន ១០គ្រួសារ មានអ្នកខ្លះមកពីស្រុកកោះសូទិន ដូចជាឈ្មោះ រេក ធ្វើពេទ្យ អ្នកមកពីភ្នំពេញ មានឈ្មោះ សុង ជាពីឡុតបើកយន្តហោះ ត្រូវបានខ្មែរក្រហមចាប់យកទៅវាយចោល និងមានគ្រួសារមួយទៀតជម្លៀសមកនៅភូមិជាំតាម៉ៅ ឈ្មោះ បូរ៉ាវី ជាតួកុន មានប្តីឈ្មោះ ឈឿន និងមានកូនមួយ ត្រូវបានខ្មែរក្រហមយកទៅវាយចោលដែរ។ ចំណែកប្តីឈ្មោះ ឈឿន បានស្លាប់ដោយសារជំងឺ។ សម័យនោះ មានការងារផ្នែកកសាង ផ្នែកសន្តិសុខ ផ្នែកសង្គមកិច្ច ផ្នែកសេដ្ឋកិច្ច និងវប្បធម៌។ ក្នុងរបបខ្មែរក្រហមមានសាលាបង្រៀនសិស្សដែរ តែមិនមានគ្រូ និងសិស្សមករៀនបានជិតដល់ទេ។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំជាប្រធានភូមិ គឺជាអ្នកដឹកនាំប្រជាជនឲ្យធ្វើស្រែ ដាំបន្លែ និងធ្វើការពលកម្មផ្សេងៗទៀត។ ខ្មែរក្រហមបានបញ្ជាឲ្យប្រធានភូមិចាត់ចែងដាំបបរសម្រាប់ប្រជាជនហូបជំនួសបាយ។

ប្រជាជនហូបមិនគ្រប់គ្រាន់ ខ្ញុំបានលួចដាំបាយឲ្យអ្នកភូមិហូប ដោយមិនខ្លាចខ្មែរក្រហមឃើញឡើយ។ នៅអំឡុងពេលនោះ មានមន្ទីរសន្តិសុខឃុំជាំតាម៉ៅ នៅភូមិថ្នល់កែង។ តួនាទីមេភូមិក្នុងមួយសប្តាហ៍ត្រូវប្រជុំជាមួយប្រធានឃុំចំនួន ២ដង រឿងការងារធ្វើស្រែ និងកសិកម្មផ្សេងៗទៀត។ ខ្ញុំធ្វើប្រធានភូមិពីឆ្នាំ១៩៧៣ រហូតដល់ឆ្នាំ១៩៧៦ ពេលនោះខ្ញុំមានកូនចំនួន២ នាក់។ នៅឆ្នាំ១៩៧៦ ។ ខ្ញុំបានចូលធ្វើកងទ័ពស្រុកត្រមូង។ ចំណែកប្រធានភូមិថ្នល់កែងថ្មីឈ្មោះ សោ ញ៉ោក។

បន្ទាប់ពីចូលធ្វើទ័ពស្រុកខ្ញុំបានធ្វើជាមេក្រុមគ្រប់គ្រងកងទ័ពចំនួន ១០នាក់។ ប្រធានយោធាស្រុកឈ្មោះ សឿន។ ខ្ញុំបានទៅហាត់រៀននៅមាត់ព្រែកឆ្លងបានរយៈពេលកន្លះខែ ខាងមជ្ឈិមបានចូលមកដល់ ក៏រំសាយពួកខ្ញុំឲ្យត្រឡប់មកផ្ទះវិញ ។ ខ្ញុំបានត្រឡប់មករកគ្រួសារនៅភូមិថ្នល់កែងវិញ។បន្ទាប់មកធ្វើជាកសិករ ធ្វើស្រែដូចអ្នកភូមិដទៃទៀតដែរ។

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសខ្ញុំ និងគ្រួសារទៅនៅភូមិទោលឃុំស្រែរនាមស្រុកស្នួល និងកាប់ឈើធ្វើរោងបាយ និងធ្វើស្រែរយៈ៣ ទៅ៤ខែ។ ឪពុករបស់ខ្ញុំស្លាប់នៅទីនោះ ព្រោះអត់អាហារ។ បន្ទាប់មកខ្មែរក្រហមបានជម្លៀសខ្ញុំ និងក្រុមគ្រួសារទៅនៅ ភ្នំព្រិចស្រុកសម្បូរ។ ចុងក្រោយខ្មែរក្រហមជម្លៀសខ្ញុំទៅថ្មក្រែជិះកាណូតទៅស្ទឹងត្រង់ និងបន្តជិះឡានទៅរស់នៅស្រុកចម្ការលើទៀត។ ពេលកងទ័ពវៀតណាមបានចូលមកដល់ប្រទេសកម្ពុជា ក៏ប្រកាសឲ្យអ្នកណានៅស្រុកណាឲ្យត្រឡប់ទៅស្រុកវិញចុះ។ ខ្ញុំ និងគ្រួសារបានធ្វើដំណើរមកកំពង់ចាមឆ្លងសាឡាងមកទន្លេបិទ និងធ្វើដំណើរដោយថ្មើរជើងរហូតដល់ស្រុកមេមត់។ បន្ទាប់ពីសម្រាកនៅស្រុកមេមត់ ២ថ្ងៃ ខ្ញុំបានបន្តដំណើរមកដល់ស្រុកកំណើត។ ខ្ញុំនិងគ្រួសារបានចាប់ផ្តើមធ្វើផ្ទះថ្មី ទៅរកគ្រាប់ស្រូវពូជដើម្បីយកមកដាំ និងធ្វើស្រែចម្ការរហូតតមកដល់សព្វថ្ងៃនេះ។

ខ្ញុំមានប្អូនប្រុសម្នាក់ឈ្មោះ ខ្មៅ ហៅ តូច សីហាធ្វើយោធានៅក្តុល មានតួនាទីជាអនុវរៈ ត្រូវខ្មែរក្រហមយកទៅវាយចោលនៅក្នុងឆ្នាំ១៩៧៧។

## ៧) នោម ចាន់៖ រត់គេចខ្លួនទៅវៀតណាមក្នុងសម័យខ្មែរក្រហម



នោម ចាន់ អាយុ៦១ឆ្នាំ សព្វថ្ងៃខ្ញុំរស់នៅភូមិលាជក្រោម (ហៅភូមិថ្នល់ថ្មី) ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ នោម ចាន់ ភេទស្រី អាយុ៦១ឆ្នាំ មានស្រុកកំណើតនៅភូមិលាជក្រោម ឃុំជាំ ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិលាជក្រោម (ហៅភូមិថ្នល់ថ្មី) ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ណុប និងមានម្តាយឈ្មោះ ជូ ។ ខ្ញុំមានបងប្អូន២នាក់ ស្រី១នាក់ និង ប្រុស១នាក់។ ខ្ញុំមានប្តីឈ្មោះ ប៊ុន ធឿន សព្វថ្ងៃមានអាយុ៦៣ឆ្នាំ។

កាលពីខ្ញុំនៅក្មេងៗ ខ្ញុំមិនបានរៀនសូត្រទេ ព្រោះនៅក្នុងភូមិលាជក្រោម និងភូមិនៅក្បែរៗមានសង្គ្រាមរវាងទាហានសហរដ្ឋអាមេរិក និងកងទ័ពវៀតកុង។ នៅពេលទាហានសហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកមកលើភូមិរបស់ខ្ញុំ ហើយខ្ញុំមិនរៀនទេ។ ឪពុកខ្ញុំបានស្លាប់តាំងពីខ្ញុំនៅក្មេង ខ្ញុំរស់នៅតែជាមួយម្តាយ។ ខ្ញុំបានរត់គេចគ្រាប់កាំភ្លើង គ្រាប់បែកជាមួយម្តាយ មានពេលខ្លះ ខ្ញុំអត់បាយ អត់ទឹក ក៏មានពីព្រោះមានគ្រាប់ផ្លោងខ្លាំងពេក។ នៅអំឡុងឆ្នាំ១៩៧៣-១៩៧៤ សង្គ្រាម និងទម្លាក់គ្រាប់បែកបានបញ្ចប់ ខ្ញុំនិងម្តាយបានវិលត្រឡប់មករស់នៅ

ភូមិលាជក្រោម និងបានធ្វើស្រែចម្ការធម្មតា ប៉ុន្តែមិនបានប៉ុន្មានផង ក្នុងភូមិរបស់ខ្ញុំមានសង្គ្រាមម្តងទៀត។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកគ្រប់គ្រងក្នុងភូមិរបស់ខ្ញុំ។ ខ្ញុំនិងម្តាយ ត្រូវបានអង្គការខ្មែរក្រហមបង្ខំឲ្យធ្វើស្រែចម្ការរួម និងហូបរួមជាមួយអ្នកភូមិផ្សេងទៀត។ នៅពេលនោះ អង្គការខ្មែរក្រហមមិនបានឲ្យប្រជាជនហូបចុកគ្រប់គ្រាន់ឡើយ។ នៅដើមឆ្នាំ១៩៧៦ ខ្ញុំនិងម្តាយបានរត់ភៀសខ្លួនទៅរស់នៅប្រទេសវៀតណាម។ ប៉ុន្តែប្រសិនខ្មែរក្រហមបានដឹងនឹងចាប់យកទៅវាយចោលមិនខាន។ ពេលរស់នៅប្រទេសវៀតណាម ខ្ញុំនិងម្តាយ ត្រូវស៊ីឈ្នួលធ្វើជាកម្មករឲ្យថៅកែជាជនជាតិវៀតណាមដើម្បីបានប្រាក់យកមកទិញអង្ករម្ហូប និងរបស់របរប្រើប្រាស់ផ្សេងៗទៀត។

នៅឆ្នាំ១៩៨០ ខ្ញុំនិងម្តាយបានវិលត្រឡប់មកស្រុកខ្មែរនិងមករស់នៅស្រុកកំណើតវិញ។ ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំនៅក្នុងឆ្នាំ១៩៨០។ កាលនោះប្តីខ្ញុំជាប៉ូលីស តែក្រោយមកប្តីរបស់ខ្ញុំបានលាឈប់ពីប៉ូលីសមកធ្វើស្រែដាំស្រូវជាមួយក្រុមគ្រួសាររហូតមកដល់សព្វថ្ងៃ។

## ៨) ទិត្យ សៀម



ទិត្យ សៀម ភេទស្រី អាយុ៧៤ ឆ្នាំ សព្វថ្ងៃរស់នៅភូមិលាជលើ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ទិត្យ សៀម ភេទស្រី អាយុ៧៤ ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅភូមិលាជលើ ឃុំដាំ ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិលាជលើ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឪពុកឈ្មោះ ទិត្យ និងមានម្តាយឈ្មោះ សណ្ហ ខ្ញុំមានបងប្អូន៩ នាក់ ស្រី៤ នាក់ ប្រុស៥ នាក់។ ប្តីរបស់ខ្ញុំឈ្មោះ យន្ត អ៊ុច ខ្ញុំមានកូន៧ នាក់ ស្រី៤ នាក់ និងប្រុស៣ នាក់។

នៅពេលខ្ញុំអាយុ១០ឆ្នាំ ខ្ញុំបានចូលរៀននៅសាលាលាជលើ ដោយចាប់ផ្តើមពីថ្នាក់ទី១២ចាស់។ កាលនោះមានកូនសិស្សច្រើនណាស់បានមករៀននៅសាលាលាជលើ។ កូនសិស្សត្រូវរៀនពេញមួយថ្ងៃគឺត្រូវរៀនទាំងព្រឹក និងល្ងាច ហើយព្រះសង្ឃជាអ្នកបង្រៀនកូនសិស្សទាំងលេខនិងអក្សរ។ ខ្ញុំឈប់រៀននៅអាយុ១៧ឆ្នាំ បន្ទាប់មកខ្ញុំរៀបការ និងធ្វើស្រែចម្ការ។ នៅពេលខ្ញុំអាយុ២០ឆ្នាំក្នុងភូមិមានសង្គ្រាមរវាងកងទ័ពវៀតកុង និងទាហានសហរដ្ឋអាមេរិក និងមានទម្លាក់គ្រាប់បែកជាច្រើនមកលើភូមិ។ កាលនោះខ្ញុំមានកូន១ ខ្ញុំនាំកូនរត់ពួនក្នុងរណ្តៅគេចពីគ្រាប់ផ្លោង។ បន្ទាប់មកខ្ញុំ និងក្រុមគ្រួសារបានភៀសខ្លួនទៅនៅមេមត់ ហើយអាមេរិកបានមកចែកអង្ករម្នាក់១០គីឡូ។ នៅពេលនោះមានវៀតកុងពួនតាមព្រៃព្រោះខ្លាចទាហានអាមេរិកឃើញ។ ខ្ញុំបានរត់គេចពីគ្រាប់ផ្លោងទៅនៅភូមិអំបិលបាន៣យប់ក៏មានគ្រាប់ផ្លោងទៅដល់ទីនោះទៀត។ បន្ទាប់មកទៀតខ្ញុំរត់ទៅ ខ្វាយ ក្រោយមកខ្ញុំទៅនៅក្រុមហ៊ុនកៅស៊ូប៉ា នៅទីនោះខ្ញុំបានស្លាប់ប្អូនម្នាក់ដោយសារឈឺមិនបានព្យាបាលត្រឹមត្រូវ។ ក្រោយមកទៀត ខ្ញុំទៅនៅស្រែសោមបានប៉ុន្មានថ្ងៃ ទើបត្រឡប់មកស្រុកវិញ។ ពេលមកដល់ស្រុកវិញផ្ទះសម្បែងត្រូវឆេះអស់ ខ្ញុំនិងប្តីបានធ្វើខ្ទមតូចមួយសម្រាប់រស់នៅ និងបានបេះបន្លែបន្ការនៅជិតផ្ទះ ដូចជា ដំឡូងចេកយកមកស្ងោរហូប។













# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវបុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!















# វេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារខ្មែរក្រហមខេត្តកំពង់ចាម

*មេន នឿន*



សិស្សានុសិស្សថ្នាក់ទី១២មកពីវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប ទស្សនាការដាក់តាំងសម្ភាររបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តកំពង់ចាម។ (ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅរសៀលថ្ងៃច័ន្ទ ទី៣ ខែមេសា ឆ្នាំ២០២២ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តកំពង់ចាម និងការចុះទស្សនកិច្ចទៅកាន់ទីតាំងចេតីយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម ស្ថិតនៅភូមិចម្ការសាមសិប ឃុំគគរ ស្រុកកំពង់សៀម។ សិស្សថ្នាក់ទី១២ ចំនួន២០នាក់ ដឹកនាំដោយអ្នកគ្រូ សៅ វឌ្ឍនា និងអ្នកគ្រូ យឿន ស្រីភ័ណ បង្រៀនមុខវិទ្យាប្រវត្តិវិទ្យានៃវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប នៅស្រុកបាធាយ បានចូលរួមកម្មវិធីវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងដំណើរទស្សនកិច្ចនៅទីតាំងចេតីយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម។



សិស្សានុសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប ទស្សនាពិព័រណ៌រូបថត នៅការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តកំពង់ចាម។ (ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

លោក ផេង ពង្ស៊រ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តកំពង់ចាម។ (ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



ការបង្កើតឡើងនូវវេទិកាថ្នាក់រៀននេះ ធ្វើឡើងដើម្បីជំរុញនិងបង្កើនការយល់ដឹងអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងការស្វែងយល់អំពីទ្រឹស្តី និងនិយមន័យអំពើប្រល័យពូជសាសន៍ដល់សិស្សានុសិស្សចូលរួម។ បន្ថែមលើនេះទៀត វេទិកាថ្នាក់រៀននេះបានជំរុញសិស្សានុសិស្សឲ្យធ្វើការពិភាក្សា និងការពិចារណា ដើម្បីស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ វេទិកាថ្នាក់រៀននេះបានបង្កើតឡើងកម្មវិធីសិក្សារួមមាន៖ ការទស្សនាពិព័រណ៍រូបថត, ការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ, និងការចុះទស្សនកិច្ចទៅកាន់ទីតាំងចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហមបង្កើតឡើងដោយសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

សិស្សចូលរួមទាំងអស់បានចំណាយអស់រយៈពេល១៥នាទីដើរទស្សនាពិព័រណ៌រូបថត និងសម្ភារដែលរក្សាទុកដោយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីឈ្វេងយល់អំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ បន្ទាប់ពីការដើរទស្សនាការដាក់តាំងបង្ហាញនេះបានបញ្ចប់ សិស្សានុ-សិស្សបានទស្សនាវីដេអូឯកសារ អំពីការដាក់សម្ពោធចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម និងអ្នកស្ម័គ្រចិត្តកម្ពុជា។ ជាកិច្ចបន្ទាប់ លោក ផេង ពង្ស៊រ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងនិយមន័យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍។ បន្ទាប់ពីបទបង្ហាញត្រូវបានបញ្ចប់ សិស្សានុសិស្សទាំងអស់ទទួលបានឱកាសពិភាក្សា និងសួរដេញដោលអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ មុនពេលបញ្ចប់វេទិកាថ្នាក់រៀន ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានចែកសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)» ជាភាសាខ្មែរ បោះពុម្ពលើកទី ២ ដល់សិស្សានុសិស្សចូលរួមទាំងអស់ ទុកជាឯកសារដើម្បីសិក្សាបន្ថែមពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។



លោក គុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិចម្ការសាមសិប និយាយប្រាប់សិស្សានុសិស្សថ្នាក់ទី១២មកពីវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើបអំពីការសាងសង់ចេតិយ៍នេះឡើង និងរឿងរ៉ាវនៃការបាត់បង់ឪពុកដែលខ្មែរក្រហមចាប់យកទៅសម្លាប់នៅឆ្នាំ១៩៧៨។ (ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

កម្មវិធីបន្ទាប់ គឺជាដំណើរទស្សនកិច្ចទៅកាន់ទីតាំងចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម ដែលផ្តល់ជាវេទិកាផ្ទាល់ និងនិមិត្តរូប សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីផ្សារភ្ជាប់ប្រាស្រ័យទាក់ទង និងចែករំលែក បញ្ហាប្រឈមដែលតែងជួបប្រទះ និងដោះស្រាយ។ លោក គុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិចម្ការសាមសិប បានដឹកនាំ និងរៀបរាប់យ៉ាងលម្អិតអំពីគោលបំណងនៃការសាងសង់ចេតិយ៍នេះ, រឿងរ៉ាវកើតឡើងនៅក្នុងរបបខ្មែរក្រហម និងការបាត់បង់ឪពុកដែលត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់នៅឆ្នាំ១៩៧៨។បន្ទាប់មកសិស្សានុសិស្សបានចោទសួរចំណួរអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅភូមិចម្ការសាមសិប ក្នុងរបបខ្មែរក្រហម ក៏ដូចជាការចាប់យកឪពុករបស់លោក គុង សុភា ទៅសម្លាប់។

ជាចុងក្រោយ សិស្សានុសិស្សចូលរួមវេទិកាថ្នាក់រៀននេះ បានបង្ហាញការយល់ឃើញផ្ទាល់ខ្លួនចំពោះកម្មវិធីដូចខាងក្រោម ៖

សិស្ស **ញឹម បញ្ញារ៉ាត់** អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២-គ នៃវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប បានបញ្ចេញទស្សនៈថា “ខ្ញុំយល់ថាវេទិកាថ្នាក់រៀននេះ គឺល្អសម្រាប់ខ្ញុំដែលកំពុងរៀនថ្នាក់ទី១២។ ខ្ញុំទទួលបានចំណេះដឹងយ៉ាងច្រើនពីប្រវត្តិ-សាស្ត្រកម្ពុជាប្រជាធិបតេយ្យ តាមរយៈការទស្សនាពិព័រណ៍រូបថតដែលបង្កប់នូវរឿងរ៉ាវពីក្រោយផ្ទាំងរូបថតនីមួយៗ ការដាក់តាំងសម្ភាររបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការចុះមើលនៅទីតាំង



ញ៉ឹម បញ្ញារ៉ាត់ អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២-គ នៃវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប ទស្សនាពិព័រណ៍រូបថត នៅការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តកំពង់ចាម។ (ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ចេតិយ៍។ ខ្ញុំមានការអាណិតអាសូរដល់ជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំនឹងនាំយកចំណេះដឹងទាំងនេះទៅចែលរំលែកដល់មិត្តរួមថ្នាក់រៀនជាមួយខ្ញុំ និងសិស្សានុសិស្សរៀនថ្នាក់ផ្សេងទៀតនៅវិទ្យាល័យសម្តេចតេជោ ហ៊ុនសែន សង្កើប ទាំងអស់ឲ្យបានយល់ដឹងដូចខ្ញុំដែរ។ ជាចុងក្រោយ ខ្ញុំសំណូមពរឲ្យមានកម្មវិធីវេទិកាថ្នាក់រៀនជាបន្តបន្ទាប់ទៀត នៅតាមវិទ្យាល័យនៅខេត្តកំពង់ចាម”។



ម៉េង សីហា អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២-ខ នៃវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប ទស្សនាពិព័រណ៍រូបថត នៅការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តកំពង់ចាម។ (ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្ស **ម៉េង សីហា** អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២-ខ នៃវិទ្យាល័យសម្តេចតេជោ ហ៊ុនសែន សង្កើប ចែករំលែកការយល់ដឹងរបស់ខ្លួនពីកម្មវិធីវេទិកាថ្នាក់រៀននេះថា ៖ “ខ្ញុំទទួលបានចំណេះដឹងជាច្រើនពីវេទិកាថ្នាក់រៀននេះរួមមាន៖ ទី១- ការដឹងអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, ទី២- ការយល់អំពីនិយមន័យអំពើប្រល័យពូជសាសន៍និងវិធីសាស្ត្រទប់ស្កាត់, ទី៣- ការដឹងអំពីប្រភេទនៃឧក្រិដ្ឋកម្មឃោរឃៅ, ទី៤- ការដឹងអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, ទី៥- ការស្គាល់ទីតាំងសម្លាប់រង្គាល និងការចុះទស្សនាទីតាំងចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម។ ខ្ញុំនឹងយកចំណេះដឹងដែលខ្ញុំទទួលបានពីកម្មវិធីវេទិកានេះទៅចែករំលែកដល់មិត្តរួមថ្នាក់ និងសួរនាំគ្រួសាររបស់ខ្ញុំអំពីអ្វីដែលគាត់បានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហម”។



ដាំ ដាវី ភេទស្រី អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២-គ នៃវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប ទស្សនាពិព័រណ៍រូបថត នៅការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តកំពង់ចាម។ (ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្ស **ដាំ ដាវី** ភេទស្រី អាយុ ១៧ឆ្នាំ រៀនថ្នាក់ទី១២-គ នៃវិទ្យាល័យសម្តេចតេជោ ហ៊ុនសែន សង្កើប បានបញ្ចេញយោបល់ថា ៖ “បន្ទាប់ពីបានចូលរួមវេទិកាថ្នាក់រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និង

ចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅទីតាំងចេតិយ៍ នាងខ្ញុំយល់បានកាន់តែច្រើនពីប្រវត្តិសាស្ត្រខ្មែរក្រហមបន្ថែមទៀតទៅលើអ្វីដែលនាងខ្ញុំដឹងពីការរៀននៅសាលា និងការនិយាយប្រាប់អំពីប្រវត្តិខ្មែរក្រហមចេញពីឪពុកម្តាយរបស់នាងខ្ញុំផ្ទាល់។ នៅពេលដែលខ្ញុំបានស្តាប់លោកគ្រូ "វ៉ា ស៊ី" ធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ស្តីពីការសម្លាប់រង្គាលដែលផ្តើមចេញក្នុងអំឡុងខែមេសានេះផ្ទាល់ នាងខ្ញុំទទួលបានអារម្មណ៍ និងនឹកស្រម៉ៃថា ខ្លួនខ្ញុំកំពុងស្ថិតនៅក្នុងហេតុការណ៍នេះផ្ទាល់។ បន្ថែមលើនេះទៀត នៅពេលដែលនាងខ្ញុំឈានជើងចូលទៅក្នុងការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តកំពង់ចាម ដែលមានការរៀបចំដាក់តាំងបង្ហាញនូវរូបថត ឯកសារចាស់ៗ និងវត្ថុបន្សល់ទុកតាំងពីសម័យខ្មែរក្រហមមក ខ្ញុំសឹងតែមិនគួរឲ្យជឿនៃសភាពព្រៃផ្សៃ និងទុកលំបាកដែលបានកើតឡើងនៅពេលនោះ។ ទាំងនេះបានធ្វើឲ្យនាងខ្ញុំ និងមិត្តភក្តិទាំងអស់ ដែលមកទស្សនកិច្ចនៅទីនេះ មានអារម្មណ៍រន្ធត់ និងអាណិតអាសូរ។ ជាចុងក្រោយ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម និងក្រុមការងារដែលបានរៀបចំកម្មវិធីនេះឡើង និងជាពិសេស លោកគ្រូដែលបានបកស្រាយរាល់សំណួររបស់នាងខ្ញុំ និងមិត្តភិក្ក ដើម្បីយល់ដឹងកាន់តែច្រើនពីប្រវត្តិសាស្ត្រខ្មែរក្រហម"។



អ្នកគ្រូ សៅ វឌ្ឍនា បង្រៀនថ្នាក់ទី១២ មុខវិទ្យាសង្គម និងប្រវត្តិសាស្ត្រដឹកនាំសិស្សានុសិស្សថ្នាក់ទី១២មកពីវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប ទស្សនាពិព័រណ៍រូបថត នៅការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តកំពង់ចាម និងចេតិយ៍រំឭកដល់វិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម។ (ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្នកគ្រូ **សៅ វឌ្ឍនា** បង្រៀនថ្នាក់ទី១២ មុខវិទ្យាសង្គម និងប្រវត្តិសាស្ត្រ បានសម្តែងការអរគុណដល់ក្រុមការងារដែលបានរៀបចំកម្មវិធីវេទិកាថ្នាក់រៀននេះឡើងថា "ការបង្កើតឡើងវេទិកាថ្នាក់រៀន និងការចុះទស្សនកិច្ចនៅទីតាំងចេតិយ៍ដែលមានការសម្លាប់ប្រជាជននៅក្នុងរបបខ្មែរក្រហម គឺពិតជាសំខាន់ណាស់សម្រាប់សិស្សានុសិស្សសិក្សាឈ្វេងយល់អំពីប្រត្តិសាស្ត្រខ្មែរក្រហម។ ការដឹងអំពីប្រវត្តិសាស្ត្រ គឺដូចជាការដឹងអំពីអត្តសញ្ញាណរបស់ខ្លួនអញ្ចឹងដែរ។ ខ្ញុំសូមសំណូមពរឲ្យមានកម្មវិធីអប់រំប្រវត្តិសាស្ត្រខ្មែរក្រហមនេះជាបន្តបន្ទាប់ទៀត ដើម្បីអនុញ្ញាតឲ្យសិស្សានុសិស្សរៀននៅវិទ្យាល័យផ្សេងទៀតនៅខេត្តកំពង់ចាមមានឱកាសសិក្សាឈ្វេងយល់កាន់ច្បាស់ពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ"។

# វេទិកាប្រវត្តិសាស្ត្រគ្រួសារនៅ ស្រុកបូរីជលសារ ខេត្តតាកែវ

*សៀង កញ្ញា និង ង៉ាន់ វីន*



*ខ្លោងទ្វារសាលាស្រុកបុរីជលសារ*
*( ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា )*

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានចុះធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ នៅក្នុងស្រុកបុរីជលសារ ខេត្តតាកែវ រយៈពេលពីរថ្ងៃចាប់ពីទី២៨ ដល់ ២៥ ខែមីនា ឆ្នាំ២០២២ ។ នៅថ្ងៃទី១ វេលាម៉ោង៩ព្រឹក ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវបានទៅសាលាឃុំ គោកពោធិ៍ ដោយជួបជាមួយជំទប់ឃុំទី១ឈ្មោះ ស៊ិន បេក។ បន្ទាប់មកលោកស្មៀនឃុំបាននាំក្រុមការងារទៅជួបសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៨គ្រួសារ។ នៅថ្ងៃទី២ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារតាកែវ បានចុះជួបជាមួយ ទាហាន និងបានទៅទស្សនកិច្ចផ្ទះតាម៉ុក នៅស្រុកបូរីជលសារ។ ក្រុមការងារបានសម្ភាសន៍អ្នករស់រានមានជីវិតម្នាក់ឈ្មោះ ឃួន សន ដែលនៅចាំរឿងរ៉ាវមួយចំនួនទាក់ទងផ្ទះតាម៉ុកក្នុងស្រុកបូរីជលសារ។ ក្រុមការងារបានធ្វើដំណើរទៅកាន់ភូមិ ឡូទឹកត្រី និងបានធ្វើដំណើរបន្តទៀតទៅកាន់ព្រំដែនខ្មែរ-វៀតណាម ដោយឃើញមានដាំងសំណង់កំពុងសាងសង់ស្ពាននៅតាមព្រំដែន។

## ១. នេត ផល្លី



នេត ផល្លី អាយុ៥៩ឆ្នាំនៅភូមិជ្រៃគោកពោធិ៍ ឃុំគោកពោធិ៍ ស្រុកបុរីជលសារ ខេត្តតាកែវ (ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នេត ផល្លី អាយុ៥៩ឆ្នាំ។ នេន ផល្លី បានរៀបរាប់អំពីរឿងរ៉ាវរបស់ខ្លួនមកកាន់ក្រុមការងារដូចតទៅ៖ ខ្ញុំកើតនៅ ទីក្រុងភ្នំពេញ។ ឪពុករបស់ខ្ញុំឈ្មោះ នេត ឃុំ( ស្លាប់នៅឆ្នាំ១៩៧៣ ដោយសារការទម្លាក់គ្រាប់បែក) និងម្តាយឈ្មោះ ជីប អិន។ ខ្ញុំមានបងប្អូនបង្កើតទាំងអស់ចំនួន៦នាក់ ដែលក្នុងនោះមានបងប្អូនប្រុសចំនួន ៤នាក់ និងស្រីម្នាក់ (បងស្រីត្រូវបានខ្មែរក្រហមយកទៅសម្លាប់ដោយសារគាត់ជាអ្នកមានចំណេះដឹងពីសម័យ លន់ នល់)។ កាលពីកុមារភាពមុនរបប លន់ នល់ ខ្ញុំមិនទាន់បានរៀនសូត្រនោះទេ ដោយសារនៅក្មេងពេក ហើយស្ថានភាពស្រុកទេសមិនសូវល្អ។ រហូតមកដល់ឆ្នាំ១៩៨០ទើបខ្ញុំអាចរៀននៅសាលាបានជាប់រហូតដល់ថ្នាក់ទី៧ នៅសាលាវត្តគោកពោធិ៍ ដែលមានទីតាំងនៅឃុំគោកពោធិ៍ ស្រុកបុរីជលសា។ នៅសម័យលន់ នល់ ខ្ញុំមិនសូវដឹងអំពីព្រឹត្តិការណ៍នៅក្នុងសង្គមនោះទេ។ នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំបានបាត់បង់ឪពុកជាទីស្រឡាញ់ ដោយសារតែយន្តហោះទម្លាក់គ្រាប់បែកត្រូវចំឪពុករបស់ខ្ញុំ (គាត់ធ្វើជាទាហាន) ។

បន្ទាប់មក នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមានអាយុ១០ឆ្នាំរស់នៅ ទីក្រុងភ្នំពេញ ត្រូវបានខ្មែរក្រហមជម្លៀសឲ្យមករស់នៅតាមជនបទវិញ។ ម្តាយរបស់ខ្ញុំបាននាំកូនៗឲ្យមកស្រុកកំណើតនៅភូមិគោកពោធិ៍ ឃុំគោកពោធិ៍ ស្រុកបុរីជលសា ខេត្តតាកែវ។ នៅពេលដែលមកដល់ ខ្មែរក្រហមបានចាត់ទុកគ្រួសាររបស់ខ្ញុំជាប្រជាជនថ្មី។ ខ្ញុំត្រូវបានអង្គការចាត់ទៅនៅក្នុងកងកុមារ ដោយអង្គការប្រើឲ្យឃ្វាលគោ និងរែកដីដំបូកជាដើម។ ចំណែកម្តាយរបស់ខ្ញុំត្រូវបានអង្គការបញ្ជូនឲ្យទៅចូលទៅក្រុមដេរម្ហូបជាអ្នកដេរម្ហូក។ រីឯបងស្រីរបស់ខ្ញុំ ត្រូវបានអង្គការចាត់ទៅនៅក្នុងកងនារី តែដោយសារខ្មែរក្រហមដឹងថាបងស្រីរបស់ខ្ញុំរៀនសូត្រចេះដឹងក៏យកគាត់ទៅសម្លាប់ចោល។ អង្គការមិនអនុញ្ញាតឲ្យប្រជាជនរស់នៅជួបជុំគ្រួសារទេ គឺរស់នៅតាមកងរៀងៗខ្លួន។ ចំពោះការហូបចុកវិញគឺមិនគ្រប់គ្រាន់នោះទេ។ អង្គការប្រើឲ្យធ្វើការហួសកម្លាំង តែសំណាងល្អខ្ញុំមិនដែលឈឺ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំបានរៀនចប់ និងធ្វើការជានគរបាលឃុំហើយក៏ឡើងដំណែងជានគរបាលស្រុកតាំងពីឆ្នាំ១៩៨៦ និងចូលនិវត្តន៍នៅឆ្នាំ២០២០នេះ។ ខ្ញុំមានប្រពន្ធឈ្មោះ កែវ ស្រីមាន អាយុ ៥៦ឆ្នាំ ហើយមានកូនចំនួន៦នាក់ ក្នុងនោះមានកូនស្រី២នាក់និងកូនប្រុស៤នាក់។

## ២. សេ ហុត



សេ ហុត អាយុ៧៨ឆ្នាំ រស់នៅភូមិជ្រៃគោកពោធិ៍ ឃុំគោកពោធិ៍ ស្រុកបុរីជលសារ ខេត្តតាកែវ (ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

សេ ហុត មានអាយុ៧៨ឆ្នាំ មុខរបរជាកសិករ មានស្រុកកំណើតនៅភូមិគោកពោធិ៍ ឃុំគោកពោធិ៍ ស្រុកបូរីជលសារ ខេត្តតាកែវ។ សេ ហុត បានរៀបរាប់អំពីដំណើរជីវិតរបស់ខ្លួនថា៖ “ ខ្ញុំមានឪពុកឈ្មោះ សេ (ស្លាប់) និងម្តាយឈ្មោះ ភឿក (ស្លាប់)។ ខ្ញុំជាកូនទោលនៅក្នុងគ្រួសារ។ ខ្ញុំពុំធ្លាប់បានចូលរៀននោះទេ តាំងពីកុមារភាពរហូតមកដល់អាយុ១៦ឆ្នាំ។ ចូលដល់សម័យឥស្សរៈ បុរាណនិគមនិយមបារាំង ក្មេងៗក្នុងភូមិដែលមានអាយុប្រហែលខ្ញុំត្រូវហាត់ទាហាន នៅក្នុងភូមិគោកពោធិ៍។ ខ្ញុំបានរៀបការក្នុងឆ្នាំ១៩៦៩ មានប្រពន្ធឈ្មោះ ហ៊ួត ហុន មានអាយុ៧៨ឆ្នាំ មានស្រុកកំណើតរស់នៅឃុំអង្គកែវ ស្រុកអង្គរជ័យ ខេត្តកំពត និងមានកូនចំនួន៩នាក់ ប្រុស៨នាក់ និងស្រី៥នាក់។

នៅក្នុងសម័យ លន់ នល់ ខ្ញុំបានចូលធ្វើជាទាហាននៅខាងកើតវត្តព្រៃផ្តៅ និងចូលជាមួយសម្តេចសីហនុវាយទាហាន លន់ នល់ ។ ក្នុងអំឡុងពេលធ្វើសង្គ្រាម ខ្ញុំត្រូវអំបែងគ្រាប់របស់ទាហាន លន់ នល់ ឃ្មាត់ចំខ្នងបណ្តាលឲ្យរបួសធ្ងន់។

ក្នុងសម័យខ្មែរក្រហម ខ្ញុំត្រូវបានខ្មែរក្រហម ចាត់តាំងឲ្យធ្វើជាឈ្លប និងធ្វើស្រែ។ ខ្ញុំបានក្រោកឡើងម៉ោង៤ព្រឹក ធ្វើដំណើរមកធ្វើស្រែនៅភូមិព្រៃរុនដូចជាដកស្ទូង និងភ្ជួររាស់ជាដើម។ ក្រោយមក ខ្ញុំបានត្រឡប់មកធ្វើជាកងឈ្លបយាមអ្នកទោសនៅភូមិជើងចាប ឃុំរនាម ស្រុកទ្រាំង ខេត្តតាកែវ ដែលស្ថានភាពអ្នកទោសមានដាក់ច្រវ៉ាក់នៅនឹងកជើង ចំណែកគុកប្រក់ស្លឹកត្នោត។ អ្នកទោសហូបបបរមួយថ្ងៃពីរពេល ដូចទៅនឹងប្រជាជនក្នុងសហករណ៍ដទៃទៀតដែរ និងធ្វើការគ្មានពេលសម្រាក។ នៅចុងឆ្នាំ១៩៧៩ បន្ទាប់ពីប្រទេសត្រូវបានរំដោះពីខ្មែរក្រហម ខ្ញុំមិនមានបាត់បង់សមាជិកគ្រួសារណាម្នាក់ឡើយ។ ខ្ញុំបានត្រឡប់មករស់នៅភូមិជ្រៃគោកពោធិ៍ ឃុំគោកពោធិ៍ ស្រុកបូរីជលសារ ជាមួយគ្រួសារ និងបានប្រកបធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។



ស្ពាននៅស្រុកបុរីជលសារ
(ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ភូមិយោតកំណើតអ្នកបួស

## សំណោកបងប្អូនប្រាំនាក់

ខែឆ្នាំ និងទឹកទន្លេមិនប្រែប្រួលទេ តែព្រហ្មលិខិតនិងវាសនា ពិតជាផ្លាស់ប្តូរលើសពី៣៦០ដឺក្រេ នៅក្នុងសង្គមភក់ជ្រាំនោះ។ ពិតជាលំបាកណាស់នៃជីវិតឪពុកធ្លាប់បួសជាសង្ឃ។

ក្រោយពីការសម្រេចចិត្តមិនធ្វើអត្តឃាត ហើយងាកមកដោះស្រាយដើម្បីជីវិតគ្រួសារឲ្យរួចផុតពីការយកទៅសម្លាប់ក្រោមអំណាចកម្មាភិបាលខ្មែរក្រហមក្នុងការចោទប្រកាន់ថាឪពុកខ្ញុំខ្សែខ្មាំងចក្រពត្តិអាមេរិក វាគឺជាទម្ងន់អម្រែកលានទុក្ខដែលមិនអាចដោះស្រាយបាន។

បន្ទាប់ពីបានទទួលលិខិតនិងគ្រឿងដ្ឋូនៗពីមេកងសយឲ្យគ្រួសារខ្ញុំទៅនៅទួលស្លាំង។ ថ្ងៃមួយពេលកម្មាភិបាលបញ្ជូនឲ្យឪពុកខ្ញុំទៅកាប់ខសនៅឯព្រៃរនាមមាត់ស្ទឹងគ្រៀង។ ឪពុកខ្ញុំលួចបររទេះគោបង្ហួសទៅភូមិយោតស្រុកកំណើតគាត់ ហើយបាននិយាយរ៉ាយរ៉ាប់រឿងនេះប្រាប់ទៅធំ ទីម ធំហុង ពូហ៊ុល មឹងទូច ដែលជាបងប្អូនបង្កើត។

បងប្អូនទាំងអស់មានទឹកភ្នែករលីងរលោងចេញមកមិនដឹងខ្លួនទឹកអាណិតប្អូននិងបង។ បន្ទាប់មកធំ ទីម ធំហុង បាននិយាយមកកាន់ឪពុកខ្ញុំថា "លោកប្អូនកុំត្រឡប់ទៅភូមិក្រាំងវិញអី នៅលាក់ខ្លួនក្នុងព្រៃព្រែកយោតនេះចុះ បងនិងប្អូនជួយលាក់បំពួនមិនឲ្យអង្គការដឹង"។ លោកឪពុកបន្ត "មិនបានទេលោកបង លោកប្អូន បើធ្វើបែបនេះជាទង្វើមួយមិនគប្បីចំពោះប្រពន្ធកូន និងឪពុកម្តាយក្មេកដែលគេពឹងមកលើយើងតែម្នាក់! ខ្ញុំសច្ចាថាបើស្លាប់ត្រូវតែស្លាប់ទាំងអស់គ្នា បើរស់ត្រូវតែរស់ទាំងអស់គ្នា"។ ម្យ៉ាងទៀតយើងពិបាករត់គេចចេញពីការតាមដានរបស់ពួកគេណាស់។ ប៉ុន្តែខ្ញុំប្រហែលជាលាក់ទុកកូនចិន្តា និងកូនវ៉ា នៅជាមួយតាយាយវាហើយ ខ្ញុំនឹងយកកូនវង្ស និងអាភ្លោះពីរនាក់ទៅជាមួយ។ ឪពុកខ្ញុំបន្តទៀតទាំងអួលដើមក "ខ្ញុំមកនេះគឺមកជម្រាបលាបងនិងប្អូនទាំងអស់ ហើយប្រហែលជាមិនបានជួបគ្នាទៀតទេ"។ បន្ទាប់មកឪពុកខ្ញុំក៏អង្គុយបត់ជើងសំពះជម្រាបលាធំទីម និងធំហុង។ បងប្អូនទាំងប្រាំនាក់ទ្រហោយំក្នុងពោះនូវទម្ងន់ទុក្ខសោកចំពោះមុខបងប្អូន។ ចំណែកធំទីមបានសូត្រធម៌ខ្សឹបៗយកដៃអង្អែលក្បាលឪពុកខ្ញុំក្នុងក្តីអាណិតប្អូន។

និយាយចប់ឪពុកខ្ញុំបររទេះចេញទៅវិញ។ បងប្អូនទាំងបួននាក់លើកដៃវា និងបន្ទឺសំឡេងតាមក្រោយផ្តែផ្តាំថា "សូមលោកប្អូន លោកបង នាំកូនៗបង្ហួសមកភូមិយោតមក កុំចូលទួលស្លាំងអី"។ ឪពុកខ្ញុំងាកមើលក្រោយយកក្រមាជូតទឹកភ្នែកទឹកសម្បោរទុក្ខ ហើយស្រែកទាំងអួលដើមកមកថា "លោកបង លោកប្អូនបើខ្ញុំស្លាប់ទៅជួយមើលកូនៗឲ្យខ្ញុំផង"។

**ពាក្យសម្តីនៃសម្រែកដួងចិត្តពិតជាមានអត្ថន័យរុញច្រានទ្រនំវាសនាឲ្យដួលរញ្ជួយឱរាគួរឲ្យអណោចអាធម្មណាស់។ បងប្អូនបន្ទឺបន្តព្រមៗគ្នា "មិនអីទេ! សង្ឃឹមថាគ្រួសារលោកប្អូន លោកបងបានសេចក្តីសុខធម្មតា!"។**

ពុកខ្ញុំងាកមើលក្រោយឃើញបងប្អូនទាំងបួននាក់លើកដៃសំពះទៅលើ។ គាត់គិតថានេះជាការបន់ស្រន់ដល់អ្នកតាតន់ឲ្យជួយថែរក្សាដល់អ្នកចងក្រង៦ប្រវត្តិអ្នកតា ដែលរូបគាត់កំពង់ទទួលរងនូវទណ្ឌកម្មជីវិតឥតមេត្តា ប្រហារដួងចិត្ត និងគ្រួសារឲ្យព្រាត់ប្រាសនិរាស។

គាត់ងាកមើលក្រោយឃើញតែសំណល់អនុស្សាវរីយ៍ខ្លោចផ្សានៃទឹកចិត្តភក្តី នឹកអាល័យភូមិកំណើត និងទួលអ្នកតាតន់ដែលធ្លាប់មានមហិទ្ធិឫទ្ធិស័ក្តិសិទ្ធិគួរឲ្យគោរពបន់ស្រន់ធ្លាប់អង្គុយរៀនធម៌ រួមរស់ជាមួយគ្នា ពោរពេញដោយមនោសញ្ចេតនា ក្រាបសំពះតាមផ្លូវពុទ្ធោវាទកាលបួសជាសង្ឃ ធ្វើទានដាក់បាត្រសន្សំកុសលដើម្បីទទួលបានសព្វសារធុការពរ ដែលពុទ្ធសាសនិកជនទាំងឡាយប្រាថ្នាចង់បានគ្រប់ៗគ្នា។ តែអ្វីៗមកដល់ពេលនេះត្រូវរលាយបាត់ស្រមោលនៅចុងបញ្ចប់ជីវិតនៃព្រហ្មលិខិតគ្មានមេត្តាដល់គ្រួសារសម្បូរដោយធម៌អាថ៌ចាប់តាំងពីកំណើតរហូតដល់ពេលនេះ។

ពេលវេលាដែលកម្មាភិបាលអង្គការបដិវត្តន៍ប្រមូលគ្រួសារអ្នក១៧ មេសាយកទៅសម្លាប់នៅទួលស្លាំង កាន់តែកក្រើកទៅៗនៃអវសាន

# កម្ដៅការឈឺចាប់អ្នកទោសបដិវត្តន៍![១]

ជីវិតគ្រួសារ ដែលនៅជិតជាមក្នុងអារម្មណ៍ជាអម្រែកទម្ងន់ទុក្ខសោកស្ទើរបោកប្រាណឲ្យដួលរំដួលចិត្តខ្លាំងក្លាយជាបទចម្រៀងខ្ទង់ខែកហែកឲ្យកង្វ័យនោះអ៊ីៗគាត់បានត្រៀមខ្លួនស្លាប់រួចជាស្រេចហើយក្នុងការទិនក្បាលឲ្យពួកបិសាចខោអាវខ្មៅសម្លាប់ ដូចមានក្នុងការរៀបរាប់របស់ពូ យំ ជាអតីតកូនសិស្សពុកធ្លាប់ដើរបិណ្ឌបាត្រកាលឪពុកខ្ញុំបួសជាសង្ឃមកនិយាយប្រាប់ ក្នុងពេលខ្ញុំកំពុងតែស្រងូតស្រងាត់ទាំងទឹកមុខក្រៀមក្រំ។

គាត់បានពោលមកកាន់ខ្ញុំថា "ក្មួយវង្ស ពូអាណិតពុករបស់ក្មួយណាស់ ដែលជាគ្រូរបស់ពូរកអ៊ីមកប្រៀបផ្ទឹមពុំបានទេ ទោះជាគាត់ដឹងថាគេយកគ្រួសារក្មួយទៅសម្លាប់ ក៏លោកបងមិនគេចវេសដែរ។

ក្មួយដឹងទេ ថ្ងៃមួយកាលពីជំនាន់ប៉ុលពត ពេលល្ងាចពួកប្រជាជនមកពីស្រែវិញៗ គេដើរចូលភូមិត្រសងដែលមានបន្ទប់ការឃ្លាំមើលពីកងសន្តិសុខនិងគណៈមុខព្រួញខ្មែរក្រហម តាមពីក្រោយមិនឲ្យយើងនិយាយគ្នាឡើយ។ ពេលនោះពូកំពុងតែបំពក់ភ្លើងដេញមូសក្នុងក្រោលគោ ស្រាប់តែពូឃើញលោកបងដែលជាពុករបស់ក្មួយដើរយឺតៗគេចចេញពីហ្វូងមនុស្សមកកៀនរបងផ្លូវ ហើយក្រឡេកមើលមុខមើលក្រោយ។ ពូលួចមើលបន្តទៀតៗ មេឃងងឹតមើលឃើញស្រមោលមនុស្សស្ងងៗ លោកបងបានដើរមកឈរអែបរបងផ្លូវដែលមានព្រៃល្អុងខ្ទង់ស៊ប់ទ្រុប។

មិនយូរប៉ុន្មានមនុស្សពីរបីនាក់ដែលតាមឃ្លាំមើលពីក្រោយបានស្ទុះមកសួរពុកក្មួយថា "សមមិត្ត ឡូងធ្វើអ្វីនឹង? ម៉េចមិនដើរទៅផ្ទះ ចង់គេចប្រយ៉ាងម៉េច?" ពេលនោះពុកក្មួយបានសោយជើងខោដែលប្រឡាក់សុទ្ធតែភក់រហែករញ៉េររញ៉ៃ ឱនទៅអេះជើង ហើយឆ្លើយប្រាប់គេថា "អូ! សមមិត្តខ្ញុំបេះសត្វឈ្លើងទាមចេញពីជើង"។ ពេលនោះប្រធានកងសន្តិសុខបាននិយាយបន្តថា "បេះឈ្លើងចេញហើយប្រញាប់ទៅផ្ទះ កុំគេចវេស" ហើយលោកបងឆ្លើយថា "បាទសមមិត្ត" ។

បន្ទាប់ពីកម្មាភិបាលនោះដើរទៅបាត់ លោកបងអេះអុញមើលមុខមើលក្រោយ ហាក់ដូចចង់និយាយអ្វីជាមួយពូៗ មើលទៅលោកបងហាក់ដូចជាមានអារម្មណ៍ភ័យខ្លាចមិនហ៊ាននិយាយពូក៏សួរទៅពុកក្មួយទាំងខ្សឹបៗថា លោកបងមានការអ្វីនិយាយមកកុំខ្លាចចិត្តខ្ញុំអី។

បន្ទាប់មកលោកបងងាកមើលជុំវិញខ្លួន ដោយមានសភាពស្ងាត់ គាត់ពោលថា នែ អាក្អូន! តើប្អូនមានដឹងរឿងអ្វីទេ? ព្រោះគ្រួសារបងត្រូវមេកងឲ្យទៅរស់នៅទួលស្លាំង។ ពូបានប្រាប់ទៅពុកក្មួយវិញថា នែលោកបងកុំទៅអី បើលោកបងទៅប្រាកដជាត្រូវគេសម្លាប់នៅទីនោះហើយ ព្រោះខ្ញុំទៅចាំគោមើលឃើញពីចម្ងាយគេចងបណ្ដើរមនុស្សនៅលើទួលនោះមានទាំងកូនក្មេងយំព្រំពង ដោយភាពភ័យខ្លាចៗ អ៊ីចឹងលោកបងគេចខ្លួន



ទិដ្ឋភាពតំណាងៈ ពួកកងឈ្លបសន្តិសុខតាមឃ្លាំមើលឪពុកខ្ញុំខ្លាចក្រែងគាត់គេចវេស បន្ទាប់មកពីស្ទូងស្រែវិញ ។ ( ឡុង វង្សសមិទ្ធ/ សៀវភៅ ទួលពិឃាដ)

ទៅព្រៃចំឡក់បឹងបុស្សី ខាងជើងភូមិយោគទៅ។

អ៊ីៗពុកក្មួយបានដឹងទាំងអស់ តែលោកបងមកសួរពូគ្រាន់ទុកជាដំណឹងបន្ថែម ហើយឲ្យអស់ចិត្តប៉ុណ្ណោះ។ ពេលនោះពុករបស់ក្មួយក៏យកក្រមាជូតទឹកភ្នែកដែលហូរមកស្រាក់ ហើយលោកបងពោលមកថា "ប្អូនអើយ ទោះជាគេចទៅណាក៏មិនរួចដែរ។ គឺចុះទឹកក្រពើ ឡើងលើខ្លា" ហើយគាត់និយាយថា "លាសិនហើយប្អូន អរគុណច្រើន។ ពូមើលទៅដំណើរពុកក្មួយឯង ដើរស្ទើរតែមិនរួចដោយ យកក្រមាមកជូតទឹកភ្នែក ទាំងទឹកមុខក្រៀមស្វិតស្រពោន និងអស់សង្ឃឹម"។

ពូបន្តប្រាប់ខ្ញុំទៀតថា ពុកក្មួយជាអ្នកបួស ដូច្នេះគាត់ប្រកាន់ភ្ជាប់នូវពុទ្ធឱវាទ "ចាញ់បានជាព្រះ ឈ្នះបានជាមារ"។

មកដល់ត្រង់នេះ ខ្ញុំគិតក្នុងចិត្ត ពុកខ្ញុំគាត់មិនដែលគិតអនុវត្តតាមពំនោលមួយឃ្លាដែលខ្ញុំគិតថា "ផ្លូវវៀចកុំបោះបង់ ផ្លូវត្រង់កុំវៀចវេ" នោះទេ។

ពេលនោះពូដែលជាអតីតសិស្សពុកខ្ញុំរៀបរាប់ចប់។ ខ្ញុំពិតជាមានអារម្មណ៍ក្តុកក្តួល សោកសង្វេគ រាប់លានទុក្ខកង្វល់នៃឆាកជីវិតពុកពិតជាមានបញ្ហាច្រើនលើសលុបណាស់ដែលត្រូវដោះស្រាយ ហើយដែលគួរឲ្យអាណិតខ្លោចចិត្តនូវភាពស្លូតស្លាប់ ទោះជាដឹងថាគេយកទៅសម្លាប់យ៉ាងណាក៏ដោយ។ ពេលនោះពូដែលជាអតីតសិស្សរបស់ពុកដឹងថាខ្ញុំមានអារម្មណ៍ក្តុកក្តួល គាត់ក៏ដើរចេញទៅ។ មកដល់ត្រឹមនេះ ខ្ញុំអួលដើមកស្រក់ទឹកភ្នែកនឹកហួសចិត្ត អាណិតឪពុក។

ខ្ញុំពោលក្នុងចិត្តពុកមានចាំទេ ថ្ងៃមួយខ្ញុំឈ្លោយមាត់និយាយប្រាប់កុមារយ៉ាន់រ័ត្ន ជាកុមារមូលដ្ឋានថា ពុកដាំបាយនឹងកំសៀវទឹកឲ្យខ្ញុំ ហូបមុននឹងទៅចាំចាប។ ខ្ញុំហូរទឹកភ្នែកនិយាយសុំទោសពុកនូវកំហុសដ៏ធ្ងន់ស្មើស្លាប់នៃការឈ្លោយមាត់នេះ តែពុកមិនបានស្តីបន្ទោសដល់កូនទេ ថែមទាំងអង្អែលក្បាលកូនហើយ និយាយថា មិនអីទេកូន។

ខ្ញុំ ដឹងទាំងអស់ពុកបាននិយាយលាក់ការពិតច្រើនណាស់ខ្លាចកូនភ័យព្រួយ ចាប់តាំងពីមេកងចុចឈ្មោះគ្រួសារយើងឲ្យទៅទួលស្លាំង។ បន្ទាប់ពីខ្ញុំនិយាយចប់ ពុកបានប្រមូលអង្ករប៉ុន្មានកំប៉ុង នោះយកទៅកប់ចោលក្នុងគុម្ពបេកខ្លាចកងឈ្លបមកអង្កេតឃើញ។ នេះជាទឹកចិត្ត ឪពុកចំពោះកូនមិនអាចកាត់ថ្លៃបាន ដែលជាកាយវិការបង្កប់នូវមនោសញ្ចេតនាជ្រាលជ្រៅរវាងឪពុកនិងកូន។

ស្រមោលស្បែសុបិនអាក្រក់អតីតកាលបានរសាត់បាត់ទៅមែន តែស្លាកស្នាមដំបៅខ្មៅបាននៅដានស្រស់ៗជាមរតកចុកឈាមអំណោយគ្មានមេត្តានៃមេដឹកនាំទុច្ចរិតក្បត់ប្រជាជនផ្តល់ដល់តួអង្គកម្សត់ទារុណកម្មរហូតដល់ស្លាប់។ រសជាតិមួយលានជូរចត់នៃកម្តៅភ្នក់ភ្លើងជីវិតពិតជាក្តៅងំបានដក់ជាប់មិនអាចសាបរលាបបានទោះបីរយខែឆ្នាំដល់ព្រលឹងឈឺចាប់របស់អ្នកទោសបដិវត្តន៍ក្នុងរបបខ្មៅនោះ។

---

# ពន្លឺសម្តីមីងហៀប

**មេត្តូមិអ៊ី, លន់ ចិត្តបុណ្យ**

ក្រោយពីបានទទួលលិខិតពីមេកងសយឲ្យគ្រួសារខ្ញុំទៅនៅទួលស្លាំង។ ម្តាយខ្ញុំពិតជាមានអារម្មណ៍ខ្វាយខ្វល់យ៉ាងខ្លាំងនិងខំប្រឹងរកដំណោះស្រាយស្ទើរបែកធ្លាយដើមទ្រូងអង្រួនបេះដូងឲ្យកក្រើក នឹកស្រណោះពីឆាកជីវិតទុក្ខសោកនេះ។

ថ្ងៃមួយម្តាយខ្ញុំបាននិយាយរឿងនេះប្រាប់មីងហៀបដែលជាសាច់ញាតិស្រឡាញ់រាប់អានគ្រួសារខ្ញុំ។ មីងហៀបធ្លាប់អង្គការចាត់តាំងឲ្យទៅប្រជុំនៅទួលស្លាំង ប្រហែលជាគាត់បានដឹងរឿងច្រើន។

មីងហៀបបាននិយាយខ្សឹប ងាកមើលឆ្វេង មើលស្តាំ ប្រាប់ម្តាយខ្ញុំថា "អ្នកបងឆេងត្រូវតែទៅជួបមេកងកម្មាភិបាលសយ សំពះអង្វរកគាត់ដើម្បីសុំរស់នៅក្នុងភូមិជាមួយឪពុកម្តាយ ព្រោះគាត់ចាស់ៗហើយ។ បើអ្នកបងឆេងមានដូចជា នាឡិកាដៃ ឬមាសខ្សែកចិញ្ចៀនយកឲ្យមេកងសយនោះទៅ ព្រោះមានគ្រួសារខ្លះនៅភូមិផ្សេងបានរួចខ្លួន ដោយគេប្តូរឈ្មោះគ្រួសារ

យើង ហើយយកគ្រួសារថ្មីផ្សេងទៅជំនួស"។

បន្ទាប់មកមីហៀបបន្តទៀត "អ្នកបងដឹងទេ កាលពីជាងមួយខែមុនរូបខ្ញុំនិងអ្នកភូមិដទៃទៀតមានគ្រួសារបង អ៊ួស សាមី ពូ ស្រ៊ុន ពូគី ពូឈួន មីលី និងអ្នកផ្សេងទៀតប្រហែល១៧ នាក់ ត្រូវប្រធានភូមិអ៊ី និងលន់ប្រាប់ឲ្យទៅប្រជុំនៅទួលស្វាំង គេចោទជាខ្មាំងមិនស្មោះត្រង់នឹងបដិវត្តន៍ព្រោះចង់នាំគ្នាប្រមូលផ្តុំកម្លាំងធ្វើបាតុកម្មតវ៉ាដែលខុសពីនយោបាយរបស់អង្គការ ដូច្នេះពួកគេត្រូវតែកម្ទេច តែប្រធានភូមិអ៊ី និងលន់ចិត្តបុណ្យបានលួចខ្សឹបប្រាប់ថា បើគេសួរចម្លើយថា ធ្វើអ្វីពីមុនមកប្រាប់ថាជាកសិករតាំងពីដើមរៀងមកៗ ពេលនោះពួកខ្ញុំក៏ចេញទៅ ទាំងអស់គ្នា។

---

## សន្តិសម្ព័ន្ធ

មកដល់ទួលស្វាំង គេឲ្យនៅរង់ចាំក្នុងរោងតៀមមួយ ជញ្ជាំង និងដំបូលប្រក់ស្លឹកត្នោត យាមដោយកងឈ្លប៦នាក់ ប្រដាប់ដោយកាំភ្លើងអាកាគ្រប់ដៃ។

រង់ចាំជាយូរខ្ញុំក៏សួរទៅកងឈ្លបម្នាក់នៅទីនោះថា នែ! សមមិត្ត! គេឲ្យខ្ញុំមកទីនេះធ្វើអ្វី គេឆ្លើយថា "រង់ចាំបន្តិច"។

បន្តិចក្រោយមកឃើញកងឈ្លបបីនាក់ចូលមក ហើយក៏ចាប់ផ្តើមសួរចម្លើយម្នាក់ម្តងៗ។ ដំបូងគេសួរទៅបងអ៊ួស "មើល! សមមិត្តតាំងពីឆ្នាំ១៩៧០ដល់១៩៧៥ ធ្វើអ្វីខ្លះ?" បងអ៊ួស ឆ្លើយថា ធ្វើជាប្រធានក្រុមក្នុងភូមិក្រាំង កូនធ្វើកងទ័ពរំដោះ"។ ពួកគេសរសេរថា សន្តិសម្ព័ន្ធពីរជាន់។

បន្ទាប់មកដល់វេនពូស្រ៊ុន ពូស្រ៊ុនឆ្លើយថា "ធ្លាប់ធ្វើប្រធានភូមិ ដើរប្រមូលវែអង្ករ ត្រីងៀត ផ្ញើជូនដល់កងទ័ពរំដោះយើងនៅសមរភូមិមុខ ហើយកូនប្រុសពីរនាក់ធ្លាប់ធ្វើជាកងទ័ពរំដោះ"។ ឆ្លើយរួចគេគេដាក់បញ្ចូលក្នុងសន្តិសម្ព័ន្ធពីរជាន់។

បន្ទាប់មកគេសួរ ពូ ឈួន គាត់ឆ្លើយថា "ជាអ្នកដើរកោសខ្យល់ឲ្យប្រជាជនដែលមានអាការៈមិនស្រួលខ្លួន..." ពួកគេសួរបន្តទៀតថា "អ៊ីចឹងសមមិត្តធ្វើពេទ្យមែនទេ?" ខ្ញុំកាត់ហើយប្រកែកទៅពួកគេ" មិនមែនទេ គ្រាន់តែអ្នកភូមិពឹងពាក់ឲ្យកោសខ្យល់ម្តងម្កាលប៉ុណ្ណោះ បើឆ្លើយថាធ្វើពេទ្យគេសម្លាប់បាត់ហើយ។

បន្ទាប់មកដល់វេនពូគី ពូគី ឆ្លើយថា "បានធ្វើកងឈ្លបបីថ្ងៃ" ហើយគេដាក់គាត់ក្នុងសន្តិសម្ព័ន្ធបីថ្ងៃ។ រួចរាល់ហើយពួកគេកាន់ក្រដាសចម្លើយទៅវិញ។

មួយស្របក់ គេត្រឡប់មកវិញ ហើយប្រាប់ថា "ឲ្យឈ្មោះ អ៊ួស និងស្រ៊ុនទៅនៅជាមួយប្រធានសន្តិសុខឌុច សូមកុំបារម្ភអី។ ខ្ញុំក្រឡេកតាមបង្អួចឃើញពួកគេដោះក្រមាចេញពីកអ្នកទាំងពីរយកមកចងស្លាបសេកបណ្តើរទៅ។ មីលី ពួកវាឲ្យចេញតាមទ្វារមួយទៀតទៅក្នុងទួលដែរ ហើយគេប្រាប់ពួកខ្ញុំឲ្យរង់ចាំ។

រង់ចាំជាយូរថ្ងៃហៀបលិចស្រាប់តែឃើញមនុស្សពីរនាក់ជិះម៉ូតូ CL90 មានកាំភ្លើងអាកាស្ពាយពីក្រោយទាំងពីរនាក់ ដែលគេហៅថា គណៈចាត់តាំង កម្មាភិបាលប្រាប់ឲ្យពួកខ្ញុំត្រឡប់មកសហករណ៍វិញ ហើយបន្តទៀតថា "ពេលអង្គការត្រូវការ ត្រូវមកតាមការចាត់តាំង ហើយត្រូវចេះលាក់ការណ៍ និងរាយការណ៍ខ្មាំងជូនអង្គការយើង។ បន្ទាប់មកមីងហៀបបន្តទៀតថា តើរកខ្មាំងរបៀបណា? ពួកគេប្រាប់ថា ប្រជាជនដែលជាអតីតប្រធានភូមិគណៈ "ក, ខ, គ" សុទ្ធសឹងជាខ្មាំងដៃជើងសោភឹម ហៅយ៉ានទ។ ពួកវាបន្តទៀតថា គ្រូពេទ្យ គ្រូបង្រៀន ទាហានប៉ូលិសក៏ជាខ្មាំងដែរៗពុដូច្នោះពួកខ្ញុំចាកចេញមកយ៉ាងលឿនៗ

ដើរចេញពីទួលបានពីរបីស្រែ ឃើញកងឈ្លបបីនាក់រត់មក ហើយស្រែកថា "ឈប់សិន!ៗ មេកងសន្តិសុខត្រូវការសមមិត្តនារីឲ្យជួយដាក់បាយជ្រូកពីរបីថ្ងៃសិន។" ពេលនោះខ្ញុំប្រកែកថា "ខ្ញុំទៅមើលកូនៗនៅឯសហករណ៍"។ មួយភ្លែតនោះ ស្រាប់តែសាមី ប្រពន្ធបងអ៊ួស ឆ្លើយថា "អ៊ីចឹងខ្ញុំត្រឡប់ទៅវិញ" ខ្ញុំបានតបប្រាប់សាមីថា "មិត្តនារីឯងទៅធ្វើអ្វី ទៅផ្ទះទៅ ព្រោះកូនខ្ញីកំពុងពបំបៅដោះនេះ វាយំខ្លាំងណាស់ ហើយកូនតូចៗនៅផ្ទះទៀតៗ តែសាមីមិនព្រម ហើយត្រឡប់ទៅជាមួយពួកឈ្លបនោះវិញទៅ។ តែប្រហែលជាសាមីចង់ដឹងពីប្តី សុខទុក្ខយ៉ាងណា?

ស្អែកឡើង អ្នកឡើងត្នោតនៅទីនោះបានឃើញពួកគេសម្លាប់បងអ៊ួស និង ពូស្រ៊ុន នៅល្ងាចនោះបាត់ ហើយចំណែកមីលីនិងសាមីនៅឃើញដាក់បាយជ្រូក តែបីថ្ងៃក្រោយមកពួកវាសម្លាប់ចោល ទាំងអស់រួមទាំងកូនង៉ែតរបស់សាមីដង ពួកវាបានចាប់បោះចូលទៅក្នុងរណ្តៅ ទាំងរស់។

អ៊ីចឹងអ្នកបងប្រញាប់ប្រញាល់ទៅជួបមេកងសយជាបន្ទាន់ ព្រោះមេកងសយមានសិទ្ធិអំណាចខ្លាំងណាស់។

ម្តាយខ្ញុំងក់ក្បាលជាសញ្ញាជាមួយការរ៉ាយរ៉ាប់ដំរន្ធត់ស្លុតអារម្មណ៍ឥតឧបមា។

# ទម្ងន់ទុក្ខសោកម្តាយ
# ជីវិតខ្សោះឈាម

## មរតកអស់និស្ស័យនៃគំណក់ញើសឈាមបរិសុទ្ធ

បន្ទាប់ពីបានទទួលពន្ទីសម្តីពីមីហៀបមក។ ស្អែកឡើងមកពីវាលវិញ ម្តាយខ្ញុំគាត់មិនបានចូលហូបបាយនៅរោងបាយរួមទេ។ ខ្ញុំសង្កេតមើលគាត់បានចូលទៅក្នុងផ្ទះ ហើយចេញមកវិញយ៉ាងលឿន ដោយមានរបស់របរដាក់ក្នុងថង់ក្រណាត់មូរក្នុងចង្កេះខោខ្មៅផ្ទេរប្រាំប្រឡាក់សុទ្ធតែភក់។

ខ្ញុំដឹងថាគាត់បានយកមាសជាខ្សែក និងគ្រឿងប្រាក់ដែលគាត់បានសន្សំទុកបន្តិចបន្តួចសម្រាប់ចែកកូន សល់ពីប្រាក់ខែជាញើសឈាមបរិសុទ្ធរបស់ឪពុកជាគ្រូបង្រៀនក្នុងការចិញ្ចឹមកូន ៦នាក់។ ម្តាយខ្ញុំដើរយ៉ាងលឿនទាំងជើងទទេទៅផ្ទះសមមិត្តមេភូមិដើម្បីខ្ចីកង់ជិះទៅភូមិជ្រៃនិងភូមិស្វាយរកជួបកម្មាភិបាលមេកងសយ។

យប់ងងឹតមើលឃើញមនុស្សស្ងួនៗម្តាយខ្ញុំដើរមកផ្ទះវិញ។ ឪពុកនិងបងស្រីខ្ញុំអង្គុយចាំនៅកាំជណ្តើរ។ គាត់ទាំងពីរចូលទៅសម្រាន្តទាំងខោអាវប្រឡាក់ភក់ ពោះទទេគ្មានអាហារ។ ឪពុកសួរម្តាយខ្ញុំថា "បានជួបមេកងសយទេ?" ម្តាយខ្ញុំគ្រវីក្បាលហើយពោលថា "មិនបានជួបទេ សួរគេសួរឯងគេថាមេកងទៅប្រជុំនៅថ្នាក់លើ"។

មិនបានប៉ុន្មាននាទីផង ឮសំឡេងស្រែកហៅពីខាងក្រៅផ្ទះ "សមមិត្តឡុងអើយៗ ចេញមកក្រៅ និរសាកម្មាភិបាលមេកងចង់ជួប។" នេះជាសំឡេងសមមិត្តមេគណៈមុខព្រួញរោងបាយ។ ឪពុកម្តាយខ្ញុំចេញមក គេនិយាយមកកាន់គាត់ថា ដល់ថ្ងៃកម្មាភិបាលឲ្យទៅនៅទួលស្វាំង ម៉េចបានសមមិត្តថ្មីឯងមិនទៅ ម្តាយខ្ញុំនិយាយទៅកាន់និរសាទាំងទឹកភ្នែករលីងរលោងយកដៃសំពះថា "សូមសមមិត្តមេត្តាអនុញ្ញាតឲ្យខ្ញុំពីរបីថ្ងៃទៀតមក ខ្ញុំរង់ចាំលាឪពុកម្តាយខ្ញុំសិនគ្រួសារខ្ញុំគង់តែទៅរស់នៅទីនោះទេ សូមសមមិត្តជួយរាយការណ៍ដល់កម្មាភិបាលមេកងសយផង"។

នេះជាលេសម្តាយរបស់ខ្ញុំដើម្បីដកឃ្លាស្វែងរកជួបមេកងសយឲ្យអស់លទ្ធភាពប៉ុណ្ណោះ។ គេតបមកវិញថា "សមមិត្តថ្មីឯងត្រូវទទួលខុសត្រូវចំពោះមុខអង្គការថ្នាក់លើ បើមិនឃើញទៅទេកម្មាភិបាលយើងនឹងមកនាំខ្លួនបន្ទាប់មកពួកគេក៏ចេញទៅវិញ។"

ឪពុកម្តាយខ្ញុំងាកមើលមុខគ្នាដកដង្ហើមធំៗ ទឹកភ្នែកហូរចេញមករឹមៗក្នុងភាពអស់សង្ឃឹមយ៉ាងខ្លាំង ហើយចូលទៅក្នុងផ្ទះសម្រាករៀងៗខ្លួន។ គាត់នៅតែនិយាយខ្សឹបៗ ពោរពេញដោយភាពភ័យខ្លាច និងចំបែងចិត្តវែងឌិរា។

ល្ងាចថ្ងៃបន្ទាប់ពេលខ្ញុំចេញពីរោងបាយរួម ម្តាយខ្ញុំចូលទៅហូបបាយជួបមួយភ្លែតគាត់សួរថា "កូនហូបបាយហើយឬនៅ?" ទាំងទឹកមុខក្រៀមក្រំ ដោយក្តីអាណិតកូនៗ ខ្ញុំឆ្លើយថា "ហើយៗម៉ែ"។ មួយស្របក់ក្រោយមកគាត់មកដល់ផ្ទះរួចចូលទៅក្នុង ហើយចេញមកវិញភ្លាម មានរបស់ដាក់ក្នុងរមូលចង្កេះខោផ្ទេរប្រាំពណ៌ខ្មៅជ្រលក់មក្លឿ ហើយដើរតម្រង់ទៅផ្ទះសមមិត្តមេភូមិដើម្បីខ្ចីកង់ជិះ។ ពេលនោះមេភូមិសួរថា "សមមិត្តនារីទៅណា?" ដោយគាត់មិនបានគិតវែងឆ្ងាយ ម្តាយខ្ញុំឆ្លើយថា "ចាស ខ្ញុំទៅជួបមេកងសយ" មេភូមិ



ទិដ្ឋភាព៖ កញ្ចប់ខ្សែកបន្តិចបន្តួចដែលសល់ពីប្រាក់ខែជាគ្រូបង្រៀនក្នុងការចញ្ចឹមកូនៗ៦នាក់ ដែលម្តាយខ្ញុំយកទៅជូនមេកងសយ សុំគេនៅក្នុងភូមិដើម្បីរស់ (ឡុង វង្សសមិទ្ធ/សៀវភៅទួលពិឃាដ)

ពុកដូច្នេះក៏ប្រាប់ម្ដាយខ្ញុំថា “មិនបានទេ ជាប់រវល់ល្បាតក្នុងភូមិ។”

មេភូមិមិនចង់ឲ្យម្ដាយខ្ញុំជួបមេកងសយឡើយ។ គេពិតជាមានចេតនាទុច្ចរិតសម្លាប់ជាប្រព័ន្ធ។

ម្ដាយខ្ញុំក៏សម្រេចចិត្តដើរជើងទទេទៅភូមិជ្រៃ និងភូមិស្វាយ ដែលមានចម្ងាយប្រហែលជាងបីគីឡូម៉ែត្រ ទាំងមេឃចាប់ផ្ដើមងងឹតរកភ្លៀង។

ឪពុកខ្ញុំអង្គុយរង់ចាំជាមួយបងស្រីយ៉ាងអន្ទះសារដើរចុះដើរឡើង មេឃកាន់តែងងឹតខ្លាំង លាយឡំនឹងតំណក់ទឹកភ្លៀងធ្លាក់មកៗ ម៉្យាងទៀតម្ដាយខ្ញុំដើរតែម្នាក់ឯងបារម្ភខ្លាចជួបកងឈ្លបតាមផ្លូវ ប្រាកដជាគេសង្ស័យ ហើយរឿងរ៉ាវកាន់តែធំ។

ស្រមោលមនុស្សស្គមៗ ដើរពុះជ្រែកទឹកភ្លៀង គឺជាអ្នកម្ដាយ។ ឪពុកនិងបងស្រីខ្ញុំស្ទុះទៅសួរនាំ “យ៉ាងម៉េចហើយម៉ែរ៉ា?” ម្ដាយខ្ញុំគ្រវីក្បាលជាមួយទឹកភ្នែកហើយពោលថា “មិនបានជួបមេកងសយទេ មេភូមិប្រាប់ថា គេទៅប្រជុំនៅថ្នាក់លើមិនទាន់មកវិញ។”

ម៉ែក៏ចូលទៅសម្រាន្តទាំងអស់កម្លាំងល្ហិតល្ហៃខ្សោះឈាមសម្លៀកបំពាក់ទទឹកជោករួចនិយាយគ្នាថា “យើងមិនអាចគេចបានទេ យើងត្រូវតែទៅនៅទួលស្វាំងតាមបញ្ជាមេកងសយ គ្រាន់តែយើងត្រូវគិតថា តើកូនណាត្រូវទុកនៅទីនេះ ហើយកូនណាត្រូវទៅជាមួយ។”

---

# ក្ដីសង្ឃឹមឆ្ងាយហួសពីជើងមេឃ

### រំដោះកូនចេញពីក្រញាំអង្គការបិសាច

ទន្ទឹមនឹងការឈ្លុសឈ្លុលកកាយរកមេកងសយមិនជួប ធ្វើឲ្យម្ដាយខ្ញុំអស់សង្ឃឹមយ៉ាងខ្លាំង។ ព្យុះរលកជីវិតបានបក់បោកមកមិនឈប់ពិតជាធ្វើឲ្យម្ដាយខ្ញុំវិលវល់ស្មាប់អារម្មណ៍រកគិតអ្វីមិនចេញ។

ទុក្ខញាំញីរកកួនពេញប្រាណហើយក៏លែងខ្លាចសេចក្ដីស្លាប់នៅចំពោះមុខទៀតដែរ អ្វីដែលសំខាន់បំផុតនោះពេលអត់ពីឪពុកម្ដាយទៅ តើជីវិតកូនៗនៅរស់របៀបណា ឬក៏គេអាចមកឆក់យកជីវិតតាមក្រោយ ព្រោះកូនៗនៅតូចប្រៀបដូចកូនមាន់ទើបនឹងដុះស្លាបកាក់រៀនដើរតេះតះ។

មួយថ្ងៃៗគាត់អង្គុយត្របោមក្បាលជង្គង់គិតវែងឆ្ងាយពីដំណើរជីវិតកូនៗ ទាំងហូរទឹកភ្នែកសស្រាក់ស្រវាំងនេត្រាមើលអ្វីពុំយល់ពីខ្សែជីវិតដ៏អាប់អួរនេះ។ ម៉្យាងទៀតពេលវេលាអង្គការយកទៅសម្លាប់នៅលើទួលស្វាំងក៏មកដល់។

អំឡុងពេលនោះគាត់បានសម្រេចចិត្តរួចហើយគាត់នឹងយកខ្ញុំ និងប្អូនភ្លោះទាំងពីរទៅជាមួយ។ ព្រោះពេលកន្លងមកគាត់ឃើញខ្ញុំត្រូវមេកងកុមារយកទៅអប់រំធ្វើស៊ូយ ទិតៀន និងដាក់ពិន័យស្ដីបន្ទោសជាហូរហែ ដែលគាត់ពិបាកមើលនឹងភ្នែកណាស់។ ចំណែកប្អូនភ្លោះនៅតូចបើអត់ពីគាត់មិនដឹងថាគេធ្វើបាបប៉ុនណាទេ? ពេលនោះព្រលឹងគាត់ប្រាកដជាមិនស្ងប់ឡើយ បើគាត់ត្រូវគេសម្លាប់ដូច្នេះគាត់សម្រេចចិត្តយកទៅជាមួយ។ តែគាត់លាក់ទុកប្អូនរ៉ា និងបងស្រីចិន្តាឲ្យនៅជាមួយតាយាយ។ ម្ដាយគាត់នៅតែមិនទុកចិត្តអារម្មណ៍មិនស្ងប់សោះ ព្រោះកូនរ៉ានៅតូច ហើយនៅក្នុងភូមិក្រាំងក្បែរទួលស្វាំងទៀតខ្លាចក្រែងពេលគាត់ចាកចេញទៅពួកកងឈ្លបឃើញប្រាកដជាគេតាមយកទៅសម្លាប់ចោល នេះជាការគិតស្មើរបែកទ្រូង អង្រួនបេះដូង។

ថ្ងៃនោះគាត់បានទាញក្បាលកូនរ៉ាមកឱបនឹងដើមទ្រូង ទាំងទឹកភ្នែកលាអាឡោះអាល័យថានឹងមិនបានជួបមុខកូនទៀតទេ ហើយប្រាប់កូនរ៉ាថា “កូនសម្លាញ់! ចូរកូនទៅលេងតា និងអ៊ីនៅភូមិព្រៃក្រឡាញ់តូចចុះ ហើយ

មិនបាច់ត្រឡប់មកវិញទេ នៅលេងទីនោះឲ្យបានយូរបុះ។ គាត់បានលាក់ក្បត់ការពិតមិននិយាយប្រាប់កូនវ៉ាថា អង្គការឲ្យគ្រួសារទៅនៅទួលស្វាំងឡើយ ខ្លាចកូនស្លុតអារម្មណ៍ដូចពេលខ្ញុំឃើញគេជីករណ្តៅ ទុកជាស្រេច។

ស្អែកឡើងព្រលឹងព្រាលៗ កូនវ៉ាក៏លួចរត់រំដោះចេញពីភូមិក្រាំងផ្តោះទៅភូមិព្រៃក្រឡាញ់តូចប្រថុយនឹងគ្រោះថ្នាក់ជាទីបំផុត ក្រោមក្រសែភ្នែកម្តាយខ្ញុំលួចមើលមិនឲ្យកូនដឹងដោយតំណក់ទឹកភ្នែករមៀលធ្លាក់ទាំងមិនដឹងខ្លួន។ មានតែខោខ្លីមួយចង្កេះចងនឹងសម្បារបេកមកដល់ភូមិព្រៃក្រឡាញ់តូចជួបតានិងអ៊ុំ ហើយនិយាយប្រាប់ថា ម្តាយឲ្យមកលេង។

នៅជាមួយអ៊ុំបានមួយយប់ដោយមានការនឹករលឹកឪពុកម្តាយពេក កូនវ៉ាយំស្ទើររាល់យប់ រាល់ថ្ងៃ ទឹកភ្នែកទឹកសម្បោរ ហូរអណ្តឺតអណ្តក ទោះជាតានិងអ៊ុំ លួងលោមយ៉ាងណាក៏ដោយ។ តានិងអ៊ុំដឹងថា ម្តាយខ្ញុំបានរំដោះកូនវ៉ាចេញពីក្រញាំអង្គការបិសាច ទុកឲ្យតានិងអ៊ុំ ជួយមើលថែរក្សាជីវិត ព្រោះគ្រួសារកូន និងប្អូនមិនដឹងគេសម្លាប់នៅពេលណា។

កូនវ៉ា វាយំខ្លាំងពេក តាពិតជាតឹងទ្រូង និងមានការបារម្ភយ៉ាងខ្លាំងខ្លាចក្រែងឮសំឡេងដល់កងឈ្លបកម្មាភិបាលបដិវត្តន៍ គេប្រាកដជាដឹងថា យើងលាក់បំពួនឈាមខ្មាំងប្រឆាំងបដិវត្តន៍ នោះនឹងមានរឿងរ៉ាវកាន់តែធំៗ ដោយខ្លាចអង្គការបដិវត្តន៍ដឹង មុនថ្ងៃម្តាយខ្ញុំចាកចេញទៅទួលស្វាំងប៉ុន្មានថ្ងៃ តាក៏សម្រេចចិត្តនាំចៅដើរមកភូមិក្រាំងវិញទាំងទឹកភ្នែកអាណិតដល់កូនស្រីខ្លោចចិត្ត។ ខ្លាចថា ឪពុកនិងបងស្រីចិត្តមិនបាន ហើយបាននិយាយប្រាប់កូនស្រីថា ឲ្យពុកសុំទោសផង ដែលពុកមិនអាចលាក់ទុកចៅឲ្យនៅក្នុងភូមិព្រៃក្រឡាញ់តូចបានដោយចៅវ៉ាវាយំ ហើយម្យ៉ាងទៀតខ្លាចអង្គការដឹង ដូច្នេះពុកសម្រេចនាំចៅមកវិញ។ ម្តាយខ្ញុំមិនមានមាត់កអ្វីដែរ។ វាជាវាសនា និងព្រហ្មលិខិតដែលកម្រិតឲ្យកូនវ៉ា និងឪពុកម្តាយបានជួបមុខគ្នាជាចុងក្រោយមុនពេលដែលគាត់ត្រូវគេសម្លាប់។

យប់នោះ ពេលនោះ ម៉ោងនោះ គាត់ទាំងពីរមិនទាន់សម្រាន្តទេ។ គាត់កំពុងគិតយ៉ាងវក់វីក្នុងអន្ទង់ទឹកភ្នែកកម្មនៃសង្គមអន្យតិត្ថិយ មិនប្រណីដល់ជីវិតប្រជាជនស្លូតត្រង់ដែលគ្មានជីវិតសុំរស់រានទាំងគ្មានវិញ្ញាណជួបជុំគ្រួសារតែប៉ុណ្ណោះ។ សំឡេងជជែកគ្នាខ្សោយទៅៗ ម្តងឮម្តងបាត់រហូតស្ងាត់ឈឹង គាត់ទាំងពីរ ហាក់ដូចជាអស់កម្លាំងកាយ និងចិត្ត។

## សំឡេងអន្ទងមរណៈ

គាត់ឈប់ជជែកគ្នាមិនបានប៉ុន្មានផងក៏ឮសំឡេងស្រែកហៅពីខាងក្រៅល្ហើយៗ គឺមិនខុសពីមនុស្សមុនទេ។

ឪពុកម្តាយខ្ញុំក៏ចេញមកជួប ទាំងមិនទាន់ជូតទឹកភ្នែកផង។ ពាក្យសម្តីសំឡេងសំនៀងខ្លោចផ្សារមិនខុសពីមុនឡើយ ហៅអន្ទងខាបច្បាមយកព្រលឹងគ្រួសារខ្ញុំឲ្យទៅនៅទួលនោះ ម្តាយខ្ញុំក៏តបវិញថា នឹងហើយគ្រួសារខ្ញុំ នឹងធ្វើតាមបញ្ជាកម្មាភិបាលមេកងសយ ស្អែកឡើងខ្ញុំនឹងរៀបចំអីវ៉ាន់ចេញទៅហើយ។

នីរសារនោះចេញទៅវិញដោយបោះសម្តីគ្រោតគ្រាតថា សមមិត្តថ្មីឯងត្រូវធ្វើតាមបញ្ជាមេកងសយនេះឲ្យបាន។

រូបក្របមុខ៖

អ្នកបើកបររថភ្លើងរឺយក្មេងដែលភាគច្រើនគឺជាក្មេងជំទង់បើកបរយកប្រជាជនកម្ពុជារាប់ម៉ឺននាក់ពីតាមបណ្ដាទីតាំងនានា
ក្នុងផ្ទៃប្រទេសទៅកាន់ភូមិភាគពាយ័ព្យដែលមានខេត្តពោធិ៍សាត់ និងបាត់ដំបង នៅអំឡុងរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទទួលបានប្រអប់អនុស្សាវរីយ៍ពីអ្នកស្ម័គ្រចិត្តកម្ពុជាដែលកំពុងធ្វើការ
នៅតាមតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 268, April 2022 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.